## ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន ក្នុងខេត្តស្វាយរៀង

# PREPARATION AND IMPLEMENTATION OF SCHOOL ANNUAL OPERATION PLAN IN SVAY RIENG PROVINCE

**ដោយ**/by

**ទេព គង្គា**/TEP KONGKEA

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២០**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការរៀបចំ និងការអនុវត្ត
# ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
# ករណីសិក្សា៖ ខេត្តស្វាយរៀង

PREPARATION AND IMPLEMENTATION OF SCHOOL ANNUAL OPERATION PLAN CASE STUDY: SVAY RIENG PROVINCE

ដោយ/by

ទេព គង្គា/TEP KONGKEA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ
ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

សាស្ត្រាចារ្យណែនាំ៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

សាស្ត្រាចារ្យណែនាំរង៖ លោក សៀង វាសនា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ករណីសិក្សាៈ ខេត្តស្វាយរៀង**» សម្រាប់បំពេញលក្ខខណ្ឌទទួលសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ………………….ខែ............. ឆ្នាំ................. ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..... ខែ...... ឆ្នាំ ២០២០

**ហត្ថលេខា**

**ទេព គន្ធា**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជាសាស្ត្រាចារ្យណែនាំ

លោក **សៀង វាសនា** ជាសាស្ត្រាចារ្យណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ទេព គន្ធា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ករណីសិក្សា៖ ខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃ................. ខែ................. ឆ្នាំ............. ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ....... ឆ្នាំ២០២០

...............................

...............................

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា**

នាយកវិទ្យាស្ថានជាតិអប់រំ

លោក **សៀង វាសនា**

មន្ត្រីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ [illegible] អយក.ឧទ្ទ

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ អាចសម្រេចដល់គោលដៅប្រកបដោយភាពជោគជ័យ គឺដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានាក្នុងការផ្តល់ឱកាសជួយសម្របសម្រួលនិងជ្រោមជ្រែងតាំងពីដើមរហូតដល់ចប់។ ហេតុនេះ ខ្ញុំបាទដែលជាអ្នកសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ជំបូន្មាន ឧបត្ថម្ភគាំទ្រ និងផ្តល់ឱកាសឱ្យខ្ញុំរៀនសូត្រទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

ម្តាយក្មេក និងភរិយាជាទីស្រលាញ់ ដែលតែងតែលើកទឹកចិត្ត និងគាំទ្រដល់ការបន្តការសិក្សារបស់ខ្ញុំដោយមិនគិតពីការនឿយហត់។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឱ្យខ្ញុំបាទមានឱកាសបន្តការសិក្សានៅទីនេះ។

គណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** ជាសាស្ត្រាចារ្យណែនាំបង្គោល ដែលតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្តល់គំនិតណែនាំជាទ្រឹស្តីល្អៗ កែលម្អចំណុចខ្វះខាត ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត បច្ចេកទេស និងវិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ ឯកឧត្តមបានផ្តល់ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ។

លោក **សៀង វាសនា** ជាសាស្ត្រាចារ្យណែនាំរងដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការកែសម្រួល រចនាបទ ឃ្លាប្រយោគ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួលកម្រងសំណួរផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការវិភាគទិន្នន័យផងដែរ។

មិត្តរួមថ្នាក់ជំនាន់ទី៧ទាំងអស់ ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅនៃការស្រាវជ្រាវក្នុងការសរសេរនិក្ខេបបទនេះ។

គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកពាក់ព័ន្ធភាគសំណាកទាំងអស់ដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការផ្តល់ទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរ ដល់អ្នកមានគុណទាំងទ្វេ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍន៍ ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ........ I

**លិខិតបញ្ជាក់** ........ II

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ III

**លិខិតថ្លែងអំណរគុណ** ........ IV

**មាតិកា** ........ VI

**បញ្ជីតារាង** ........ X

**បញ្ជីក្រាហ្វ** ........ XI

**បញ្ជីអក្សរកាត់** ........ XII

**មូលន័យសង្ខេប** ........ XIV

ABSTRACT ........ XVII

**ជំពូកទី១** ........ 1

**សេចក្តីផ្តើម** ........ 1

១.១. សាវតារ ........ 2

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 8

១.៣. គោលបំណងនៃការស្រាវជ្រាវ ........ 13

១.៤. សំណួរស្រាវជ្រាវ ........ 13

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ 13

១.៦. ដែនកំណត់ និងវិសាលភាព ........ 14

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 15

**ជំពូកទី២ រំលឹកទ្រឹស្តី** ........ 17

២.១. ប្រវត្តិនៃការរៀបចំផែនការ ........ 17

២.២. ការរៀបចំផែនការបែបប្រពៃណី ..... 18

២.៣. ការរៀបចំផែនការយុទ្ធសាស្ត្រ ..... 21

២.៤. គោលការណ៍សំខាន់ៗនៃការរៀបចំផែនការអប់រំនៅកម្ពុជា ..... 23

២.៥. ការរៀបចំផែនការវិស័យអប់រំ ..... 28

**២.៥.១. លក្ខណៈសម្បត្តិនៃផែនការវិស័យអប់រំដ៏ល្អមួយ ..... 28**

**២.៥.២. ផ្នែកសំខាន់ៗនៃដំណើរការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព ..... 29**

**២.៥.៣. ជំហានសំខាន់ៗក្នុងការរៀបចំផែនការ ..... 31**

២.៦. គោលការណ៍រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១ ..... 48

**២.៦.១. ពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ..... 50**

**២.៦.២. តារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១ ..... 50**

២.៧. អត្ថប្រយោជន៍នៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ..... 54

២.៨. ពន្យល់ពាក្យគន្លឹះ ..... 55

**២.៨.១. តើអ្វីគឺជាផែនការ? ..... 55**

**២.៨.២. តើអ្វីគឺជាផែនការអប់រំ? ..... 58**

**២.៨.៣. ផែនការប្រតិបត្តិប្រចាំឆ្នាំ ..... 59**

២.៩. ដំណើរការនៃការរៀបចំផែនការអប់រំ ..... 60

**២.៩.១. ការរៀបចំផែនការ ..... 61**

**២.៩.២. ការអនុវត្តផែនការ ..... 62**

**២.៩.៣. ការវាយតម្លៃផែនការ ..... 63**

**ជំពូកទី ៣ វិធីសាស្ត្រស្រាវជ្រាវ ..... 65**

៣.១. គម្រោងវិភាគ ..... 65

៣.២. ការប្រមូលទិន្នន័យ ........ 65

៣.៣. ឧបករណ៍ស្រាវជ្រាវ ........ 66

៣.៤. ការជ្រើសរើសភាគសំណាក ........ 68

៣.៥. ការវិភាគទិន្នន័យ ........ 70

**ជំពូកទី៤** ........ 72

**លទ្ធផល និងការពិភាក្សា** ........ 72

៤.១. ផ្នែករៀបចំផែនការ ........ 72

៤.១.១. ស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្នុងក្របខ័ណ្ឌទូទាំងខេត្ត)..72

៤.១.២. ស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ) ........ 76

៤.១.៣. សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត) ........ 79

៤.១.៤. សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌសាលានីមួយៗ) ........ 81

៤.២. ផ្នែកអនុវត្តផែនការ ........ 84

៤.២.១. ស្ថានភាពអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្របខ័ណ្ឌទូទាំងខេត្ត) ........ 84

៤.២.២. ការអនុវត្តសកម្មភាពក្នុងការជួសជុល និងសាងសង់(ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ) ........ 86

៤.២.៣. ការអនុវត្តសកម្មភាពក្នុងការកែលម្អបរិស្ថាន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ) ........ 88

៤.២.៤. ការអនុវត្តសកម្មភាពក្នុងការបង្រៀន និងរៀន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ) ........ 89

៤.២.៥. ការអនុវត្តសកម្មភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈ (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ) ........ 90

៤.៣. បញ្ហាប្រឈមក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត) ........ 92

៤.៣.១. បញ្ហាប្រឈមកត្តាគ្មានតម្លាភាពថវិកា (ក្របខ័ណ្ឌសាលានីមួយៗ) ........ 93

៤.៣.២. បញ្ហាប្រឈមកត្តាកង្វះសមត្ថភាព (ក្របខ័ណ្ឌសាលានីមួយៗ) ........ 94

**៤.៣.៣. បញ្ហាប្រឈមកត្តាខ្វះការចូលរួម (ក្របខ័ណ្ឌសាលានីមួយៗ) ......95**

**៤.៣.៤. បញ្ហាប្រឈមកត្តាថវិកាធ្លាក់យឺត (ក្របខ័ណ្ឌសាលានីមួយៗ) ......96**
៤.៤. តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ(ក្របខ័ណ្ឌទូទាំងខេត្ត) ......97

៤.៥. ការពិភាក្សា ......99

**៤.៥.១. ស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ......99**

**៤.៥.២. ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ...... 101**

**៤.៥.៣. តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ ......102**
**ជំពូកទី៥** ......104

**សេចក្តីសន្និដ្ឋាន និងសំណូមពរ** ......104

៥.១. សេចក្តីសន្និដ្ឋាន ......104

៥.២. សំណូមពរ ......107

ឯកសារយោង ...... 110

ឧបសម្ព័ន្ធ(ក) ......1

ឧបសម្ព័ន្ធ(ខ) ......9

# បញ្ជីតារាង

*តារាងទី1៖ ភាពខុសគ្នាសំខាន់ៗ រវាងការរៀបចំផែនការបែបប្រពៃណី និងការរៀបចំផែនការយុទ្ធសាស្ត្រ*.......... 22

*តារាងទី2៖ ពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ*.................................................................. 50

*តារាងទី3៖ តារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១*........................................................................... 50

*តារាងទី4៖ ចំនួនវិទ្យាល័យ ចំនួនបុគ្គលិកអប់រំ និងចំនួនសំណាកដែលបានជ្រើសរើសតាមស្រុកនីមួយៗ*..........69

*តារាងទី5៖ ស្ថានភាពអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្របខ័ណ្ឌទូទាំងខេត្ត)*........................86

# បញ្ជីក្រាហ្វ

*ក្រាហ្វទី 1៖ តួនាទីរបស់អ្នកចូលរួមបំពេញកម្រងសំណួរ*......................................................... 70

*ក្រាហ្វទី 2៖ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្នុងក្របខ័ណ្ឌទូទាំងខេត្ត)*......................... 75

*ក្រាហ្វទី 3៖ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*...............79

*ក្រាហ្វទី 4៖ សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)*...........................................81

*ក្រាហ្វទី 5៖ សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌសាលានីមួយៗ)*....................................84

*ក្រាហ្វទី 6៖ ការអនុវត្តសកម្មភាពក្នុងការជួសជុល និងសាងសង់(ក្របខ័ណ្ឌសាលានីមួយៗ)*..........................87

*ក្រាហ្វទី 7៖ការអនុវត្តសកម្មភាពក្នុងការកែលម្អបរិស្ថាន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*..........................89

*ក្រាហ្វទី 8៖ ការអនុវត្តសកម្មភាពក្នុងការបង្រៀន និងរៀន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*..................... 90

*ក្រាហ្វទី 9៖ការអនុវត្តសកម្មភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈ (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*..........................91

*ក្រាហ្វទី 10៖ បញ្ហាប្រឈមក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)*............................ 93

*ក្រាហ្វទី 11៖ បញ្ហាប្រឈមកត្តាគ្មានតម្លាភាពថវិកា (ក្របខ័ណ្ឌសាលានីមួយៗ)*...........................................94

*ក្រាហ្វទី 12៖ បញ្ហាប្រឈមកត្តាកង្វះសមត្ថភាព (ក្របខ័ណ្ឌសាលានីមួយៗ)*............................................. 95

*ក្រាហ្វទី 13៖ បញ្ហាប្រឈមកត្តាខ្វះការចូលរួម (ក្របខ័ណ្ឌសាលានីមួយៗ)*..................................................96

*ក្រាហ្វទី 14៖ បញ្ហាប្រឈមកត្តាថវិកាធ្លាក់យឺត (ក្របខ័ណ្ឌសាលានីមួយៗ)*.................................................97

*ក្រាហ្វទី 15៖ តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ(ក្របខ័ណ្ឌទូទាំងខេត្ត)*..........................................99

# បញ្ជីអក្សរកាត់

AOP- Annual Operation Plan ផែនការប្រតិបត្តិប្រចាំឆ្នាំ

BSP- Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិកា

D-PB- District's Program Budget ថវិកាកម្មវិធីរបស់ក្រុង/ស្រុក

D-AOP- District's Annual Operation Plan ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រុង/ស្រុក

D-BSP- District's Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិការបស់ក្រុង/ស្រុក

D-SDP- District's Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍក្រុង/ស្រុក

DTMT- District Training and Monitoring Team ក្រុមបំប៉ន និងត្រួតពិនិត្យតាមដានក្រុង-ស្រុក-ខណ្ឌ

DOE- District Office of Education ការិយាល័យអប់រំស្រុក

EFA- Education for All ការអប់រំសម្រាប់ទាំងអស់គ្នា

ESD- Education Sector Diagnosis ហេតុវិនិច្ឆ័យវិស័យអប់រំ

ESP- Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

EMIS- Education Management Information System ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

LSSC- Local School Support Committee គណៈកម្មការទ្រទ្រង់សាលារៀន

MoEYS- Ministry of Education, Youth and Sports ក្រសួងអប់រំ យុវជន និងកីឡា

MDG- Millennium Development Goals គោលដៅអភិវឌ្ឍសហសវត្សរ៍

M-ESP- Ministry's Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួង

M-PB- Ministry's Program Budgeting ថវិកាកម្មវិធីរបស់ក្រសួង

M-BSP- Ministry's Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង

M-AOP- Ministry's Annual Operation Plan ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួង

NP-SNDD- National Program for Sub-National Democratic Development កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ

P-ESP- Province's Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខេត្ត

P-BSP- Province's Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិការបស់ខេត្ត

P-PB- Province's Program Budgeting ថវិកាកម្មវិធីរបស់ខេត្ត

P-AOP- Province's Annual Operation Plan ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរ

POE- Provincial Office of Education មន្ទីរអប់រំ យុវជន និងកីឡា

PB- Program Budgeting ថវិកាកម្មវិធី

SDG- Sustainable Development Goals គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

SWOT- Strength, Weakness, Opportunity and Threat ភាពខ្លាំង ភាពខ្សោយ ឱកាស និងឧបសគ្គ

S-SDP- School's Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍរបស់សាលារៀន

S-BSP- School's Budget Strategic Plan ផែនការយុទ្ធសាស្ត្រថវិការបស់សាលារៀន

S-PB- School's Program Budget ថវិកាកម្មវិធីរបស់សាលារៀន

S-AOP- School's Annual Operation Plan ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

UNESCO- United Nations Educational Scientific and Cultural Organization អង្គការវប្បធម៌ និងវិទ្យាសាស្ត្រអប់រំរបស់អង្គការសហប្រជាជាតិ

# មូលន័យសង្ខេប

គោលបំណងនៃការសិក្សាគឺដើម្បីកំណត់ពីស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់វិទ្យាល័យនានាក្នុងខេត្តស្វាយរៀង និងកំណត់ពីតម្រូវការបណ្តុះបណ្តាលសម្រាប់អ្នករៀបចំ និងអ្នកអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន។ សំណួរស្រាវជ្រាវចំនួនពីរ ត្រូវបានលើកឡើង។ ដើម្បីសម្រេចបាននូវគោលបំណងនេះ អ្នកសិក្សាស្រាវជ្រាវបានធ្វើការស្ទង់មតិតាមរយៈកម្រងសំណួរបំពេញ និងសម្ភាសន៍ដែលជាវិធីសាស្ត្រដ៏សំខាន់ក្នុងការប្រមូលទិន្នន័យ។ អ្នកចូលរួមឆ្លើយសរុបចំនួន១០០នាក់ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពីវិទ្យាល័យចំនួន៨ ក្នុងនោះ នាយក-នាយិកាសាលា៨នាក់ នាយករង-នាយិការង៨នាក់ គណនេយ្យសាលា៤នាក់ ប្រធានក្រុមបច្ចេកទេស១១នាក់ និងគ្រូបង្រៀនចំនួន៦៩នាក់។ ក្នុងការសិក្សាប្រធានបទនេះឱ្យទទួលបានជោគជ័យ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រចម្រុះតាមបែបបរិមាណវិស័យនិងគុណវិស័យ ហើយវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធី Excel។

តាមរយៈការសិក្សា បានបង្ហាញឱ្យឃើញថា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងក្របខ័ណ្ឌទូទាំងខេត្ត មិនទាន់បានល្អនៅឡើយទេ ដោយការរៀបចំពុំមានលក្ខណៈជាយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពុំឆ្លើយតបទៅនឹងបញ្ហាប្រឈមនិងតម្រូវការជាក់ស្តែងរបស់សាលារៀន និងមិនឆ្លើយតបទៅនឹងគោលនយោបាយនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ អ្នកចូលរួមឆ្លើយ៦០% បញ្ជាក់ថាការរៀបចំផែនការគឺធ្វើឡើងតែនាយក នាយករង និងគណនេយ្យដោយពុំមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ចំណែកឯការអនុវត្តផែនការក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀង ក៏ពុំទាន់ទទួលបានលទ្ធផលល្អប្រសើរផងដែរ ដោយសម្រេចបានក្រោម ៦០%។ ប៉ុន្តែបើពិនិត្យក្នុងក្របខ័ណ្ឌសាលាវិញ សាលាដែលធ្វើផែនការដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ គឺអនុវត្តបានភាគរយខ្ពស់ជាងសាលាដែលរៀបចំដោយគ្មានការចូលរួម ។ ដូចនេះជារួមគឺលទ្ធផលមិនទាន់ឆ្លើយតបទៅនឹងគោលនយោបាយអប់រំនោះទេ ដោយសារ

ទាក់ទងទៅនឹងការរៀបចំផែនការគ្មានលក្ខណៈជាយុទ្ធសាស្រ្ត គ្មានការចូលរួម កត្តាសមត្ថភាពនៅមានកម្រិតទាប អ្នកចូលរួមអនុវត្តពុំទាន់មានមូលដ្ឋានគ្រឹះច្បាស់លាស់ ក្នុងការកសាងផែនការដ៏ល្អមួយ មិនយល់ច្បាស់ពីជំហាននីមួយៗនៃការរៀបចំផែនការ និងមិនបានធ្វើហេតុវិនិច្ឆ័យពីស្ថានភាពអប់រំឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយមុននឹងរៀបចំផែនការ។

ដោយឡែក ផ្នែកតម្រូវការបណ្តុះបណ្តាលសមត្ថភាពបន្ថែមក្នុងក្របខ័ណ្ឌទូទាំងខេត្ត មានអ្នកចូលរួមលើ៩០% ត្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំលើចំណុចចំនួន៥គឺៈ (១) របៀបទាក់ទាញសហគមន៍ (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង (៥) ការអនុវត្តផែនការ។ នេះសបញ្ជាក់ឱ្យឃើញថា អ្នកចូលរួមទាំងអស់មានគោលបំណង និងឆន្ទៈមោះមុត ក្នុងការទទួលបាននូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដើម្បីចូលរួមរៀបចំ និងអនុវត្តផែនការរបស់សាលារៀនឱ្យមានការរីកចម្រើនប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្រ្ត និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ទន្ទឹមនឹងនោះក៏មានសំណូមពរមួយចំនួនត្រូវបានដាក់ស្នើដល់ក្រសួងអប់រំ យុវជន និងកីឡា សាលារៀន និងសហគមន៍ផងដែរ។ ចំពោះក្រសួងអប់រំ យុវជន និងកីឡា គឺសំណូមពរឱ្យផ្តល់វគ្គបណ្តុះបណ្តាលលើផ្នែក (១) របៀបទាក់ទាញសហគមន៍ (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ (៥) ការអនុវត្តផែនការទៅដល់គណៈគ្រប់គ្រងសាលារៀន និងសូមឱ្យទម្លាក់ថវិកាបានទាន់ពេលវេលា ព្រមទាំងពង្រឹងយន្តការត្រួតពិនិត្យតាមដានការប្រើប្រាស់ថវិកាឱ្យបានហ្មត់ចត់ និងច្បាស់លាស់។ ចំពោះសាលារៀនគួរតែផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ឱ្យបានពេញលេញទៅតាមនីតិវិធី និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ចំពោះសហគមន៍ សូមឱ្យចូលរួមសហការ និងគាំទ្រគ្រប់សកម្មភាពរបស់សាលារៀន ចូល

រួមរៀបចំ អនុវត្ត និងពិនិត្យតាមដានផែនការរបស់សាលារៀន ដើម្បីជានាឱ្យសាលារៀនមានការអភិវឌ្ឍដោយលទ្ធផលសិក្សារបស់សិស្សមានការកើនឡើង និងការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព។

# Abstract

The purposes of the study were to understand the preparation processes and the level of implementation of school annual operation plan (AOP), in selected high schools of Svay Rieng province. Two basic questions were raised to understand the current situation in the preparation and implementation of the school's AOP and the training requirements for planners and implementers of the school's AOP. To Achieve these researcher conducted surveys through questionnaires and interviews. These are the methods of data collection in response to the research questions and purposes. A total of 100 respondents (8 principals, 8 deputy principals, 4 school accountants, 11 technical team leaders, and 69 teachers) were randomly selected from 8 high schools to participate in this study. To conduct a successful study for this research, the researcher used blended method (Quantitative and Qualitative) and analyzed data using Microsoft Excel.

Based on the result of research, it was found that the preparation of the schools AOP across the province is not good enough and does not respond to the policy of the Ministry of Education, Youth and Sports, (MoEYS) as most of them were planned without strategic, transparency, accountability, unprofessional use of funds and broad participation from all relevant stakeholders. In general, 60% of schools AOP were developed by a small number of stakeholders, failing to meet the education policies, challenges and specific needs of other stakeholders, resulting in a lack of cooperation, participation and support from them.

Meanwhile, the implementation of the plan in schools of Svay Rieng province involving in the study achieving less than 60%. However, the percentage of that with the participation of all stakeholders is higher than that of the schools without the participation of all stakeholders. In general, the results have not yet responded to the education policy due to the lack of strategic planning, the lack of participation, the capacity of planners are still limited and the participants have not yet had a clear foundation of good planning. One does not fully understand each step of the plan and does not judge the educational situation clearly and comprehensively before planning.

In terms of the needs for additional capacity training within the province, there are more than 90% of participants need to be trained in educational planning on the 5 main areas: (1) how to attract the community (2) education sector diagnosis (3) steps in planning (4) plan monitoring and evaluation; and (5) plan implementation. It illustrates that all participants willing to receive training for capacity development in the preparation and implementation of the school plans that responses to strategic plans and policies of MoEYS.

The last but not least, a number of proposals have been submitted to the MoEYS, schools ,and communities. For the MoEYS, it is suggested to provides training on (1) how to attract the community (2) education sector diagnosis (3) steps in planning (4) plan monitoring and evaluation; and (5) plan implementation. It is also suggested to transect the budget on time and to strengthen the mechanism of monitoring the use of budget thoroughly and clearly. For schools, it is suggested that they should invilve all stakeholders to fully participate in the preparation and implementation of the school's annual operation plan and based on the procedures and policies of the MoEYS. For communities, it is suggested that they should cooperates and supports all school activities by participating in preparing, implementing and monitoring the school plans to ensure that the school develops student learning outcomes and the education as a whole is effective and qualified.

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្ដីផ្ដើម

រាជរដ្ឋាភិបាលបាននឹងកំពុងយកចិត្តទុកដាក់ជាខ្លាំងក្នុងការធ្វើឱ្យប្រសើរឡើង នូវការអភិវឌ្ឍសាលារៀនតាមរយៈការបង្កើនថវិកាពីមួយឆ្នាំទៅមួយឆ្នាំ។ សម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ ថវិកាសម្រាប់វិស័យអប់រំបានកើនឡើងជាគំហុក និងនៅតែបន្តកើនឡើងបន្ថែមទៀតនៅឆ្នាំ២០២១ ហើយភាគច្រើនផ្ដោតលើគ្រូបង្រៀន និងសាលារៀន។ ស្របនឹងការវិនិយោគថវិកាដ៏ច្រើននេះ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននីមួយៗ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែក ធ្វើឱ្យប្រសើរឡើងនូវការអប់រំ ប្រកបដោយសមធម៌ និងបរិយាបន្ន។ ផែនការអភិវឌ្ឍន៍សាលារៀនជាផែនទីបង្ហាញផ្លូវដែលរៀបចំឡើងដើម្បីធ្វើការផ្លាស់ប្ដូរកែលម្អឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់សិស្ស ឆ្លើយតបទៅនឹងទស្សនវិស័យ និងបេសកកម្មរបស់សាលារៀន។

ផ្អែកលើនិន្នាការអប់រំសកល ក្រសួងអប់រំ យុវជន និងកីឡា បានផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាពអប់រំ។ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងក៏បានប្ដេជ្ញាចិត្តថានឹងសម្រេចឱ្យបាននូវមុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលគឺ "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" តាមរយៈការធ្វើកំណែទម្រង់វិស័យអប់រំជាបន្តបន្ទាប់។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបន្តពង្រឹងយុទ្ធសាស្ត្រនៃការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ដើម្បីធានាបាននូវការដឹកនាំ និងគ្រប់គ្រងសាលារៀន ការបង្រៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

ការរៀបចំ និងការអនុវត្តផែនការរួមទាំងការដឹកនាំ និងការគ្រប់គ្រងសាលារៀនផ្អែកលើលទ្ធផលធ្វើឱ្យសាលារៀនបង្កើនស្វ័យភាពរបស់ខ្លួន និងមានភាពជាម្ចាស់រួមទាំងមានជំនាញ និងចំណេះដឹងទូលំទូលាយក្នុងការធ្វើឱ្យសាលារៀនទទួលបាននូវការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ។ ម្យ៉ាងទៀតតាមរយៈការបំពេញការងាររបស់ខ្លួន សាលារៀនអាចធ្វើការឆ្លុះបញ្ចាំងទៅលើគោលការណ៍ គោលនយោបាយ សេចក្ដីណែនាំ លិខិតបទដ្ឋាននានាដើម្បីប្រាកដថាការអនុវត្តផែនការ និងការដឹកនាំនិងគ្រប់គ្រងសាលា

រៀនស្ថិតនៅកម្រិតណា ហើយអាចឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡាកម្រិតណាដែរ។

ការរៀបចំផែនការអប់រំគឺជាការអនុវត្តមួយដែលសំដៅលើការរៀបចំប្រព័ន្ធអប់រំ សម្រាប់ពេលអនាគត និងសំដៅជួយសម្រេចបាននូវគោលបំណងរយៈពេលមធ្យម និងរយៈពេលវែងដែលត្រូវបានធ្វើឡើងសម្រាប់វិស័យនេះដើម្បីឱ្យមន្ត្រីអប់រំថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ បំពេញការងារប្រកបដោយប្រសិទ្ធភាព យល់ដឹងច្បាស់ពីបញ្ញត្តិជាគន្លឹះនៃការធ្វើផែនការអប់រំ និងជំហានសំខាន់ៗនៃការរៀបចំផែនការអប់រំ។

ដើម្បីអនុវត្តគម្រោងកម្មវិធី និងសកម្មភាពណាមួយរបស់មនុស្សប្រកបដោយភាពជោគជ័យ ចាំបាច់ត្រូវតែមានការរៀបចំគម្រោងផែនការ។ ផែនការគឺជាឆន្ទៈ និងគោលបំណងនាពេលអនាគតដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ទុកជាមុន ហើយត្រូវបានគេអនុវត្ត ដើម្បីសម្រេចបាននូវក្តីសុបិន ចក្ខុវិស័យ នវានុវត្តន៍ និងជាសកម្មភាពនៃការដោះស្រាយបញ្ហា។ ជាងនេះទៅទៀត ការធ្វើផែនការអប់រំ ក៏បានក្លាយជាការចាំបាច់ ដើម្បីផលិតកម្លាំងពលកម្ម ពោលគឺធនធានមនុស្សដែលប្រកបដោយគុណភាពនៅគ្រប់កម្រិត ដើម្បីជំរុញសេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។

## ១.១. សាវតារ

ការអប់រំគឺពិតជាត្រូវបានគេឱ្យតម្លៃទូទាំងពិភពលោកចំពោះសក្តានុពល នៃការអភិវឌ្ឍធនធានមនុស្ស និងចូលរួមលើកកម្ពស់នៃការរីកលូតលាស់របស់សង្គមវប្បធម៌ នយោបាយ និងសេដ្ឋកិច្ច។ ជាការពិតប្រទេសទាំងឡាយណាដែលមានប្រព័ន្ធអប់រំខ្ពស់ គឺជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង និងស្តង់ដានៃការរស់នៅរបស់ប្រជាជនក៏មានលក្ខណៈជឿនលឿនផងដែរ។ នៅពេលដែលសេដ្ឋកិច្ចកាន់តែមានភាពឯករាជ្យទៅលើបច្ចេកវិទ្យា ឧស្សាហកម្ម រួមទាំងវិស័យសេវាកម្មខ្ពស់បន្ថែមទៀតនោះ តម្រូវការមនុស្សដែលមានចំណេះដឹងទូលំទូលាយ ក៏ដូចជាកម្លាំងពលកម្មដែលទទួលបានការបណ្តុះបណ្តាលខ្ពស់ក៏ក្លាយទៅជាធាតុចាំបាច់មួយសម្រាប់តម្រូវការទីផ្សារសេដ្ឋកិច្ច ( Foskett and Nlumby, ២០០៣ : viii )។ លើសពីនេះទៅទៀតនៅទូទាំងពិភពលោក ការអប់រំគឺជាយុទ្ធសាស្ត្រដ៏សំខាន់បំផុត សម្រាប់ការអភិវឌ្ឍ

សង្គមនីមួយៗ ដើម្បីឈានទៅដល់ពិភពលោកមួយមានការផ្លាស់ប្តូរពីភាពអន់ថយ ទៅរកភាពរីកចម្រើន (Aikaman and Unterhalter, ២០០៥)។

នៅក្នុងលក្ខខណ្ឌជាក់លាក់ជាសកល ការអប់រំគឺពិតជាមានឥទ្ធិពលខ្លាំងណាស់ ក្នុងការលុបបំបាត់នូវភាពក្រីក្រ រក្សាបាននូវសុខមាលភាពរបស់ប្រជាពលរដ្ឋខ្ពស់ ព្រមទាំងលើកកម្ពស់នូវលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេស។ មនុស្សដែលទទួលបានការអប់រំ អាចធ្វើការសម្រេចចិត្តប្រកបដោយគតិបណ្ឌិត មានការទទួលខុសត្រូវខ្ពស់ ដែលអាចជះឥទ្ធិពលជាវិជ្ជមានចំពោះគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។ ជាងនេះទៅទៀត ការអប់រំគឺមានការជះឥទ្ធិពលដោយផ្ទាល់ ទៅលើគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍមនុស្ស រួមទាំងសកម្មភាពសេដ្ឋកិច្ច ការផ្តល់អំណាចដល់ស្ត្រី ឬលើកកម្ពស់សិទ្ធិនារី ជំរុញផលិតផលកសិកម្ម ការពារបរិស្ថាន និងសុវត្ថិភាពនៃការចិញ្ចឹមជីវិតនៅក្នុងក្រុមគ្រួសារ។ ដូច្នេះ ការអប់រំគឺត្រូវបានគេកត់សម្គាល់ថាជាទម្រង់មួយនៃការវិនិយោគនូវចំណេះដឹងរបស់មនុស្ស ដែលជាសមិទ្ធផលដ៏មានតម្លៃសម្រាប់សេដ្ឋកិច្ចសង្គម និងវប្បធម៌ (Woodhall, ១៩៩២: ៣)។

ដើម្បីទទួលបាននូវគុណប្រយោជន៍ទាំងនោះពីការអប់រំ តួនាទី និងមុខងាររបស់អ្នកគ្រប់គ្រងអប់រំគឺពិតជាមានសារសំខាន់ខ្លាំងណាស់។ ទន្ទឹមនឹងនេះដែរ យោងតាមលោក Joilu,(២០០៩) នាយកសាលារៀនក៏មានទំនួលខុសត្រូវក្នុងការសហការជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន និងបុគ្គលិកទាំងអស់នៅក្នុងអង្គភាព រួមទាំងសហគមន៍ផងដែរ ចំពោះដំណើរការនៃការរៀបចំផែនការ ការបង្កើតនូវបរិយាកាសល្អប្រកបដោយភាពស្និទ្ធស្នាល និងការលើកទឹកចិត្តចំពោះបុគ្គលិកបង្រៀននៅក្នុងអង្គភាព។ ដូច្នេះ នាយកសាលាត្រូវតែបង្ហាញពីទម្រង់បែបបទ រចនាសម្ព័ន្ធនៃការរៀបចំផែនការ ការរៀបចំរាល់សកម្មភាពផ្សេងៗរួមទាំងធនធាន ការរៀបចំពិគ្រោះប្រឹក្សាយោបល់ នីតិវិធីនៃការទំនាក់ទំនង និងការធ្វើសេចក្តីសម្រេចព្រមទាំងមានតួនាទីគ្រប់គ្រងទៅលើការអនុវត្ត និងការវាយតម្លៃទៅលើផែនការផងដែរ។ គ្រូក៏ត្រូវមានតួនាទីដូចនាយកសាលាផងដែរ រួមទាំងបុគ្គលិកអប់រំនៅក្នុងអង្គភាពទាំងអស់ ក៏គួរតែចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំ និងការអនុវត្តផែនការអប់រំរបស់សាលារៀនដើម្បីបញ្ជាក់ពីបេសកកម្ម ចក្ខុវិស័យ និងគោលបំណងរបស់សាលារៀន ក្នុងទិដ្ឋភាពជាក់ស្តែងនៃស្ថានភាពបច្ចុប្បន្នរបស់សាលារៀន និង

រៀបចំជម្រើសអាទិភាពនៃសកម្មភាពរបស់សាលាដែលត្រូវធ្វើការអភិវឌ្ឍ។ ដំណើរការនៃសកម្មភាពទាំងឡាយ គួរតែត្រូវមានការគ្រោងឡើងដើម្បីមានការយល់ព្រមពីបុគ្គលិកអប់រំនៅក្នុងអង្គភាពទាំងអស់ និងចូលរួមពិភាក្សាក្នុងការសម្រេចចិត្តទៅលើការបង្កើតផែនការ។

តម្លៃនៃការអប់រំកាន់តែមានការរីកលូតលាស់ រួមទាំងតម្រូវការនៃសេវាអប់រំក៏មានការកើនឡើង ដូចនេះតម្រូវការនៃការធ្វើផែនការអប់រំក៏មានការកើនឡើងផងដែរ។ កិច្ចការរដ្ឋបាលមានភាពស្មុគស្មាញ រួមទាំងឧបសគ្គហិរញ្ញវត្ថុនៃប្រព័ន្ធអប់រំទាក់ទងទៅនឹងការផ្តល់សេវាអប់រំ ក៏បានធ្វើឱ្យដំណើរការនៃផែនការកាន់តែមានការលំបាកខ្លាំងឡើងៗ។ ដូច្នេះ អ្នករៀបចំផែនការអប់រំគឺត្រូវស្វែងរកការចូលរួម និងការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក៏ដូចជាអ្នកជំនាញក្នុងការរៀបចំផែនការផងដែរ។ គោលដៅអភិវឌ្ឍសហសវត្សន៍ (MDG) នៅត្រឹមឆ្នាំ២០១៥ កុមារគ្រប់ទីកន្លែង ទាំងកុមារា និងកុមារីដូចគ្នាទាំងអស់នឹងអាចបញ្ចប់ការសិក្សាយ៉ាងហោចណាស់នៅកម្រិតបឋមសិក្សា រួមទាំងលុបបំបាត់វិសមភាពយេនឌ័រនៅកម្រិតបឋមសិក្សានិងអនុវិទ្យាល័យនៅគ្រប់កម្រិតថ្នាក់នៃការអប់រំ។ គោលដៅទាំងនេះគឺពិតជាកិច្ចការដ៏ស្មុគស្មាញ ដែលមិនអាចសម្រេចបានភ្លាមៗនោះឡើយ (UNESCO, ២០០៥:៣)។ ដើម្បីសម្រេចបាននូវគោលដៅទាំងនោះគឺទាមទារឱ្យមានការប្រើប្រាស់ នូវវិធីសាស្ត្រពហុវប្បធម៌ ភាពជាដៃគូរឹងមាំជាមួយរាជរដ្ឋាភិបាលព្រមទាំងការបង្កើត និងការអនុវត្តផែនការអប់រំឱ្យមានភាពប្រក្រតី និងត្រឹមត្រូវច្បាស់លាស់។

ដូច្នេះហើយដើម្បីឱ្យសម្រេចបានគោលដៅអប់រំអន្តរជាតិ ដូចជាគោលដៅអប់រំសហសវត្សន៍ (MDG) គោលដៅអប់រំសម្រាប់ទាំងអស់គ្នា (EFA) នៅក្នុងប្រទេសនីមួយៗ ត្រូវតែធ្វើការឆ្លុះបញ្ចាំង និងកែលម្អគោលដៅអប់រំជាតិរបស់ប្រទេសខ្លួន និងផែនការអប់រំមួយចំនួនទៀតដែលមានកម្រិតទាបនៅឡើយ។ ការឆ្លុះបញ្ចាំងទាំងនេះគឺពិតជាសមាសធាតុសំខាន់ នៃការអភិវឌ្ឍផែនការ និងយុទ្ធសាស្ត្រដ៏ទូលំទូលាយមួយដើម្បីសម្រេចបាននូវគោលដៅនេះផងដែរ Caillods, (២០០៥:២២)។ យោងតាមលោក Collins (១៩៩៦) បានសរសេរថាផែនការអភិវឌ្ឍន៍សាលារៀន គឺត្រូវមានការចូលរួម និងការទទួលខុសត្រូវដោយសហគមន៍របស់សាលារៀន ដើម្បីជួយផ្តល់នូវទិសដៅចំពោះការងារសាលា ដែលត្រូវអនុវត្តក្នុងគោលបំណងជានាថា សិស្សានុសិស្សទាំងអស់ទទួលបានការអប់រំប្រកបដោយគុណភាព ក្នុងលក្ខខណ្ឌ

ទាំងការអភិវឌ្ឍ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការសិក្សា។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាក់ស្តែងដូចជាប្រទេសកម្ពុជាជាដើម ការអប់រំត្រូវបានគេរំពឹងថានឹងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសទាំងមូល។ ដើម្បីសម្រេចបាននូវក្តីរំពឹងនេះ ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងរៀបចំផែនការដោយមានការយកចិត្តទុកដាក់ខ្ពស់ទៅលើការអប់រំដោយមានជំនឿជាក់យ៉ាងមុតមាំថា ការអភិវឌ្ឍរយៈពេលវែងរបស់ប្រទេសនេះ គឺត្រូវពឹងផ្អែកទៅលើការពង្រីក និងការផ្តល់ឱ្យដល់វិស័យអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព និងសមធម៌ សម្រាប់ទាំងអស់គ្នា។

លើសពីនេះទៅទៀតដំណើរការវិមជ្ឈការនៃភារកិច្ច និងតួនាទីគ្រប់គ្រងកំពុងត្រូវបានផ្លាស់ប្តូរកាន់តែខ្លាំងឡើងៗ ពីរដ្ឋបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់សាលារៀន ដែលត្រូវទទួលខុសត្រូវដោយផ្ទាល់សម្រាប់ការគ្រប់គ្រងស្ថាប័ន និងអង្គភាពអប់រំដែលត្រូវផ្តល់សេវាសាធារណៈ។ ដូច្នេះ ការអនុវត្តផែនការអប់រំគឺត្រូវតែមានការរៀបចំដោយមានការផ្លាស់ប្តូរ ពីផែនការថ្នាក់ជាតិ ទៅផែនការថ្នាក់ក្រោមជាតិ ឬថ្នាក់មូលដ្ឋាន ស្របទៅនឹងបរិបទតាមតំបន់ ធ្វើយ៉ាងណាដើម្បីធានាថាតំបន់ផ្សេងៗទៀតដែលមានកម្រិតអប់រំទាបត្រូវតែធ្វើការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនដោយខ្លួនឯងផ្ទាល់ ហើយការរៀបចំនោះត្រូវអនុវត្តទៅតាមវត្ថុបំណង និងគោលបំណងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក៏ដូចជាគោលដៅអប់រំជាតិ ពិសេសគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា និងការអប់រំបច្ចេកទេសជាដើម ដោយមានការប្តេជ្ញាចិត្តថា អាចនឹងទទួលបានជោគជ័យនាពេលអនាគត តាមរយៈលទ្ធផលសិក្សារបស់សិស្សមានការកើនឡើងជាបន្តបន្ទាប់តាមអង្គភាពនីមួយៗ (គោលនយោបាយស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ ឆ្នាំ ២០១៦)។

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល គឺកសាងសង្គមកម្ពុជាមួយទៅជាសង្គមពុទ្ធិ និងវិបុលភាព ដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារបរិស្ថាន ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិ ការគោរពគោលការណ៍លទ្ធិ

ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស អប់រំមនុស្សឱ្យមានចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះមានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិ ទាំងក្នុងសង្គមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ។

កម្ពុជាសង្ឃឹមថានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ការពង្រឹងគុណភាពសេវាអប់រំ គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាគន្លឹះចាំបាច់នៃការចូលរួមក្នុងកំណើនសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍធនធានមនុស្ស មូលធនសង្គម និងមូលធនបញ្ញា។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រថវិកា និងជំរុញឱ្យសាលារៀន ធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងគោលដៅធ្វើឱ្យសម្រេចបាន នូវគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងចាប់តាំងពីឆ្នាំ២០១២មកម្ល៉េះ ប៉ុន្តែការរៀបចំនេះមានតែនៅក្រសួងអប់រំ យុវជន និងកីឡា។ បន្ទាប់មកដល់ឆ្នាំ២០១៣ មានសេចក្តីណែនាំឱ្យមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្តរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។ លុះមកដល់ឆ្នាំ២០១៨ក៏មានសេចក្តីណែនាំបន្ថែមទៀតដល់ថ្នាក់សាលារៀន ឱ្យរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។

ផែនការប្រតិបត្តិប្រចាំឆ្នាំគឺជាការប្រែក្លាយគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលមធ្យមដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យទៅជាសកម្មភាព និងចំណុចដៅប្រចាំឆ្នាំដោយបញ្ជាក់ពីប្រភពថវិកាទាំងអស់ដែលអង្គភាពនីមួយៗមាន ដើម្បីអនុវត្តសកម្មភាពក្នុងមួយឆ្នាំ (ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣)។

ការអភិវឌ្ឍសាលារៀនមួយប្រកបដោយនិរន្តរភាព ទាមទារឱ្យអ្នកដឹកនាំ និងគ្រប់គ្រងមានបំណិនក្នុងការកៀរគរធនធានពីគ្រប់មជ្ឈដ្ឋាន បង្កើតឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធដូចជាៈ សិស្សានុសិស្ស គ្រូបង្រៀន មាតាបិតាអាណាព្យាបាលសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន អាជ្ញាធរដែនដី

និងអ្នកពាក់ព័ន្ធជាច្រើនទៀតនៅមូលដ្ឋានក្នុងការអនុវត្តសកម្មភាព ដោយត្រូវធ្វើស្វ័យវាយតម្លៃសាលារៀនដើម្បីឱ្យដឹងពីចំណុចខ្លាំង ចំណុចខ្វះខាត បញ្ហាប្រឈម និងអ្វីដែលត្រូវកែលម្អ រួចធ្វើផែនការអភិវឌ្ឍសាលារៀនដោយផ្អែកលើចំណុចកែលម្អ និងធ្វើការពិនិត្យតាមដានវាយតម្លៃសាលារៀន ក្នុងឆ្នាំសិក្សានីមួយៗ (ក្រសួងអប់រំ យុវជន និងកីឡា ឯកសារណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនឆ្នាំ ២០១៧)។ ដំណើរការរៀបចំផែនការអភិវឌ្ឍន៍សាលារៀននឹងមិនមានលក្ខណៈល្អប្រសើរ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀនបានទេ បើខ្វះការចូលរួមពីភាគីពាក់ព័ន្ធនានា។ ការចូលរួម និងកិច្ចសហការទាំងនោះវាមានសារសំខាន់ខ្លាំងណាស់ ក្នុងការប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយដើម្បីធ្វើការវិភាគ និងរៀបចំផែនការមួយប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានចេញប្រកាសស្តីពីការកំណត់គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់លើកទឹកចិត្ត ក្នុងសន្និបាតអប់រំទៀតផង ដោយកំណត់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃលើការរៀបចំផែនការ និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដែលជាសូចនាករសំខាន់មួយក្នុងចំណោមសូចនាករដទៃទៀត ក្នុងការវាយតម្លៃនាយក នាយិកាសាលារៀនល្អ (ក្រសួងអយកប្រកាសលេខ ៧៦១ ឆ្នាំ ២០១៦)និងចេញអនុក្រឹត្យស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាលដោយកំណត់លើការបើកទូលាយ ឱ្យមានការចូលរួមរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ជា លក្ខណៈវិនិច្ឆ័យសំខាន់មួយ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់ដែលបញ្ជាក់ពីស្តង់ដាគំរូរបស់សាលារៀនល្អ(រាជរដ្ឋាភិបាល អនុក្រឹត្យលេខ ៥៤ ឆ្នាំ២០១៨)។

ដំណើរការនៃការរៀបចំផែនការកើតឡើងស្របគ្នា ជាមួយនឹងបរិបទសង្គមដែលមានស្រាប់ អ្នកគ្រប់គ្រងអប់រំត្រូវតែធ្វើការអភិវឌ្ឍនូវការយល់ដឹងពីបរិបទឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយដើម្បីកំណត់បានពីបេសកកម្ម ចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍនៅក្នុងអង្គភាព គោលដៅនិងផែនការប្រតិបត្តិរបស់ខ្លួន។ ដូច្នេះ អ្នកគ្រប់គ្រងអប់រំគ្រប់រូប ត្រូវតែយល់ដឹងអំពីបរិបទសង្គមដែលផ្តល់នូវក្របខ័ណ្ឌ សម្រាប់ការរៀបចំផែនការ ជាមួយនឹងការខិតខំប្រឹងប្រែងរៀបចំផែនការរបស់ខ្លួន

(Griffin, ១៩៩៩ : ២០១)។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សា និងការគ្រប់គ្រងមានលក្ខណៈផ្សេងគ្នា។ ការរៀបចំ និងការអនុវត្តផែនការអប់រំគឺជាធាតុសំខាន់ ដើម្បីសម្រេចបាននូវគោលដៅនៃប្រទេសមួយ។ វាអាចមានលក្ខណៈគម្លាតគ្នា ឬខុសគ្នារវាងអ្វីដែលបានសរសេរនៅលើក្រដាស និងអ្វីដែលបានសរសេរនៅលើដី។ ចន្លោះប្រហោងដ៏ធំមួយទាក់ទងទៅលើការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន គឺការទទួលខុសត្រូវចំពោះអង្គភាពដែលមិនទាន់មានការសហការបែងចែកការងារត្រឹមត្រូវ ខ្វះជំនាញលើការរៀបចំ និងការអនុវត្តផែនការ។ បញ្ហានៃការយល់ដឹងពីការវិភាគហេតុវិនិច្ឆ័យវិស័យអប់រំ រួមទាំងការកំណត់ពីស្ថានភាពនៃការវិភាគ SWOT នៅក្នុងអង្គភាព និងបញ្ហានៃការចូលរួមរបស់សហគមន៍ទៅលើការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនគឺជាចំណុចខ្វះខាតដែលអ្នកសិក្សាត្រូវធ្វើការសិក្សាស្រាវជ្រាវ។

យោងតាមបញ្ហាខាងលើនេះ ចេតនាសំខាន់របស់អ្នកសិក្សាស្រាវជ្រាវ គឺមានគោលបំណងធ្វើការសិក្សាពីស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន នៅក្នុងខេត្តស្វាយរៀងដោយផ្តោតទៅលើដំណើរការនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ យុទ្ធសាស្ត្រ និងលទ្ធផលនៃការអនុវត្តផែនការ ស្ថានភាពនៃចំណេះដឹងរបស់អ្នកធ្វើផែនការ ការបង្កលក្ខណៈដល់ភាគីពាក់ព័ន្ធទាំងឡាយចូលរួមធ្វើផែនការ និងយន្តការនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃទៅលើការអនុវត្ត និងការរៀបចំផែនការអប់រំ ជាពិសេសទាក់ទងទៅនឹងតម្រូវការក្នុងការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងផែនការអប់រំ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ផែនការគឺជាផ្នែកមួយដែលមិនអាចខ្វះបាននៃដំណើរការអភិបាលកិច្ច ហើយក្នុងករណីដែលគ្មានប្រព័ន្ធផែនការនោះទេ គឺប្រៀបដូចជាការបាត់បង់នូវមូលដ្ឋានគ្រឹះដ៏សំខាន់របស់ស្ថាប័ន ឬអង្គភាពនោះផងដែរ។ ការធ្វើផែនការប្រៀបដូចជាការរៀបចំផ្លូវត្រូវដើរ និងបញ្ជាក់ពីគម្រោងដែលបានមើលឃើញជាមុន ក្នុងការបង្កើត និងការអនុវត្តកម្មវិធីគោលនយោបាយ។ ជាការពិតណាស់អ្នកគ្រប់គ្រងនៅក្នុងអង្គភាពមួយគួរតែជាបុគ្គលសកម្ម និងបង្កើតឱ្យចេញជាលទ្ធផលល្អប្រសើរជាងការរង់ចាំតែមើលបំណាំ និងរិះ

គន់។ អ្នកគ្រប់គ្រងត្រូវមានបំណិនធ្វើការវាយតម្លៃពីអ្វីមួយ នៅពេលណា នៅកន្លែងណា ដោយរបៀបណា ចំនួនប៉ុន្មាន និងចំណាយអស់ប៉ុន្មាន ដែលពួកគេត្រូវធ្វើការអនុវត្តដោយយោងទៅតាមចក្ខុវិស័យ វត្ថុបំណង និងគោលដៅដែលខ្លួនបានគ្រោងទុក និងស្របជាមួយផែនការយុទ្ធសាស្ត្រ និងគោលនយោបាយអប់រំជាតិ។ ការធ្វើផែនការជួយឱ្យអ្នកគ្រប់គ្រងពិចារណាបានម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយនូវស្ថានភាពបច្ចុប្បន្នរបស់អង្គភាព រួមទាំងជួយបង្កបរិយាកាសអំណោយផលចំពោះការប្រតិបត្តិការងារ។ ក្រៅពីនេះយោងតាមលោកAdams (២០០៦) គាត់សម្គាល់ថា ការធ្វើផែនការគឺជាសកម្មភាពដែលមានការចូលរួមស្ទើរតែគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដូចជាការចូលរួមជាលក្ខណៈបុគ្គល អង្គភាព សហគមន៍ និងជាតិសាសន៍ទាំងមូល។ ដូច្នេះ ការរៀបចំផែនការអប់រំ រួមចំណែកដល់ដំណើរការផែនការបង្កើតគោលនយោបាយតាមរយៈការកំណត់នៅតាមតំបន់ផ្សេងៗនិងជម្រើសនៃគោលនយោបាយផ្សេងៗ ដែលអាចធ្វើការដោះស្រាយនូវបញ្ហាប្រឈមដែលកើតមានឡើង។ ដូចនេះសេចក្តីសម្រេចផ្ទេរការធ្វើផែនការអប់រំជាប្រព័ន្ធ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដោយការផ្តល់ឱ្យនូវសិទ្ធិអំណាចរដ្ឋបាល និងទំនួលខុសត្រូវគឺពិតជាមានភាពចាំបាច់មួយ តែវាក៏ជាក្តីកង្វល់របស់រាជរដ្ឋាភិបាលផងដែរ ដើម្បីយល់ដឹងថា តើវត្ថុបំណង និងគោលដៅនៃការអប់រំរបស់ពួកគេ និងអនុវត្តបានយ៉ាងដូចម្តេច ហើយស្របទៅនឹងអ្វីដែលជាទិសដៅរបស់រាជរដ្ឋាភិបាលឬអត់?

ជាការពិតណាស់ តាមលោក Forojalla (១៩៩៣) បានកត់សម្គាល់ថា ការដែលមិនមានប្រព័ន្ធផែនការអប់រំច្បាស់លាស់ សមត្ថភាពនៃការរៀបចំ និងការអនុវត្តផែនការរបស់អង្គភាពនៅមានកម្រិត រួមទាំងភាពដែលមិនស៊ីសង្វាក់គ្នារវាងការធ្វើផែនការ និងការអនុវត្តផែនការក៏បានក្លាយទៅជាឧបសគ្គដ៏ធំនឹងកើតមានជាញឹកញាប់បំផុត។ បញ្ហានេះ អាចបណ្តាលមកពីការសិក្សាស្រាវជ្រាវពីតម្រូវការដែលធ្លាប់បានជួបប្រទះមិនទាន់គ្រប់គ្រាន់ ដើម្បីរៀបចំផែនការឱ្យបានច្បាស់លាស់ និងការអនុវត្តផែនការឱ្យបានត្រឹមត្រូវជាក់ស្តែង។ ក្នុងចំណោមឧបសគ្គទាំងនេះ គឺបណ្តាលមកពីកង្វះធនធានគ្រប់គ្រាន់ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងអប់រំ វិធីសាស្ត្រនៃការចូលរួមត្រឹមត្រូវ កង្វះភាពឯករាជ្យម្ចាស់ការ និងបញ្ហាកើតឡើងជាប្រព័ន្ធដែលពិបាកក្នុងការសម្រេចចិត្ត។ ប្រព័ន្ធព័ត៌មាន និងទំនាក់ទំនងនៅក្នុងផែនការ

និងសកម្មភាពនៃការអនុវត្តផែនការអប់រំ ក៏ត្រូវបានគេចាត់ទុកថាជាបញ្ហាចម្បងផងដែរ (Adams ២០០៦)។ ការរៀបចំ និងការអនុវត្តផែនការអប់រំ គួរតែត្រូវបានគេយកចិត្តទុកដាក់ជាប្រចាំនៅគ្រប់កម្រិតនៃគោលនយោបាយ និងការសម្រេចចិត្ត។ ក្នុងន័យនេះ ឋានានុក្រមនៃអង្គភាពរដ្ឋបាលទទួលបន្ទុកការអនុវត្តផែនការគឺត្រូវកំណត់ឱ្យបានច្បាស់ពីផែនការ និងដែនកំណត់នៃសិទ្ធិអំណាច និងការទទួលខុសត្រូវដែលបានផ្តល់ទៅឱ្យថ្នាក់មូលដ្ឋាន គឺជាសមិទ្ធផលដែលមានសារសំខាន់បំផុត។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងប្រទេសភាគច្រើនការរៀបចំផែនការអភិវឌ្ឍសាលារៀន និងការចូលរួមអនុវត្តផែនការនៅមានឧបសគ្គជាច្រើនដូចជា៖ សមត្ថភាពនៃការរៀបចំផែនការរបស់ប្រធានអង្គភាពនៅមានកម្រិត ព្រមទាំងប្រព័ន្ធទំនាក់ទំនងនៅមានភាពទន់ខ្សោយ និងយន្តការនៃការសម្របសម្រួល ស្ថិតនៅកម្រិតទាបនៅ ឡើយ។ បញ្ហានេះ មានន័យថាកង្វះខាតនូវបុគ្គលិកលក្ខណៈ ហិរញ្ញវត្ថុ សម្ភារ និងប្រព័ន្ធព័ត៌មានគ្រប់គ្រាន់ ដែលត្រូវបានកំណត់ថាជាឧបសគ្គនៃការអនុវត្តផែនការបន្ថែមទៀត ដែលជាសកម្មភាពនៃការអនុវត្តផែនការរបស់អង្គភាពសាលារៀនចាំបាច់ត្រូវតែដោស្រាយ(Hussien,២០០២)។

ដើម្បីសម្រេចបាននូវគោលដៅសកល ឬគោលដៅអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការនៃការអប់រំសម្រាប់ទាំងអស់គ្នា (EFA) និងគោលដៅអប់រំសហស្សវត្សន៍ (MDG) នៅកម្រិតថ្នាក់ជាតិ រួមទាំងអនុវត្តនូវប្រព័ន្ធវិមជ្ឈការនៃការគ្រប់គ្រងអប់រំ។ ដោយសារចំណុចនេះធ្វើឱ្យតួនាទីនិងមុខងារនៃការគ្រប់គ្រងអប់រំកាន់តែមានការផ្លាស់ប្តូរខ្លាំងឡើងៗ ដោយសារការផ្ទេរភារកិច្ចពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិរួមមានថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់សាលារៀន។ បទពិសោធន៍ទាំងនោះនាំមកនូវបញ្ហាប្រឈមជាច្រើនដែលកំពុងបន្តកើតមានចំពោះប្រព័ន្ធអប់រំនៅក្នុងតំបន់ដូចជា៖ បញ្ហាសមធម៌ គុណភាព សមត្ថភាពអង្គភាព បែបបទក្នុងការអនុវត្ត ការចូលរួមរបស់សហគមន៍ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥)។ លើសពីនេះទៅទៀត ការអនុវត្តផែនការនៅកម្រិតសាលារៀន ដែលបានលើកឡើងធ្វើជាគំរូនេះ នៅមិនទាន់បានអនុវត្តផែនការជាក់ស្តែងនៅឡើយទេ ក្នុងន័យនេះនិន្នាការនៅតាមសាលាដែលបានជ្រើសរើសភាគច្រើនដែលអ្នកធ្វើការសិក្សាស្រាវជ្រាវបានកំណត់នោះគឺទើបតែចាប់ផ្តើមរៀបចំផែនការអភិវឌ្ឍន៍សាលារៀនរបស់ខ្លួន។ ដូច្នេះហើយនាយក

សាលាមិនបានបង្កើតបរិយាកាសល្អសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមនៅក្នុងអំឡុងពេលដំណើរការនៃការរៀបចំ និងការអនុវត្តផែនការនោះ ជាហេតុធ្វើឱ្យអ្នកចូលរួមមានភាពស្ទាក់ស្ទើរនៅក្នុងការសហការ ជាពិសេសសហគមន៍ និងដៃគូអភិវឌ្ឍន៍។

លោក Hopkins,(២០០៥) បានកត់សម្គាល់ថា គុណភាព ប្រសិទ្ធភាពរបស់គ្រូបង្រៀន និងនាយកសាលា គឺត្រូវមានចំណេះដឹង និងជំនាញក្នុងការរៀបចំ និងការអនុវត្តផែនការសាលារៀនធ្វើ ដូច្នេះធ្វើឱ្យពួកគាត់មានចំណាប់អារម្មណ៍ក្នុងការបង្កើតទំនាក់ទំនង ផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន និងយល់ដឹងពីតម្លៃនៃការចូលរួមរបស់សមាគមន៍ ទាំងការចូលរួមផ្លូវការ និងមិនផ្លូវការ និងចេះមានការលើកទឹកចិត្តចំពោះការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ដើម្បីបញ្ជាក់នូវចំណុចខាងលើនេះ Harns et al (១៩៩៨) បានលើកឡើងថាការចង្អុលបង្ហាញពីប្រសិទ្ធភាពរបស់ផែនការសាលារៀន គឺដើម្បីបង្កើននូវលទ្ធផលសិក្សារបស់សិស្ស។ អ្នកគ្រប់គ្រងសាលារៀនក៏ត្រូវតែមានចំណេះដឹង និងការយល់ដឹងអំពីការរៀបចំ និងការអនុវត្តផែនការសាលារៀនផងដែរ។

ជាការពិតណាស់រដ្ឋបាលសាលាដែលស្ថិតនៅក្រោមការសិក្សាស្រាវជ្រាវនេះ ពុំមានការកំណត់ច្បាស់លាស់ពីគោលដៅ និងចក្ខុវិស័យក្នុងការបំពេញការងារ ក៏ដូចជាជំរុញឱ្យមានការប្តេជ្ញាចិត្ត និងការពេញចិត្ត ចំពោះការបំពេញការងាររបស់ខ្លួននៅឡើយទេ។ ដោយសារតែមានការសង្កេតជាក់ស្តែងទៅលើការអនុវត្តយ៉ាងសកម្មទើបអ្នកសិក្សាស្រាវជ្រាវរៀបចំបាននូវនិក្ខេបបទនេះ។

ទោះបីជាការពិតដែលថាការអនុវត្តនៅមានកម្រិតទាប ចំពោះការរៀបចំ និងការអនុវត្តផែនការនៅថ្នាក់សាលារៀនក៏ដោយអ្នកសិក្សាស្រាវជ្រាវយល់ឃើញថា សាលារៀនដែលបានជ្រើសរើសនៅក្នុងការអនុវត្តផែនការភាគច្រើនពុំទាន់មានប្រសិទ្ធភាព និងភាពស័ក្តសិទ្ធិនៅឡើយចំពោះការប្រៀបធៀបជាមួយនឹងបេក្ខជនដែលបានចុះកម្មសិក្សា និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំចំពោះសាលារៀនផ្សេងៗទៀតដែលបានចុះធ្វើការស្រាវជ្រាវ។ ដោយសារតែអ្នកស្រាវជ្រាវបង្ហាញខ្លួនក្នុងនាមជាគ្រូបង្រៀន រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សាលារៀនបានផ្តល់ឱកាសឱ្យអ្នកសិក្សាស្រាវជ្រាវ សង្កេតមើលពីស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ។ ពុំធ្លាប់មាននរណាម្នាក់ធ្វើការសិក្សាស្រាវជ្រាវស្រដៀង

គ្នាជុំវិញប្រធានបទនេះ ក៏ដូចជាវិទ្យាល័យនៅក្នុងខេត្តនេះនោះទេ។

ដូច្នេះហើយដើម្បីបញ្ចប់នូវបញ្ហាខាងលើនេះ បន្ទាប់ពីការស៊ើបអង្កេតយ៉ាងម៉ត់ចត់ចំពោះព័ត៌មានដែលពាក់ព័ន្ធ ឬក៏ទាក់ទងទៅនឹងការរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននៅក្នុងខេត្តស្វាយរៀងរួចមក អ្នកសិក្សាស្រាវជ្រាវបានបង្កើតនូវសំណួរស្រាវជ្រាវជាមូលដ្ឋាននៅក្នុងចំណុច ១.៤ ខាងក្រោម។ គោលបំណងនៃផែនការអភិវឌ្ឍសាលារៀនគឺធ្វើឱ្យមានការផ្លាស់ប្តូរ និងការច្នៃប្រឌិតសម្រាប់ការកែលម្អសាលារៀន ដែលវាជាដំណើរការផែនការដ៏វែងឆ្ងាយមួយ។ ក្នុងន័យនេះ ការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន ត្រូវធ្វើជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ ហើយមានគោលបំណងច្បាស់លាស់។ យោងតាមលោក Bell (ឆ្នាំ១៩៩៨) គោលបំណងនៃការរៀបចំផែនការអភិវឌ្ឍន៍គឺដើម្បីជួយដល់សាលារៀនក្នុងការផ្លាស់ប្តូរប្រកបដោយភាពជោគជ័យនូវគុណភាពនៃការបង្រៀននិងស្តង់ដានៃការសិក្សាត្រូវបានធ្វើឱ្យប្រសើរឡើង។ ចំណែកឯលោក Jones (ឆ្នាំ ១៩៩៨) ចាត់ទុកការធ្វើផែនការសាលារៀនជាវិធីសាស្ត្រមួយ ដែលត្រូវបានគេអនុម័តយ៉ាងទូលំទូលាយ ក្នុងការគ្រប់គ្រងការផ្លាស់ប្តូរដែលបានគ្រោងទុកនិងត្រូវបានគាំទ្រជាយន្តការសម្របសម្រួលមួយ ដើម្បីជួយដល់ការអនុវត្តនវានុវត្តន៍ជាច្រើន ដែលមាននៅក្នុងប្រព័ន្ធអប់រំ។ ដំណើរការកសាងផែនការអភិវឌ្ឍន៍ត្រូវការការយល់ដឹងជ្រៅជ្រះអំពីអ្វីដែលជាគោលបំណងរបស់វា និងរបៀបដែលវាត្រូវធ្វើដើម្បីសម្រេចបានផែនការដ៏ល្អមួយ។ ជាទូទៅយើងសង្កេតឃើញថា សាលារៀនជាច្រើនមិនទាន់ធ្វើការកែលម្អ និងអភិវឌ្ឍន៍ឱ្យបានល្អប្រសើរស្របតាមស្តង់ដាសាលារៀនសតវត្សទី២១ នៅឡើយ ដោយសារកង្វះធនធាន ទាំងធនធានថវិកាសម្ភារ និងធនធានមនុស្ស ពិសេសកម្រិតយល់ដឹងទូលំទូលាយនៃការរៀបចំផែនការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ ដោយសង្កេតឃើញនូវបញ្ហានានាជាច្រើនទាក់ទងនឹងដំណើរការនៃការរៀបចំផែនការសាលារៀន ទើបមានការលើកយកប្រធានបទស្រាវជ្រាវមួយមកសិក្សាគឺ“**ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន**”។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗដូចខាងក្រោម៖

១) កំណត់ពីស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

២) កំណត់ពីតម្រូវការបណ្តុះបណ្តាលលើជំនាញរៀបចំផែនការនៅកម្រិតសាលារៀន

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងស្រាវជ្រាវទាំងពីរខាងលើនេះសំណួរស្រាវជ្រាវត្រូវបានចោទសួរដូចខាងក្រោម៖

១) តើស្ថានភាពបច្ចុប្បន្នក្នុងការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនមានលក្ខណៈបែបណា?

២) តើមានតម្រូវការបណ្តុះបណ្តាលអ្វីខ្លះសម្រាប់អ្នករៀបចំ និងអ្នកអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សានេះគឺផ្តោតទៅលើ ស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននៅក្នុងខេត្តស្វាយរៀង ដូច្នេះ ការសិក្សានេះ មានសារៈសំខាន់ដូចខាងក្រោម៖

- ជួយឱ្យអ្នកអាន យល់ច្បាស់ពីការអនុវត្ត និងបញ្ហានៃការធ្វើផែនការអប់រំនៅក្នុងសាលារៀន ក្រោមការដឹកនាំ រៀបចំ និងអនុវត្តដោយគណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ មន្ត្រីគ្រប់គ្រងអប់រំ និងសហគមន៍។
- ជួយឱ្យយើងធ្វើការសង្កេតពីគម្លាត ឬក៏ភាពខុសគ្នារវាងអ្វីដែលយើងបានសិក្សា និងស្ថានភាពដែលបានកើតឡើងពិត នៅក្នុងការរៀបចំ និងការអនុវត្តផែនការអប់រំនៅតាមសាលារៀន។
- ផ្តល់នូវធាតុចូលដ៏ល្អមួយសម្រាប់ ជួយដោះស្រាយនូវបញ្ហាគោលនយោបាយ ក្នុងការបង្កើតយុទ្ធសាស្ត្រលើផែនការអប់រំ និងការអនុវត្តផែនការនៅកម្រិតសាលារៀន។

- ជាឧបករណ៍ជំនួយមួយសម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្ថែម ទៅលើស្ថានភាពរបស់សាលារៀននៅក្នុងតំបន់នោះផងដែរ។
- ចូលរួមដោះស្រាយបញ្ហាដែលកើតមាន ព្រមទាំងលើកកម្ពស់នូវការរៀបចំ និងការអនុវត្តផែនការអប់រំកម្រិតសាលារៀនឱ្យមានការរីកចម្រើន។
- ជួយឱ្យសាលារៀនកែសម្រួលផែនការប្រតិបត្តិប្រចាំឆ្នាំឱ្យកាន់តែល្អប្រសើរប្រកបដោយសុខដុមនីកម្មស្របតាមបរិបទនៃកំណែទម្រង់វិស័យអប់រំ។
- រួមចំណែកធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍជាតិ។
- ទុកជាឯកសារសម្រាប់គ្រប់មជ្ឈដ្ឋានអ្នកសិក្សា ពិសេសសម្រាប់និស្សិត ប្រធានអង្គភាព និងអ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត។

## ១.៦. ដែនកំណត់ និងវិសាលភាព

ការសិក្សាស្រាវជ្រាវលើប្រធានបទ “ **ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន**” ធ្វើឡើងផ្តោតលើស្រុក/ក្រុងទាំង ៨ ដោយជ្រើសរើសវិទ្យាល័យចំនួន៨ ក្នុងចំណោមវិទ្យាល័យសរុបទាំង២០នៅក្នុងខេត្តស្វាយរៀងរួមមាន៖ ស្រុករំដួល រមាសហែក ស្វាយទាប ស្វាយជ្រុំ ចន្ទ្រា កំពង់រោទិ៍ ក្រុងស្វាយរៀង និងក្រុងបាវិត ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីដំណើរការនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន។ សាលាចំនួន ៨នេះអាចមិនមែនជាតំណាងឱ្យសាលាទាំងអស់នៅក្នុងខេត្តស្វាយរៀងនោះទេ។ ខ្លឹមសារប្រធានបទផ្តោតលើកម្រិតនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនដោយផ្តោតលើ៣ចំណុច៖ ស្ថានភាពនៃការរៀបចំផែនការសកម្មភាពក្នុងការអនុវត្តផែនការ និងតម្រូវការបណ្តុះបណ្តាលពាក់ព័ន្ធទៅនឹងការរៀបចំនិងការអនុវត្តផែនការអប់រំនៅកម្រិតសាលារៀន។ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានគុណប្រយោជន៍ អាចជឿទុកចិត្តបាន និងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកនាយក នាយិកាសាលា

គណនេយ្យ ប្រធានក្រុមបច្ចេកទេស រួមទាំងលោកគ្រូ អ្នកគ្រូនៅក្នុងសាលាទាំង៨ នៅគ្រប់កម្រិតថ្នាក់ មកធ្វើជាសំណាកក្នុងការសិក្សាស្រាវជ្រាវ។ ដូច្នេះលទ្ធផលនៃការស្រាវជ្រាវនេះ អាចមិនតំណាងឱ្យទូទាំងខេត្ត។ ម្យ៉ាងវិញទៀត ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានធ្វើការជ្រើសរើសនាយក នាយិកា គណនេយ្យ ប្រធានក្រុមបច្ចេកទេស និងលោកគ្រូអ្នកគ្រូទាំងអស់ ដើម្បីឱ្យបំពេញកម្រងសំណួរដូចគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវ ក៏អាចមិនមែនជាតំណាងនៅទូទាំងខេត្ត បើទោះបីអ្នកសិក្សាស្រាវជ្រាវព្យាយាមជ្រើសរើសសំណាកទាំងនោះធ្វើជាតំណាងក៏ដោយ។

### ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកធំៗមានដូចខាងក្រោម៖

**ជំពូកទី១ ៖ សេចក្តីផ្តើម** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានលើកឡើងពីសេចក្តីផ្តើម សាវតារ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ព្រមទាំងដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវលើប្រធានបទ"**ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងខេត្តស្វាយរៀង**"

**ជំពូកទី២ ៖ រំលឹកទ្រឹស្តី** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលយកនូវទ្រឹស្តីចាស់ៗពាក់ព័ន្ធនឹងប្រធានបទ និងពីអ្នកសិក្សាស្រាវជ្រាវមុនៗតាមរយៈសៀវភៅ កម្រងអត្ថបទស្រាវជ្រាវជាតិ និងអន្តរជាតិ លិខិតបទដ្ឋានគតិយុត្ត សេចក្តីប្រកាស សារាចរណែនាំ និងឯកសារពាក់ព័ន្ធនានារបស់ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីធ្វើជាគំនិត និងជាទុន សម្រាប់ការស្រាវជ្រាវ និងការបង្កើតជាស្នាដៃថ្មី។

**ជំពូកទី៣ ៖ វិធីសាស្ត្រនៃការស្រាវជ្រាវ** ក្នុងជំពូកនេះ អ្នកស្រាវជ្រាវបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសសំណាក និងប្រភេទសំណាកព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យតាមរយៈកម្មវិធី Microsoft Excel និងWordសម្រាប់សង់ក្រាហ្វិក និងផ្គុំទិន្នន័យបញ្ចូលគ្នា។

**ជំពូកទី៤ ៖ លទ្ធផលនៃការស្រាវជ្រាវ** ក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានយកទិន្នន័យដែលប្រមូលបានមកធ្វើការវិភាគ និងធ្វើការបកស្រាយឱ្យបានក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវកែលម្អនៅក្នុងបរិបទជាក់ស្ដែងនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងខេត្តស្វាយរៀង។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ជាផ្នែកមួយដ៏សំខាន់ ដែលអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការថ្លឹងថ្លែងមុននឹងធ្វើការសន្និដ្ឋានទៅលើចំណុចរួមទាំងអស់ដែលបានវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួន ដល់ក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន អ្នកសិក្សាស្រាវជ្រាវក្រោយៗ និងភាគីពាក់ព័ន្ធក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍ និងធ្វើឱ្យស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងខេត្តស្វាយរៀងកាន់តែមានគុណភាព ប្រសិទ្ធភាព និងឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. ប្រវត្តិនៃការរៀបចំផែនការ

ការរៀបចំផែនការ គឺមិនមែនជារឿងថ្មីទេ ហើយក៏មិនមែនពិសេសជាងគេដែរ។ មនុស្សបានរៀបចំផែនការក្នុងរបៀបមួយ ឬច្រើនចាប់តាំងពីការគិតកើតមានឡើងមកម្ល៉េះ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលមាននៅក្នុងវិធីរៀបចំសកម្មភាពផ្លូវការមួយ ដើម្បីឈានទៅរកការអភិវឌ្ឍនៅក្នុងសង្គមសាំញ៉ាំមួយ ការរៀបចំផែនការ គឺជាភាពច្នៃប្រឌិតនៃសតវត្សទី២០។ ការបង្កើតផែនការអភិវឌ្ឍន៍សម្រាប់ណែនាំ គឺជាឆ្អឹងខ្នងរបស់ប្រទេសសង្គមនិយម ចាប់តាំងពីការធ្វើបដិវត្តិកុំម្មុយនីសនៅឆ្នាំ១៩១៧ ជាដំបូងនៅសហភាពសូវៀត បន្ទាប់មកនៅប្រទេសយូហ្គោស្លាវី ប្រទេសអាល់បានី ប្រទេសចិន ប្រទេសវៀតណាម ប្រទេសឡាវ ប្រទេសគូបា។ល។ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរភ្លាម ប្រទេសដែលមិនមែនជាប្រទេសសង្គមនិយមជាច្រើន នៅទ្វីបអឺរ៉ុបខាងលិច ដូចជាប្រទេសបារាំង ប្រទេសហូឡង់ និងទ្វីបអាស៊ីដូចជា ប្រទេសជប៉ុនជាដើម បានអនុម័តយកទស្សនៈនៃការធ្វើផែនការបែបចង្អុលបង្ហាញ ដោយចាត់ទុកថាជាការរស់រានឡើងវិញ បន្ទាប់ពីសង្គ្រាម និងដើម្បីបង្ហាញពីដំណើរការអភិវឌ្ឍបន្ទាប់ពីសង្គ្រាម។ ផ្ទុយទៅនឹងការធ្វើផែនការបែបចង្អុលបង្ហាញរបស់ប្រទេសសង្គមនិយម ការធ្វើផែនការបែបចង្អុលបង្ហាញនេះទទួលយកគំនិតស្តីពីសេដ្ឋកិច្ចទីផ្សារ ប៉ុន្តែសំដៅជំរុញការធ្វើវិនិយោគទុននានា ឆ្ពោះទៅរកគោលដៅអាទិភាពរបស់ជាតិ ដើម្បីជៀសវាងការប្រឹងប្រែងដដែលៗ និងតាមដែលអាចធ្វើទៅបាន។ ការធ្វើផែនការបែបនេះ សំដៅកាត់បន្ថយវដ្តអស្ថិរភាពនៃសេដ្ឋកិច្ច។ នៅទីបញ្ចប់ ការរៀបចំផែនការទាមទារឱ្យមានការដោះស្រាយនូវបញ្ហាប្រឈម និងឧបសគ្គដែលនាំទៅរកអស្ថិរភាព ព្រមទាំងទាមទារឱ្យមានការពិចារណាពីបញ្ហាប្រឈមនៃគ្រោះមហន្តរាយធម្មជាតិ។ ផ្នែកទាំងពីរខាងក្រោម នឹងពិពណ៌នាអំពីការវិវត្ត នៃការអនុវត្តការធ្វើផែនការ ពីការរៀបចំផែនការបែបប្រពៃណី ទៅជាការធ្វើផែនការយុទ្ធសាស្ត្រ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)។

## ២.២. ការរៀបចំផែនការបែបប្រពៃណី

នៅដើមទសវត្សរ៍ទី៦០ ការរៀបចំផែនការអប់រំ ត្រូវបានគេចាត់ទុកថាជាការចាំបាច់បំផុត សម្រាប់ប្រទេសឯករាជ្យថ្មី ដើម្បីឱ្យពួកគេអាចឈានទៅរកការអភិវឌ្ឍធនធានមនុស្ស ដែលមានលក្ខណៈជាប្រព័ន្ធ។ ការរៀបចំផែនការអប់រំបែបនេះ ត្រូវបានរៀបចំឡើងនៅក្នុងក្រសួងអប់រំ ប៉ុន្តែពឹងផ្អែកទាំងស្រុងទៅលើអ្នកឯកទេសខាងក្រៅ។ ផែនការអប់រំមួយចំនួន ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើវិធីសាស្ត្រ។ ការធ្វើផែនការអប់រំមានបីប្រភេទដែលត្រូវបានគេប្រើប្រាស់ចាប់ពីទសវត្សរ៍ទី៦០ រហូតទៅដល់ចុងទសវត្សរ៍ទី៨០។

១. វិធីសាស្ត្របែបការរៀបចំផែនការផ្អែកលើកម្លាំងធនធានមនុស្ស៖ វិធីនេះរួមមាន ការភ្ជាប់វិស័យអប់រំទៅនឹងតម្រូវការសេដ្ឋកិច្ចដែលគេរំពឹងទុក

២. វិធីសាស្ត្របែបតម្រូវការសង្គម៖ ការវិវឌ្ឍអប់រំត្រូវឆ្លើយតបទៅនឹងតម្រូវការសង្គម

៣. វិធីសាស្ត្របែបសេដ្ឋកិច្ច៖ ការវិវឌ្ឍរាល់វិស័យអប់រំ គឺផ្អែកលើអ្វីដែលគេចាត់ទុកថាជាប្រយោជន៍ដល់សង្គមសម្រាប់វិស័យអប់រំនីមួយៗ។

ការរៀបចំផែនការអប់រំ គឺជាលំហាត់ដ៏សាមញ្ញមួយ ដែលផ្អែកលើវិធីសាស្ត្រ ដំណើរការ និងតួអង្គ។ ផែនការអប់រំ គឺទាក់ទងជាចម្បងជាមួយនឹងការរៀបចំធាតុចូលសំខាន់ៗ រួមមាន៖ គណៈគ្រប់គ្រង គ្រូបង្រៀន សាលារៀន ថ្នាក់រៀន ជាជាងការត្រួតពិនិត្យមើលលទ្ធផល។ ការរៀបចំផែនការ ត្រូវបានបង្កើតឡើងភាគច្រើនដោយរដ្ឋាភិបាល សម្រាប់វិស័យសាធារណៈ និងផ្តល់ការយកចិត្តទុកដាក់មានដែនកំណត់ចំពោះថ្នាក់រដ្ឋបាលក្រោមជាតិ និងវិស័យឯកជន។

ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលជាច្រើនមិនបានឆ្លើយតបទៅនឹងការរំពឹងទុកនោះទេ ហើយភាពអស់សង្ឃឹមចំពោះការធ្វើផែនការ បានកើតនៅទសវត្សរ៍ទី៧០ និងកាន់តែមានសភាពខ្លាំងឡើងៗនៅទសវត្សរ៍ទី៨០។ នៅពេលនោះ មានការរិះគន់ជាច្រើន ស្តីពីការរៀបចំផែនការបែបប្រពៃណី ដូចមានរៀបរាប់ខាងក្រោម៖

- អាទិភាពត្រូវបានផ្តល់ទៅលើបរិមាណជាងគុណភាព៖ ផែនការអប់រំភាគច្រើន ត្រូវបានយកចិត្តទុកដាក់ទៅលើចំនួនសិស្សបញ្ចប់ការសិក្សា ជាជាងគុណភាពនៃការសិក្សានៅសាលារៀន។

- មិនបានយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើផលវិបាក នៃការផ្លាស់ប្តូរផ្នែកបរិស្ថានសេដ្ឋកិច្ច សង្គម និងបច្ចេកវិទ្យា៖ ផែនការត្រូវបានគេអនុវត្តក្នុងរបៀបមួយតឹងរ៉ឹង និងច្រំដែលៗ ដោយមិនបានយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរដែលអាចកើតមានឡើងក្នុងបរិស្ថាននីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌខាងក្រៅកំពុងតែផ្លាស់ប្តូរជាប្រចាំ ដូចដែលបានបង្ហាញតាមរយៈវិបត្តិសេដ្ឋកិច្ចនៅទសវត្សរ៍ទី៧០ និងទី៨០ និងវិបត្តិហិរញ្ញវត្ថុដែលប៉ះពាល់ដល់សេដ្ឋកិច្ចនៅទ្វីបអាស៊ីនៅចុងទសវត្សរ៍ទី៩០។ ការផ្លាស់ប្តូរដទៃទៀតបានកើតឡើងតាមរយៈព័ត៌មាន និងបច្ចេកវិទ្យាថ្មី រួមទាំងឥទ្ធិពលសាកលភាវូបនីយកម្ម និងប្រភពព័ត៌មានខាងក្រៅ។ ការរៀបចំផែនការ គឺមិនមានភាពទន់ភ្លន់គ្រប់គ្រាន់ ដើម្បីសម្របការអប់រំទៅនឹងស្ថានភាពប្រែប្រួលនោះទេ។
- ផែនការត្រូវបានរៀបចំដោយថ្នាក់ជាតិ និងតាមបែបបច្ចេកាធិបតេយ្យ៖ ផែនការភាគច្រើនត្រូវបានរៀបចំដោយអង្គភាពជំនាញផ្នែកធ្វើផែនការ (ភាគច្រើនតាមរយៈជំនាញការបរទេស) ដោយមានការចូលរួម ឬគ្មានការចូលរួមពីបុគ្គលិកក្រសួងដទៃទៀត ជាពិសេសនាយកដ្ឋានហិរញ្ញវត្ថុ ដោយមិនបានអើពើចំពោះបុគ្គលិកថ្នាក់ក្រោមជាតិ អង្គការក្រៅរដ្ឋាភិបាល និងមាតាបិតាសិស្ស។ ផលវិបាក គឺការមិនបានកំណត់វត្ថុបំណងនៃផែនការ និងសកម្មភាពជាអាទិភាពឱ្យបានច្បាស់លាស់ (សូម្បីតែចំណេះដឹងនៃផែនការ និងសកម្មភាពអាទិភាព) តាមរយៈអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិផែនការនោះ។ តាមពិតនៅពេលដែលផែនការត្រូវបានរៀបចំដោយអ្នកឯកទេសមួយក្រុមតូច ការទទួលខុសត្រូវក្នុងការប្រតិបត្តិផែនការនោះ ទាមទារឱ្យមានការចូលរួមរបស់បុគ្គលិកទាំងអស់នៅក្នុងអង្គភាពនោះ និងទាមទារឱ្យមានកិច្ចសហប្រតិបត្តិការពីភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់។
- ការរៀបចំផែនការ និងការលើកគម្រោងថវិកាពុំសូវមានទំនាក់ទំនងគ្នា៖ ផែនការ និងថវិកាត្រូវបានរៀបចំឡើងដោយនាយកដ្ឋានពីរផ្សេងគ្នា និងគ្មានទំនាក់ទំនងគ្នាច្រើនឡើយ។ ជាងនេះទៀត វាគ្មានភាពច្បាស់លាស់ និងគ្មានលក្ខណៈជាប្រព័ន្ធទេ រវាងរចនាសម្ព័ន្ធថវិកាតាមអនុវិស័យ តាមប្រភេទស្ថាប័ន និងតាមលក្ខណៈនៃការចំណាយ ក៏ដូចជារចនាសម្ព័ន្ធនៃផែនការតាមអនុវិស័យ តាមវត្ថុបំណង និងតាមសកម្មភាពទាំងនោះ។ លើសពីនេះ ខណៈដែលថវិកាត្រូវបានរៀបចំចង

ក្រុងប្រចាំឆ្នាំនោះ ផែនការដែលគ្របដណ្តប់រយៈពេល ៥ឆ្នាំ មិនអាចរួមបញ្ចូលក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធបានឡើយ។ ដូច្នេះផែនការខ្វះខាតភាពប្រាកដនិយមផ្នែកហិរញ្ញវត្ថុ ដែលបានដាក់កម្រិតយ៉ាងធ្ងន់ធ្ងរលើការអនុវត្តផែនការទាំងនោះ។

- ការយកចិត្តទុកដាក់ភាគច្រើន មានតែទៅលើការរៀបចំផែនការ និងគ្មានការយកចិត្តទុកដាក់គ្រប់គ្រាន់ទៅលើការអនុវត្តផែនការនោះទេ៖ វាជាការសន្មត់លឿនពេកថានៅពេលដែលមានការរៀបចំ និងអនុម័តផែនការល្អមួយនោះ ការអនុវត្តសមស្រប នឹងកើតមានដោយស្វ័យប្រវត្តិ។ វាមានយន្តការតិចតួចប៉ុណ្ណោះដែលត្រូវបានរៀបចំឡើងសម្រាប់រៀបចំផែនការ និងការពិនិត្យតាមដានជាប្រព័ន្ធលើការអនុវត្តផែនការ។

ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ និងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរនាដំណាច់ទសវត្សរ៍ទី៨០ នៃសតវត្សរ៍ទី២០ ផែនការរយៈពេលមធ្យម ដែលត្រូវបានរៀបចំឡើងដោយបណ្តាប្រទេសជាច្រើន គឺមិនត្រូវបានអនុវត្តឡើយ ខណៈគម្រោងផ្សេងៗ ដែលទទួលបានហិរញ្ញវត្ថុពីទីភ្នាក់ងារផ្តល់មូលនិធិនានា បាននឹងកំពុងអនុវត្ត ដោយគ្មានការសម្របសម្រួលរវាងគ្នាឡើយ។ នៅពេលមានការខ្វះខាតធនធាន ការរៀបចំផែនការរយៈពេលខ្លី ការត្រៀមរៀបចំថវិកា និងការត្រៀមរៀបចំគម្រោងបានប្រែក្លាយទៅជាសកម្មភាពរៀបចំផែន ការរួម។ មនុស្សចាប់ផ្តើមប្រឈមនឹងយុត្តិកម្មនៃការរៀបចំផែនការអប់រំ។ ការរៀបចំផែនការតាមបែបប្រពៃណីបានចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗ បន្ទាប់ពីមានការមិនពេញចិត្ត ជាមួយនឹងលទ្ធផលជាក់ស្តែងដែលទទួលបានពីការរៀបចំផែនការ។ ការយល់ដឹងកាន់តែច្បាស់ អំពីការលំបាកនៅក្នុងការព្យាករណ៍ឱ្យ បានកាន់តែសុក្រឹតក្នុងបរិយាកាសប្រែប្រួលយ៉ាងឆាប់រហ័ស និងការទទួលស្គាល់ដ៏ល្អប្រសើរលើតួនាទីរបស់តួអង្គ ភាគីពាក់ព័ន្ធ និងចលករខាងក្រៅក្នុងការអនុវត្តផែនការ បានធ្វើឱ្យមានការផ្លាស់ប្តូរការរៀបចំផែនការតាមបែបប្រពៃណី។

តម្រូវការទម្រង់ថ្មីមួយនៃការរៀបចំផែនការ បានលេចឡើងដោយមានគំនិតផ្តួចផ្តើមថ្មីៗ ដូចជាការអប់រំសម្រាប់ទាំងអស់គ្នា ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងការបង្កើតវិធីសាស្ត្រចម្រុះវិស័យ ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍ ក្នុងទសវត្សរ៍ទី៩០នៃសតវត្សរ៍ទី២០។ ជំនួយដែលផ្តល់

ដោយម្ចាស់ជំនួយត្រូវបានលើកឡើងថាអាចមានប្រសិទ្ធភាព ល្អឹកណាជំនួយទាំងនោះ គាំទ្រការអនុវត្ត យុទ្ធសាស្ត្រថ្នាក់ជាតិច្បាស់លាស់មួយដែលបានបង្កើតឡើង និង"គ្រប់គ្រង" ដោយប្រទេសទទួលជំនួយ។ ការពិត វត្តមានផែន ការវិស័យអប់រំ និងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ត្រូវបានចាត់ទុកជាលក្ខណៈវិនិច្ឆ័យចម្បងដើម្បីទទួលបានអត្ថប្រយោជន៍ពីគំនិតផ្តួចផ្តើម ពន្លឿនការអប់រំ ក្រោមក្របខ័ណ្ឌការអប់រំសម្រាប់ទាំងអស់គ្នា (ដែលឈ្មោះនេះត្រូវបានផ្លាស់ប្តូរទៅជាភាពជាដៃគូសកល សម្រាប់ការអប់រំក្នុងឆ្នាំ២០១១) បានធ្វើឱ្យមានចំណាប់អារម្មណ៍ជាថ្មីលើការរៀបចំផែនការ និងផ្តល់ការជំរុញដល់ការបង្កើតទម្រង់ថ្មីមួយនៃការរៀបចំផែនការអប់រំ។

ជាលទ្ធផល ការរៀបចំផែនការ បានឆ្ពោះទៅរកវិធីសាស្ត្រមួយ ដែលផ្តោតកាន់តែខ្លាំងទៅលើលទ្ធផលសម្រេច កាន់តែមានការចូលរួម និងកាន់តែមានភាពបត់បែន។ គំរូនៃការរៀបចំផែនការនេះ ត្រូវបានហៅថា "ការរៀបចំផែនការយុទ្ធសាស្ត្រ" និងត្រូវបានពិពណ៌នាក្នុងផ្នែកខាងក្រោម (Carron, G. et al. 2010a: 13)

## ២.៣. ការរៀបចំផែនការយុទ្ធសាស្ត្រ

ការរៀបចំផែនការយុទ្ធសាស្ត្រ គឺជាដំណើរការសម្រាប់កំណត់ស្ថានភាពជាទីគាប់ប្រសើរដែលត្រូវតែសម្រេចឱ្យបាននូវការងារពាក់ព័ន្ធដែលត្រូវអនុវត្តដើម្បីសម្រេចគោលដៅចំណាយសមស្របមួយ។ការរៀបចំផែនការយុទ្ធសាស្ត្រ ក៏ជាឧបករណ៍គ្រប់គ្រងមួយដែលត្រូវបានប្រើប្រាស់ដើម្បីជួយឱ្យអង្គភាពមួយអាចលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន ដោយធានាថាសមាជិករបស់ខ្លួនធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅតែមួយ និងកែសម្រួលទិសដៅរបស់អង្គភាពជាបន្តបន្ទាប់ដើម្បីសម្រេចតាមស្ថានភាពប្រែប្រួលដោយផ្អែកលើលទ្ធផលសម្រេចបាន។

ម្យ៉ាងវិញទៀត ការរៀបចំផែនការយុទ្ធសាស្ត្រ គឺមិនមែនសុទ្ធតែជាការងារបច្ចេកទេសដែលបញ្ជាក់ពីវត្ថុបំណងនាពេលខាងមុខដែលត្រូវសម្រេចឱ្យបាន និងសកម្មភាពដែលត្រូវអនុវត្តនោះឡើយ។ ការរៀបចំផែនការយុទ្ធសាស្ត្រតម្រូវឱ្យមានគោលបំណងច្បាស់លាស់ និងទិសដៅដែលអាចណែនាំអ្នកអនុវត្តនៅក្នុងការបង្កើតជម្រើសប្រចាំថ្ងៃ ពីសកម្មភាពដែលគួរអនុវត្ត ដើម្បីសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុក។

ជាការពិតណាស់ផែនការអប់រំដែលអនុវត្តតាមវិធីសាស្ត្រជាយុទ្ធសាស្ត្រអាចនៅមានលក្ខណៈមួយចំនួនរបស់ផែនការបែបប្រពៃណី។ បន្ថែមពីលើនេះវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រសន្មត់ពីការបង្កើតវប្បធម៌នៃការគ្រប់គ្រងបែបថ្មី ដោយផ្អែកលើគុណតម្លៃនៃការធ្វើសេចក្តីសម្រេចដែលមានការចូលរួម មានគណនេយ្យភាព និងតម្លាភាព។ ការផ្លាស់ប្តូរនេះសន្មត់ថា មានការគាំទ្រផ្នែកនយោបាយរឹងមាំ និងប្រកបដោយចីរភាព ក្នុងការកែលម្អវប្បធម៌នៃការគ្រប់គ្រងវិស័យសាធារណៈទាំងមូល។ ដំណើរការនេះអាចនឹងត្រូវចំណាយពេលវេលាក្នុងការអនុវត្ត និងចេញជាលទ្ធផលពិសេសនៅក្នុងបណ្តាប្រទេសដែលមិនបានបំពេញលក្ខខណ្ឌជាមូលដ្ឋានមួយចំនួនសម្រាប់ប្រព័ន្ធសេវាសាធារណៈដែលមានប្រសិទ្ធភាព។

ភាពខុសគ្នាចម្បងរវាងវិធីសាស្ត្រទាំងពីរនេះ ពោលគឺវិធីសាស្ត្របែបប្រពៃណី និងវិធីសាស្ត្រជាយុទ្ធសាស្ត្រមានសង្ខេបនៅក្នុងតារាងទី១។

***តារាងទី1៖ ភាពខុសគ្នាសំខាន់ៗ រវាងការរៀបចំផែនការបែបប្រពៃណី និងការរៀបចំផែនការយុទ្ធសាស្ត្រ***

| **ការរៀបចំផែនការបែបប្រពៃណី** | **ការរៀបចំផែនការយុទ្ធសាស្ត្រ** |
|---|---|
| ផ្តោតលើធាតុចូល(ធនធាន) | ផ្តោតលើលទ្ធផល |
| សេចក្តីសម្រេចសំខាន់បែបបច្ចេកាធិបតេយ្យ | សេចក្តីសម្រេចត្រូវធ្វើឡើងទៅតាមសេចក្តីណែនាំពីថ្នាក់កណ្តាល ប៉ុន្តែមានការចូលរួមកាន់តែច្រើនជាងមុន |
| ការរៀបចំផែនការពីលើចុះក្រោម | ការរៀបចំផែនការពីលើមកក្រោម និងពីក្រោមទៅលើ |
| ការរៀបចំផែនការខ្សែបន្ទាត់ (លីនេអ៊ែរ) | ការរៀបចំផែនការដោយមានការកែលម្អឡើងវិញ |
| ផ្អែកលើទម្លាប់ | ផ្តោតលើការផ្លាស់ប្តូរ |
| ការអនុវត្តដោយមិនមានការបត់បែន | ការអនុវត្តសម្របទៅតាមកាលៈទេសៈប្រែប្រួលតាម រយៈការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ |
| ការពិនិត្យតាមដានលើការអនុលោមតាមផែនការ | ការពិនិត្យតាមដានលើលទ្ធផលការងារ |
| ផ្តោតលើឯកសារផែនការ | ផ្តោតលើការអនុវត្តផែនការ |

( Carron, G. et al. 2010a: 13 )

## ២.៤. គោលការណ៍សំខាន់ៗនៃការរៀបចំផែនការអប់រំនៅកម្ពុជា

ប្រទេសកម្ពុជាមានក្របខ័ណ្ឌធ្វើផែនការដ៏រលូនមួយ សម្រាប់វិស័យអប់រំចាប់តាំងពីដើមសតវត្សរ៍ថ្មីមកម្ល៉េះ។ ឧបករណ៍ និងយន្តការសំខាន់ៗនៃដំណើរការរៀបចំផែនការអប់រំរបស់កម្ពុជារួមមាន៖

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) បង្កើតនូវក្របខ័ណ្ឌ និងសារាចរណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកំណែទម្រង់វិស័យអប់រំសម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិដំបូងត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ ហើយបញ្ហាប្រឈមនៅឆ្នាំបន្តបន្ទាប់ គឺការបង្កើតផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅគ្រប់រាជធានី-ខេត្ត។

ផែនការសកម្មភាពប្រចាំឆ្នាំ (AOP) គឺជាការប្រែក្លាយគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលមធ្យមដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឱ្យទៅជាសកម្មភាព និងចំណុចដៅប្រចាំឆ្នាំ ដោយបញ្ជាក់ពីប្រភពថវិកាទាំងអស់ (ពីរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល)។ ផែនការសកម្មភាពប្រចាំឆ្នាំ (AOP) ត្រូវបានបង្កើតត្រឹមថ្នាក់ជាតិ និងថ្នាក់ខេត្ត។ សន្និបាតអប់រំប្រចាំឆ្នាំ គឺជាព្រឹត្តិការណ៍មួយ ដែលក្នុងនោះការងារគ្រប់វិស័យទាំងអស់ត្រូវបានគេវាយតម្លៃ និងសកម្មភាពអាទិភាពនាពេលអនាគតទាំងអស់ត្រូវបានគេកំណត់។ សន្និបាតអប់រំត្រូវបានប្រារព្ធធ្វើឡើងដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

របាយការណ៍ការងារប្រចាំវិស័យនីមួយៗ៖រាយការណ៍ជូនសន្និបាតអប់រំជារៀងរាល់ឆ្នាំ។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨បានកំណត់អាទិភាពគោលនយោបាយសំខាន់ចំនួន៣ គឺការធានាបាននូវការដឹកនាំ និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពសម្រាប់បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ការចូលរៀនប្រកបដោយសមធម៌ និងការលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃសេវាកម្មអប់រំ។ អាទិភាពគោលនយោបាយនេះ ចង្អុលបង្ហាញពីតម្រូវការសម្រាប់ការផ្តល់ឱ្យ នូវសេវាកម្មអប់រំដែលមានប្រសិទ្ធភាព និងលក្ខណៈទន់ភ្លន់ជាង តាមរយៈការកែលម្អដំណើរការរៀបចំផែនការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ផ្នែកនេះនឹងផ្តល់ឱ្យនូវការពិពណ៌នាដ៏សង្ខេប ស្តីពីច្បាប់ តួនាទី និងការទទួលខុសត្រូវនានាដែលបង្កើតបាន

ជាមូលដ្ឋានគ្រឹះ សម្រាប់ឈានទៅរកដំណើរការនៃការរៀបចំផែនការអប់រំមួយ ឱ្យកាន់តែមានលក្ខណៈវិមជ្ឈការនៅកម្ពុជា។ អស់រយៈពេល១ទសវត្សរ៍មកហើយ ដែលរាជរដ្ឋាភិបាលកម្ពុជា បានបោះជំហានទៅមុខគួរជាទីកត់សម្គាល់ ក្នុងការពង្រឹងក្របខ័ណ្ឌជាតិ សម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍រួមរបស់ប្រទេស។ ចំណុចគន្លឹះមួយ ក្នុងចំណោមចំណុចគន្លឹះទាំងអស់នោះ គឺការបង្កើតច្បាប់ សារាចរ និងយុទ្ធសាស្ត្រជាច្រើន សម្រាប់ការគ្រប់គ្រងរដ្ឋបាលសាធារណៈទាំងមូល ប្រកបដោយលក្ខណៈល្អប្រសើរ និងមានលក្ខណៈកាន់តែវិមជ្ឈការ។ ការធ្វើផែនការ និងការគ្រប់គ្រងវិស័យអប់រំ គឺជាផ្នែករួមនៃកិច្ចខិតខំប្រឹងប្រែងសម្រាប់ការកែលម្អ ជាមួយនឹងការដាក់ឱ្យប្រើប្រាស់នូវច្បាប់ និងបទប្បញ្ញត្តិថ្មីជាបណ្តើរៗ ។ ទាំងនេះធ្វើឱ្យទិដ្ឋភាពនៃការធ្វើផែនការអប់រំនៅកម្ពុជាមានភាពផ្លាស់ប្តូរ។ ឯកសារគតិយុត្តខាងក្រោមនេះ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការរៀបចំផែនការអប់រំនៅកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពជំហានទី៣ បានដាក់ចេញនូវទស្សនៈ វិស័យរយៈពេលយូររបស់ប្រទេសកម្ពុជា។ វាបានបង្ហាញពីគោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងការកសាងសង្គមកម្ពុជា តាមរយៈការពង្រឹងសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់សង្គម ការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយសមធម៌ ចីរភាព ការបង្កើតលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ។ វិស័យអាទិភាពទាំង៤ របស់យុទ្ធសាស្ត្រចតុកោណគឺ (១) ការអភិវឌ្ឍធនធានមនុស្ស ដើម្បីជានាការប្រកួតប្រជែងសម្រាប់ទីផ្សារការងារនៅក្នុងតំបន់ (២) ការធ្វើវិនិយោគទុនខាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការកែលម្អការសម្របសម្រួលពាណិជ្ជកម្ម (៣) ការអភិវឌ្ឍ និងការបង្កើនតម្លៃបន្ថែមលើវិស័យកសិកម្ម និង (៤) ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពរបស់គ្រឹះស្ថានសាធារណៈ ដើម្បីកែលម្អប្រសិទ្ធភាពនៃការផ្តល់សេវាកម្មសាធារណៈព្រមទាំងបរិយាកាសនៃការធ្វើវិនិយោគទុន។ យុទ្ធសាស្ត្រចតុកោណត្រូវបានដាក់ឱ្យប្រើប្រាស់ជាលើកដំបូងនៅឆ្នាំ២០០៤ ហើយត្រូវបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០០៨ និងឆ្នាំ២០១៣។ ច្បាប់ស្តីពីការរៀបចំអង្គការ(ព្រះរាជក្រមលេខ NS/RKM/0508/017)៖ ច្បាប់ស្តីពីការរៀបចំអង្គការឆ្នាំ២០០៨ បានផ្តល់ឱ្យនូវមូលដ្ឋានគ្រឹះផ្លូវច្បាប់ សម្រាប់ការធ្វើកំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការនៅកម្ពុជា។ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំអង្គការ បានផ្តល់អំណាច

ផ្នែករដ្ឋបាលដល់ថ្នាក់ក្រោមជាតិ ដោយរាប់បញ្ចូលការបែងចែកទៅជាខេត្ត និងរាជធានី។ ក្នុងនោះ ខេត្ត បែងចែកជាស្រុក ស្រុកបែងចែកជាឃុំ ហើយរាជធានីបែងចែកជាខណ្ឌ ខណ្ឌបែងចែកជាសង្កាត់។ ជាង នេះទៅទៀត ច្បាប់ស្តីពីការរៀបចំអង្គការ បានបញ្ជាក់ថារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាអង្គភាពច្បាប់មួយ បង្កើតឡើងដោយក្រុមប្រឹក្សាដែលជ្រើសរើសតាមរយៈការបោះឆ្នោតហើយបានគួសបញ្ជាក់ផងដែរថា ពួក គេគួរតែអនុវត្តតាមគោលការណ៍រដ្ឋបាលបែបប្រជាធិបតេយ្យ នៅក្នុងរដ្ឋឯកភាពមួយ។ ក្រុមប្រឹក្សាទាំង នោះគឺមានសារៈសំខាន់ណាស់ក្នុងការអនុវត្តវិសហមជ្ឈការ និងវិមជ្ឈការឱ្យមានប្រសិទ្ធភាព ហើយក្រុម ប្រឹក្សាទាំងអស់នោះមានតួនាទី ភារកិច្ច និងអំណាចទូលំទូលាយ។ ឧទាហរណ៍នៃការទទួលខុសត្រូវរួម មានកម្មវិធីវិនិយោគទុនច្រើនឆ្នាំ ផែនការអភិវឌ្ឍន៍៥ឆ្នាំ ក្របខ័ណ្ឌថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយ ថវិការយៈពេលមធ្យម។

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD) ឆ្នាំ២០១០-២០១៩៖ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិគឺជាជំហានថ្មីបំផុត មួយដែលបានធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា នៅលើផ្លូវឆ្ពោះទៅកាន់ការអនុវត្តគោលនយោបាយកម្ម វិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ហើយការធ្វើបែបនេះ គឺជាការសម្រេច បាននូវវត្ថុបំណងនៃការកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍជនបទ។ គោលនយោបាយសម្រាប់ ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ក្នុងក្របខ័ណ្ឌយុទ្ធ សាស្ត្រសម្រាប់កំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការ។ ក្របខ័ណ្ឌច្បាប់នេះ ត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីការរៀបចំអង្គការនៅឆ្នាំ២០០៨ ហើយកំណែទម្រង់ជាច្រើន បានចាប់ផ្តើមជាមួយការ បោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នៅកម្រិតរាជធានី/ខេត្ត កម្រិតក្រុង/ស្រុក/ខណ្ឌនៅឆ្នាំ២០០៩។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD) ដឹកនាំដោយគណៈកម្ម ការជាតិដែលបានតែងតាំងឡើងដោយព្រះរាជក្រឹត្យនៅឆ្នាំ២០០៨ ដើម្បីសម្របសម្រួល និងដឹកនាំការ អនុវត្តច្បាប់ស្តីពីការរៀបចំអង្គការ។ កម្មវិធីនេះមាន ៥ វិស័យ៖ (១) ការអភិវឌ្ឍស្ថាប័នក្រោមជាតិ (២) ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (៣) ការផ្ទេរមុខងារ និងធនធាន (៤) ប្រព័ន្ធគ្រប់គ្រងទ្រព្យ

សម្បត្តិ ហិរញ្ញវត្ថុ និងថវិកាថ្នាក់ក្រោមជាតិ (៥) ស្ថាប័នគាំទ្រសម្រាប់ដំណើរការកំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការ។

តួនាទី និងការទទួលខុសត្រូវក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ៖ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ បានបញ្ជាក់ថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវបានអនុវត្តស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ជាមួយនឹងការផ្ទេរមុខងារ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុជាបណ្តើរៗទៅដល់ថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ និងសាលារៀន។ ជាងនេះទៅទៀត វាបានគូសបញ្ជាក់ថាផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវបានណែនាំដោយច្បាប់ស្តីពីការរៀបចំអង្គការ និងយុទ្ធសាស្ត្រវិសហមជ្ឈការ និងវិមជ្ឈការ ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD)។ នៅក្នុងប្រព័ន្ធអប់រំ ផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០១៤-២០១៨ បានគូសបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាពរដ្ឋបាល និងអនុវិស័យអប់រំផ្សេងៗគ្នា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ បញ្ជាក់ថា៖

**ក្រសួងអប់រំ យុវជន និងកីឡា** មានការទទួលខុសត្រូវផ្នែកបច្ចេកទេសទាំងអស់ ស្តីពីការអនុវត្ត និងការតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ រដ្ឋមន្ត្រី និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា ជួបគ្នាជាទៀងទាត់ ដើម្បីពិនិត្យមើលឡើងវិញនូវការវិវត្តន៍តាមវិស័យនីមួយៗ និងបង្ហាញរបាយការណ៍ប្រចាំឆ្នាំនៅក្នុងសន្និបាតអប់រំ។ របាយការណ៍នេះ អាចស្នើនូវការផ្លាស់ប្តូរផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឬក្របខ័ណ្ឌតាមដាន។

**អនុវិស័យនីមួយៗ** ទទួលបន្ទុកដោយរដ្ឋលេខាធិការមួយរូប ឬអនុរដ្ឋលេខាធិការមួយរូប។ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ត្រូវបានគាំទ្រដោយអគ្គនាយក ឬអគ្គនាយករង។ អនុវិស័យមួយនឹងត្រូវបានប្រតិបត្តិ តាមរយៈក្រុមការងារអនុវិស័យ ដែលរាប់បញ្ចូលនាយកដ្ឋានបច្ចេកទេសដែលដើរតួនាទីដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ។ ការរៀបចំ និងតួនាទីនៅក្នុងអនុវិស័យមួយ អាចមានការប្រែប្រួលទៅតាមបទពិសោធន៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំជាក់ស្តែង។ ក្រុមការងារនីមួយៗរៀបចំបំណែងចែកភារកិច្ចរបស់បុគ្គលិកអប់រំម្នាក់ៗ។ ពួកគេនឹងរៀបចំ

ផែនការសកម្មភាពប្រចាំឆ្នាំ និងរយៈពេលច្រើនឆ្នាំ។ នាយកដ្ឋានផែនការដើរតួជាអ្នកសម្របសម្រួលរបស់អង្គភាពឬអនុវិស័យនីមួយៗ។

**នាយកដ្ឋានបច្ចេកទេស** ផ្តល់ការគាំទ្រដល់មន្ត្រីថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ក្នុងការអនុវត្ត តាមដាន និងធ្វើរបាយការណ៍ស្តីអំពីកម្មវិធីផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំប្រចាំរាជធានី-ខេត្ត។

**មន្ទីរអប់រំរាជធានី-ខេត្ត** (POE) រៀបចំ និងតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី-ខេត្ត។ ការវិវឌ្ឍនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី-ខេត្ត (ដែលនឹងត្រូវបានរៀបចំដោយយកតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា) ត្រូវបានគេរាយការណ៍ នៅក្នុងសន្និបាតអប់រំខេត្ត។ ខេត្តមានតួនាទីគ្រប់គ្រងសាលាមធ្យមសិក្សា ដោយរាប់បញ្ចូលការប្រគល់ភារកិច្ចក្រោមរូបភាពវិមជ្ឈការ។ អភិបាលរាជធានី-ខេត្ត នៃក្រុមប្រឹក្សាភិបាលរាជធានី-ខេត្ត ធ្វើជាអធិបតីភាព នៃគណៈកម្មការការអប់រំសម្រាប់ទាំងអស់គ្នារបស់រាជធានី-ខេត្ត។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត (POE) រៀបចំថវិកាអប់រំរបស់ខ្លួនសម្រាប់ដាក់ជូនអភិបាលរាជធានី-ខេត្ត។

**ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ** (DOE) រៀបចំផែនការការងារប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី-ខេត្ត និងរៀបចំរបាយការណ៍ស្តីពីការរីកចម្រើនប្រចាំត្រីមាស។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ មានតួនាទីគ្រប់គ្រងសាលាបឋមសិក្សាដោយរាប់បញ្ចូលការប្រគល់ភារកិច្ចក្រោមរូបភាពវិមជ្ឈការ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ (DOE) រៀបចំថវិកាអប់រំរបស់ក្រុង-ស្រុក-ខណ្ឌ សម្រាប់ដាក់ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត(POE)។ អភិបាលក្រុង-ស្រុក-ខណ្ឌនៃក្រុមប្រឹក្សាភិបាលក្រុង-ស្រុក-ខណ្ឌ ធ្វើជាអធិបតីភាពនៃគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នារបស់ក្រុង-ស្រុក-ខណ្ឌ។ ក្រុមពិនិត្យតាមដានបច្ចេកទេសថ្នាក់ក្រុង-ស្រុក-ខណ្ឌ (DTMT) គាំទ្រការអនុវត្តតាមដាន និងការធ្វើរបាយការណ៍ពីផែនការរបស់ស្រុកនៅកម្រិតសាលារៀន។

**ក្រុមប្រឹក្សាឃុំ សង្កាត់** គ្រប់គ្រង និងផ្តល់ហិរញ្ញវត្ថុដល់កម្មវិធីអប់រំ និងថែទាំកុមារតូច (មត្តេ

យុសហគមន៍ និងការរៀនតាមផ្ទះ)។ ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ធ្វើជាអធិបតីភាពនៃគណៈកម្មការការអប់រំសម្រាប់ទាំងអស់គ្នារបស់ឃុំសង្កាត់ ។

**គណៈកម្មការគាំទ្រសាលា**(LSSC)៖ សាលារៀនដោយមានការគាំទ្រពីគណៈកម្មការគាំទ្រសាលារៀន(LSSC) រៀបចំផែនការអភិវឌ្ឍន៍សាលារៀន រៀបចំចំណាយ និងធ្វើរបាយការណ៍ថវិកាសាលារៀនសម្រាប់ការផ្តល់ថវិកាតាមផ្នែកនីមួយៗ (ថវិកាកម្មវិធី) និងប្រភពថវិកាសម្រាប់ការកែលម្អសាលារៀនដទៃទៀត ឱ្យមានការរីកចម្រើនព្រមទាំងតាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ (DOE) (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)

## ២.៥. ការរៀបចំផែនការវិស័យអប់រំ

គោលគំនិតសំខាន់បំផុតក្នុងការរៀបចំផែនការវិស័យអប់រំរួមមាន៖ ការពិពណ៌នាអំពីអ្វីទៅជាផែនការអប់រំដ៏ល្អ ការបង្ហាញពីផ្នែកជាគន្លឹះសម្រាប់ដំណើរការរៀបចំផែនការប្រកបដោយប្រសិទ្ធភាពព្រមទាំងជំហានសំខាន់ៗ ក្នុងការអភិវឌ្ឍផែនការវិស័យអប់រំ។

### ២.៥.១. លក្ខណៈសម្បត្តិនៃផែនការវិស័យអប់រំដ៏ល្អមួយ

ការបែងចែកឱ្យដាច់នៃលក្ខណៈសម្បត្តិនៃផែនការវិស័យអប់រំដ៏ល្អគឺអាចធ្វើទៅបាន។ លក្ខណៈសម្បត្តិទាំងនោះ អាចយកទៅអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺណែនាំដោយចក្ខុវិស័យរួម បេសកម្មបញ្ជាក់ពីទិសដៅរួម ដោយរាប់បញ្ចូលទាំង (១) គោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល (២) វិធីសាស្ត្រដែលរាជរដ្ឋាភិបាលអនុវត្តតាមដើម្បីសម្រេចនូវគោលដៅ (៣) គោលការណ៍ និងគុណតម្លៃនៃការប្រើប្រាស់វិធីសាស្ត្រនេះ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺមានលក្ខណៈជាយុទ្ធសាស្ត្រ។ វាសម្គាល់នូវយុទ្ធសាស្ត្រទាំងឡាយសម្រាប់សម្រេចបាននូវចក្ខុវិស័យរួមមាន សមត្ថភាពមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីដាក់ចេញនូវអាទិភាពនានា។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំមានលក្ខណៈជារួម។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំរាប់បញ្ចូលអនុវិស័យទាំងអស់ព្រមទាំងការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធផងដែរ។ វាទទួលស្គាល់នូវតម្រូវការសម្រាប់

តុល្យភាពក្នុងចំណោមអនុវិស័យទាំងអស់ និងឆ្លុះបញ្ចាំងពីការយល់ដឹងដែលថាការសិក្សាកើតឡើងពេញមួយជីវិត។ អ្នកសិក្សាគឺជាអ្នកទទួលផលប្រយោជន៍ពីប្រព័ន្ធអប់រំ ជាមួយសិទ្ធិ និងតម្រូវការដែលគេទទួលស្គាល់។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺអាចធ្វើទៅបាន។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺត្រូវផ្អែកលើការវិភាគនិន្នាការបច្ចុប្បន្ន និងសម្មតិកម្មប្រកបដោយការត្រិះរិះ សម្រាប់ពុះពារឧបសគ្គខាងហិរញ្ញវត្ថុ បច្ចេកទេស និងនយោបាយដើម្បីធ្វើការអនុវត្តឱ្យមានប្រសិទ្ធភាព។ កម្មសិទ្ធិរបស់អ្នកពាក់ព័ន្ធ មានឥទ្ធិពលទៅលើភាពដែលអាចធ្វើទៅបាន។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ត្រូវស៊ីទៅនឹងបរិបទ វារាប់បញ្ចូលការវិភាគភាពងាយរងគ្រោះដែលមាននៅក្នុងប្រទេស។ ភាពងាយរងគ្រោះអាចរាប់បញ្ចូលជម្លោះ គ្រោះមហន្តរាយធម្មជាតិ និងវិបត្តិសេដ្ឋកិច្ច។ល។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវតែលើកឡើងនូវការត្រៀមលក្ខណៈ ការការពារ និងការកាត់បន្ថយហានិភ័យ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ លើកឡើងពីភាពខុសប្លែកគ្នានៅក្នុងប្រទេសនីមួយៗ ហើយធ្វើការពិចារណាលើបញ្ហានេះ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ មិនត្រឹមតែត្រូវបានបង្កើតឡើងសម្រាប់ប្រទេសមួយចំនួនប៉ុណ្ណោះទេ តែសម្រាប់គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ដែលមានក្រុមមនុស្សជួបប្រទះការលំបាកហើយពួកគេទាមទារនូវការយកចិត្តទុកដាក់ជាអាទិភាព។

### ២.៥.២. ផ្នែកសំខាន់ៗនៃដំណើរការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព

ជាមួយការអភិវឌ្ឍផែនការវិស័យអប់រំ នៅក្នុងប្រទេសកាន់តែច្រើនបទពិសោធន៍ជាច្រើនត្រូវបានបង្ហាញអំពីរបៀបរៀបចំផែនការឱ្យបានប្រសើរបំផុត។

ដំណើរការនៃការចូលរួម៖ ដំណើរការរៀបចំផែនការ គួរធ្វើឡើងតាមរយៈការសន្ទនាផុលផុសដែលអាចបង្កើតនូវកិច្ចព្រមព្រៀងលើការអភិវឌ្ឍវិស័យអប់រំ។ វាគួរតែជាដំណើរការចូលរួមមួយសំដៅសម្រេចឱ្យបាននូវលទ្ធផលដូចខាងក្រោម៖ អនុញ្ញាតឱ្យមេដឹកនាំនយោបាយ និងអ្នកឯកទេសស្វែងរកនូវតុល្យភាពរវាងមហិច្ឆតានយោបាយ និងឧបសគ្គខាងបច្ចេកទេស។ លើកកម្ពស់ការយល់ដឹង និងទទួល

បានការប្តេជ្ញាចិត្តរបស់អ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ ដំណើរការនេះ គួរតែចូលរួមដោយតំណាងក្រសួងពាក់ព័ន្ធ (ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) រដ្ឋបាលអប់រំគ្រប់លំដាប់ថ្នាក់ អ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ សង្គមស៊ីវិល និងអ្នកផ្តល់ជំនួយមិនមែនរដ្ឋាភិបាល ព្រមទាំងដៃគូអន្តរជាតិ។ ការចូលរួមរបស់តួអង្គទាំងនេះ អាចកើតឡើងតាមរយៈការពិគ្រោះយោបល់នៅក្នុងអំឡុងពេលនៃដំណើរការរៀបចំផែនការ និងតាមរយៈការពិភាក្សាលើពង្រាងឯកសារផែនការ។ នៅថ្នាក់រាជធានី-ខេត្តក្រុមការងារបច្ចេកទេសរួមរបស់ខេត្ត គឺជាអ្នករៀបចំវេទិការដ៏មានតម្លៃសម្រាប់ការពិភាក្សាគោលនយោបាយ និងធ្វើឱ្យដំណើរការផែនការអប់រំកាន់តែប្រសើរ នាំឱ្យដំណើរការដែលមានការរៀបចំបានល្អ។ ប្រសិនបើការចូលរួមដំណើរការបានល្អ និងមានតួអង្គចូលរួមច្រើន នោះទាមទារឱ្យមានការរៀបចំយ៉ាងច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវ ជាពិសេសតួអង្គដែលដឹកនាំ និងសម្របសម្រួល។ រចនាសម្ព័ន្ធខាងក្រោមអាចមានប្រយោជន៍ដើម្បីពិចារណាទៅលើការអភិវឌ្ឍផែនការអប់រំរាជធានី-ខេត្ត នៅប្រទេសកម្ពុជា៖

- គណៈកម្មការដឹកនាំមានតួនាទីពិនិត្យមើល និងណែនាំពីដំណើរការ៖ គណៈកម្មការនេះរួមមានមន្ត្រីអប់រំជាន់ខ្ពស់ ជាមួយនឹងការចូលរួមពីមន្ត្រីពាក់ព័ន្ធដទៃទៀត ជាក់ស្តែងមន្ត្រីផ្នែកហិរញ្ញវត្ថុ និងផែនការ និងដៃគូអភិវឌ្ឍន៍។

- គណៈកម្មការរៀបចំផែនការ ធ្វើការសម្របសម្រួលការងារបច្ចេកទេសរាប់បញ្ចូលទាំងការកៀរគរអ្នកពាក់ព័ន្ធនៅក្នុងខេត្ត សម្រាប់ពិគ្រោះយោបល់ទូលំទូលាយ៖ គណៈកម្មការនេះ ដឹកនាំដោយប្រធានអ្នកសម្របសម្រួលបច្ចេកទេស ជាទូទៅប្រធានការិយាល័យផែនការ។ គណៈកម្មការរៀបចំផែនការ ជាទូទៅទទួលបន្ទុករៀបចំសេចក្តីព្រាងផែនការវិស័យអប់រំ។

- ក្រុមការងារផ្តោតការយកចិត្តទុកដាក់ទៅលើប្រធានបទ ឬអនុវិស័យជាក់លាក់ណាមួយ(ឧទាហរណ៍ ការអប់រំគ្រូបង្រៀន អប់រំកុមារតូច ហិរញ្ញវត្ថុ តាមដាន និងវាយតម្លៃ)។ ក្រុមការងារអាចត្រូវបានស្នើដោយគណៈកម្មការផែនការ ដើម្បីរៀបចំសេចក្តីព្រាងផ្នែកជាក់លាក់ណាមួយនៃផែនការ។

- ដំណើរការអភិវឌ្ឍសកម្មភាព៖ ដោយហេតុថាការអនុវត្តផែនការ ត្រូវពឹងផ្អែកលើតួអង្គច្រើន ក្នុងរដ្ឋបាលអប់រំ ចាប់តាំងពីរដ្ឋបាលថ្នាក់កណ្តាលរហូតដល់សាលារៀន។ វាសំខាន់ណាស់ដែលថាសមត្ថភាព

នៅគ្រប់កម្រិតត្រូវបានដោះស្រាយ។ ការរៀបចំផែនការ គឺជាទម្រង់នៃការអភិវឌ្ឍសមត្ថភាពមួយ។ ការធ្វើពង្រាងផែនការ និងការចូលរួមពិគ្រោះយោបល់ គឺមានតម្លៃសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងទឹកចិត្ត។ ការអភិវឌ្ឍសមត្ថភាពរួមមានការបង្កើតប្រព័ន្ធដោះស្រាយបញ្ហា ដើម្បីជំរុញការឯកភាពនៃការគ្រប់គ្រង។ វាក៏រាប់បញ្ចូលទាំងការធ្វើផែនការសម្រាប់ការផ្តល់ការបណ្តុះបណ្តាលជំនាញ ដល់អ្នកធ្វើផែនការផងដែរ។ វគ្គបណ្តុះបណ្តាលដែលផ្តល់ដោយវិទ្យាស្ថានជាតិអប់រំគឺជាផ្នែកនៃការខិតខំប្រឹងប្រែងដើម្បីអភិវឌ្ឍសមត្ថភាពរៀបចំផែនការនៅថ្នាក់ក្រោមជាតិ។ ទោះបីជាមានតម្រូវការគាំទ្របច្ចេកទេសខាងក្រៅក៏ដោយ វាចាំបាច់ត្រូវដាក់ជូនតាមរយៈរាជរដ្ឋាភិបាល មន្ត្រីធ្វើផែនការគាំទ្រអប់រំនៅថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់ស្រុកព្រមទាំងមានការសហការជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក។

### ២.៥.៣. ជំហានសំខាន់ៗក្នុងការរៀបចំផែនការ

ការរៀបចំផែនការ គឺជាវដ្តដំណើរការមួយដែលកើតឡើងច្រំដែលៗ។ ចំណុចដៅអាចត្រូវបានគេពិនិត្យឡើងវិញ បន្ទាប់ពីត្រូវបានគេធ្វើតេស្តទៅលើធនធានដែលមានស្រាប់ និងធនធានដែលរំពឹងទុក។ យុទ្ធសាស្ត្រអាចត្រូវបានគិតឡើងវិញ នៅពេលដែលកម្មវិធីលម្អិតត្រូវបានបង្កើតឡើង។ ការលំបាកនៃការអនុវត្តអាចនាំទៅរកតម្រូវការនៃការគិតពីចំណុចដៅ និងកម្មវិធីឡើងវិញ។ នៅពេលរៀបចំផែនការ ការពិគ្រោះយោបល់ទៀងទាត់ជាមួយនឹងបុគ្គលិករដ្ឋបាលអប់រំ និងអ្នកពាក់ព័ន្ធនឹងកើតមានឡើង។ ទាំងនេះអាចនាំទៅដល់ការកំណត់ទំហំ និងនិយមន័យនៃអាទិភាព ចំណុចដៅ និងព័ត៌មានលម្អិត ស្តីពីកម្មវិធីឡើងវិញ។ ការពិចារណាធំៗពីជំហាននៃការរៀបចំផែនការគឺ **កត្តានយោបាយ** ដែលទាក់ទងទៅដល់កម្រិតនៃការទទួលយកគំនិតនយោបាយរបស់ផែនការ **កត្តាសមត្ថភាព** ទាក់ទងដល់ប្រសិទ្ធភាពនៃរដ្ឋបាលអប់រំ និងបំណិនរបស់បុគ្គលិក **កត្តាបរិបទ** ទាក់ទងដល់ភាពទទួលរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ ឬគ្រោះមហន្តរាយធនធានមនុស្ស និង**កត្តាហិរញ្ញវត្ថុ** និយាយអំពីនិរន្តភាព និងភាពអាចព្យាករណ៍បាននៃធនធានហិរញ្ញវត្ថុ។

ដំណើរការនៃការរៀបចំផែនការ អាចត្រូវការពេលពី១២ ទៅ២៤ខែ អាស្រ័យទៅលើកត្តាជាច្រើន ជាពិសេសថាតើមានមូលដ្ឋានព័ត៌មានល្អដែរឬទេ និងថាតើនេះគឺជាផែនការវិស័យអប់រំដំបូង ដែលត្រូវ

បង្កើតឡើងនៅក្នុងប្រទេស ឬក្នុងខេត្ត។ ជំហានសំខាន់ៗនៃដំណើរការអភិវឌ្ឍផែនការយុទ្ធសាស្ត្រវិស័យអប់រំមានដូចតទៅ៖ (១) ហេតុវិនិច្ឆ័យវិស័យអប់រំ (២) អាទិភាពគោលនយោបាយយុទ្ធសាស្ត្រគន្លឹះ និងចំណុចដៅផែនការ (៣) ការសរសេរកម្មវិធី (៤) ការរៀបចំការអនុវត្ត និងសមត្ថភាព (៥) ការកំណត់តម្លៃ និងការផ្តល់ហិរញ្ញវត្ថុដល់ផែនការសកម្មភាព (៦) ការអភិវឌ្ឍ និងការផ្តល់ហិរញ្ញវត្ថុដល់ផែនការសកម្មភាព (៧) ការតាមដាន និងវាយតម្លៃ។

**ជំហានទី១៖ ហេតុវិនិច្ឆ័យវិស័យអប់រំ**

ជាទូទៅការវិភាគវិស័យអប់រំ គឺផ្តើមចេញពីមុំទាំងប្រាំបីសម្រាប់ធ្វើការវិភាគ ដែលត្រូវគិតដល់ពេលណាត្រូវដាក់បញ្ចូលគ្នា មុំទាំងនោះនឹងផ្តល់ការយល់ដឹងទូលំទូលាយទៅតាមវិស័យអប់រំ និងលទ្ធផលរបស់ប្រព័ន្ធអប់រំ។ មុំទាំងប្រាំបីនេះរួមមាន៖ (១) បរិបទ (២) គុណភាពអប់រំ (៣) លទ្ធភាពទទួលបានសេវាអប់រំ (៤) ប្រសិទ្ធភាពផ្ទៃក្រៅ (៥) ប្រសិទ្ធភាពផ្ទៃក្នុង (៦) ការចំណាយ និងហិរញ្ញប្បទាន (៧) សមធម៌ និង(៨) ការគ្រប់គ្រងអប់រំ។

**(១)បរិបទ៖** រួមមានបញ្ហាទាក់ទិនដល់ការជះឥទ្ធិពលជាពិសេសទៅលើការអប់រំដូចខាងក្រោម៖ បរិបទម៉ាក្រូសេដ្ឋកិច្ច៖ ទិន្នន័យសេដ្ឋកិច្ចទូទៅ ធនធានសាធារណៈ និងវិភាគទានរបស់ពួកគេទៅលើវិស័យទាំងអស់។ កត្តាប្រជាជន៖ ទិន្នន័យប្រជាជន ប្រជាជនគ្រប់អាយុចូលរៀន និងការធ្វើចំណាកស្រុក។ កត្តាវប្បធម៌សង្គម៖ សញ្ជាតិប្រជាជនតែមួយ វត្តមានក្រុមមនុស្សដែលងាយទទួលរងគ្រោះ ភាសាច្រើន ប្រជាជនដែលមានតម្រូវការអប់រំទាប។ កត្តាស្ថានភាពនយោបាយ៖ ស្ថិរភាព និងអស្ថិរភាពនយោបាយ ប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ។ ការវិភាគគោលនយោបាយដែលមានស្រាប់៖ គោលបំណង គឺស្វែងរកសមិទ្ធិផល ដោយអនុលោមទៅតាមគោលនយោបាយនាពេលបច្ចុប្បន្ន និងរកឱ្យឃើញនូវការអនុវត្តប្រកបដោយប្រសិទ្ធភាព។ ការវិភាគគោលនយោបាយដែលមានស្រាប់ គួរពិនិត្យមើលដូចខាងក្រោម៖ គោលនយោបាយអប់រំដែលមានស្រាប់ដែលបានឆ្លុះបញ្ចាំងពីការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល និងមាននៅក្នុងគម្រោងនៃការអភិវឌ្ឍអប់រំជាបន្តបន្ទាប់ គោលនយោបាយអភិវឌ្ឍរួម ដែលជះឥទ្ធិពលផ្ទាល់ទៅលើគោលនយោបាយអប់រំ (ឧទាហរណ៍ គោលនយោបាយឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រី

ក្រ និងផែនការអភិវឌ្ឍន៍) សកម្មភាពគាំទ្រភាពជាដៃគូទ្រង់ទ្រាយធំ។ ការវិភាគភាពងាយទទួលរងគ្រោះ៖ ការវិភាគវិនិច្ឆ័យតាមផ្នែកនីមួយៗ គួរតែវាយតម្លៃពីវត្តមាននៃហានិភ័យ ដូចជាគ្រោះមហន្តរាយធម្មជាតិ វិបត្តិសេដ្ឋកិច្ច ។ល។ និងឥទ្ធិពលសំខាន់ៗរបស់ពួកវាទៅលើវិស័យអប់រំ។

(២) **គុណភាពអប់រំ៖** នៅក្នុងការអនុវត្តជាក់ស្តែងប្រទេសទាំងអស់ មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងការវាយតម្លៃទៅលើគុណភាពនៃការអប់រំ។ ជាធម្មតា វាត្រូវបានគេវាយតម្លៃលើចំណេះដឹង និងសមត្ថភាពដែលសិស្ស ឬនិស្សិតបានទទួល។ មានការសិក្សាតិចតួចនិយាយពីការទទួលបាននូវឥរិយាបថ និងអាកប្បកិរិយា ដែលការសិក្សាត្រូវបានគេរំពឹងថានឹងមានការអភិវឌ្ឍ។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លៃនៃលទ្ធផលអប់រំដ៏ឥទ្ធិពលទៅលើការត្រួតពិនិត្យគុណភាពនៃ**បរិបទ និងធាតុចូល** នៃការសិក្សាដែលរួមមានគ្រូបង្រៀន កម្មវិធីសិក្សា ហេដ្ឋារចនាសម្ព័ន្ធសាលារៀន សម្ភារ និងដំណើរការនៃការបង្រៀន និងរៀនដោយខ្លួនឯង។ **លក្ខណៈធាតុចេញ៖** តើចំណេះ និងបំណិនអ្វីខ្លះដែលសិស្សទទួលបានពីមុខវិជ្ជាគោលក្នុងកម្មវិធីសិក្សា? តើអាកប្បកិរិយា និងឥរិយាបទបែបណាដែលសិស្សទទួលបានជាក់ស្តែង? តើលទ្ធផលនៃការប្រឡងថ្នាក់ជាតិមានប៉ុន្មានភាគរយ? តើមធ្យមពិន្ទុដែលទទួលបានតាមមុខវិជ្ជានីមួយៗ នៅពេលប្រឡងថ្នាក់ជាតិមានប៉ុន្មាន? **លក្ខណៈធាតុចូល៖ ១.គ្រូបង្រៀន៖** តើគ្រូបង្រៀនមានបទពិសោធន៍វិជ្ជាជីវៈជាមធ្យមប៉ុន្មានឆ្នាំនៅកម្រិតបឋមសិក្សា? តើមានគ្រូបង្រៀនជាស្ត្រីប៉ុន្មានភាគរយ? តើមានការលើកទឹកចិត្ត និងការប្តេជ្ញាចិត្ត ក្នុងការអនុវត្តការងារយ៉ាងដូចម្តេច? តើគ្រូបង្រៀនអវត្តមានកម្រិតណា? តើការពង្រាយគ្រូមានសមធម៌នៅទូទាំងរាជធានី-ខេត្ត និងតាមតំបន់នីមួយៗឬទេ? **២. កម្មវិធីសិក្សា៖** តើវិសាលភាពនៃវត្ថុបំណងកម្មវិធីសិក្សាឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរលើគោលនយោបាយសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់រាជធានី-ខេត្តកម្រិតណា? តើខ្លឹមសារ និងការរៀបចំកម្មវិធីសិក្សាត្រូវគ្នានឹងវត្ថុបំណងនិងលក្ខខណ្ឌជាក់ស្តែងនៃការសិក្សាដែរឬទេ? តើវិសាលភាពដែលកម្មវិធីសិក្សាអាចកែតម្រូវទៅតាមតម្លៃ ឬសិទ្ធិរបស់ក្រុមភាគតិចដែរឬទេ? **៣. សៀវភៅសិក្សា និងសម្ភារបង្រៀន៖** តើខ្លឹមសារនៃសៀវភៅសិក្សាឆ្លើយតប (ស៊ីគ្នា) ទៅនឹងកម្មវិធីសិក្សាឬទេ? តើសិស្សដែលមានសៀវភៅសិក្សាគោលមានប៉ុន្មាននាក់? តើគ្រូបង្រៀនដែលមានសៀវភៅគ្រូ និងសម្ភារឧបទេសផ្សេងៗទៀតមានប៉ុន្មាននាក់?

តើការផលិត និងចែកចាយសៀវភៅសិក្សាគោលត្រូវបានរៀបចំយ៉ាងដូចម្តេច? តើការបែងចែកសៀវភៅសិក្សាគោលនៅក្នុងរាជធានី-ខេត្តមានសមធម៌ដែរឬទេ? **៤. អគារសិក្សា សម្ភារបំពាក់ និងបរិក្ខារ៖** តើអគារសិក្សា និងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានមានស្ថានភាពបែបណា? តើមានថ្នាក់រៀនដែលបំពាក់ដោយបរិក្ខារប្រកបដោយស្តង់ដាមានប៉ុន្មាន? តើមានសិស្សដែលបានប្រើប្រាស់បណ្ណាល័យ ឬសម្ភារសិក្សាផ្សេងទៀត (ឧទាហរណ៍កុំព្យូទ័រ)មានប៉ុន្មាននាក់? តើសាលារៀនដែលបំពាក់បរិក្ខារបានល្អ ត្រូវបានបែងចែកប្រកបដោយសមធម៌ នៅតាមសាលារៀនក្នុងរាជធានី-ខេត្តទាំងមូលដែរឬទេ? **៥. លក្ខណៈនៃដំណើរការបង្រៀន និងរៀន៖** តើគ្រូបង្រៀនត្រូវបង្រៀនបែបណានៅក្នុងថ្នាក់រៀន? តើកិច្ចការផ្ទះ ការកែកិច្ចការ និងការផ្តល់ព័ត៌មានត្រឡប់ទៅសិស្សវិញ អនុវត្តយ៉ាងដូចម្តេច? តើគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាល និងការគាំទ្រគ្រប់គ្រាន់ក្នុងផ្នែកវាយតម្លៃសិស្សដែរឬទេ? តើការត្រួតពិនិត្យជំនាញវិជ្ជាជីវៈ រដ្ឋបាលរបស់គ្រូបង្រៀន និងសាលារៀនត្រូវរៀបចំយ៉ាងដូចម្តេច? តើគ្រូបង្រៀនទទួលបានការគាំទ្រពីអធិការអប់រំលើផ្នែកណាខ្លះ និងញឹកញាប់កម្រិតណា? តើអ្នកណាផ្សេងទៀតបានផ្តល់ការគាំទ្រផ្នែកគរុកោសល្យ? តើការដាក់ពិន្ទុលើការបង្រៀន និងរៀន មានសមធម៌នៅតាមរាជធានី-ខេត្តនីមួយៗ (ស្រុកខណ្ឌនីមួយៗ) ដែរឬទេ?

(៣) **លទ្ធភាពទទួលបានសេវាអប់រំ៖** នៅតាមបណ្តាប្រទេសភាគច្រើន ជាពិសេសស្ថិតនៅក្រោមឥទ្ធិពលចលនានៃការអប់រំសម្រាប់ទាំងអស់គ្នា (EFA) បានធ្វើឱ្យវាក្លាយជាអាទិភាព សម្រាប់ទសវត្សរ៍កន្លងមក ដើម្បីធានាឱ្យមានសិទ្ធិទទួលបានសេវាអប់រំ ដែលត្រូវបានចាត់ទុកថាជាសិទ្ធិមូលដ្ឋាន និងជាមធ្យោបាយនៃការអភិវឌ្ឍដ៏មានឥទ្ធិពល។ ជាលទ្ធផល ប្រទេសភាគច្រើនបានឈានដល់ការអប់រំជាសកលនៅកម្រិតបឋមសិក្សាបានតិច ឬច្រើន ហើយក៏បានដោះស្រាយបញ្ហាទាក់ទងនឹងការផ្តល់សេវាកម្មអប់រំ( យ៉ាងហោចណាស់នៅកម្រិតបឋមសិក្សា) រួមទាំងតាមរយៈគោលនយោបាយលុបបំបាត់ការបង់ថ្លៃសេវាសិក្សាផងដែរ។ ការផ្តល់សេវា និងការចូលរួមនៅតែជាបញ្ហាប្រឈមដំបូងសម្រាប់ប្រព័ន្ធអប់រំ។

ការទទួលបានការអប់រំ គឺដើម្បីវាស់វែងភាគរយនៃកុមារដែលមានអាយុចូលរៀន ថាពិតជាអាចចូលតាម(សេវាអប់រំ) កម្រិត ឬវដ្តនៃការអប់រំដែលបានផ្តល់ឱ្យ។ ការចូលរួមក្នុងការអប់រំ (ឬការគ្របដណ្តប់) កត់ត្រាកម្រិតនៃការចុះឈ្មោះនៅកម្រិតអប់រំមួយដែលបានផ្តល់ឱ្យ (បឋមសិក្សា និងអនុវិទ្យា

ល័យជាដើម)។ មានសំណួរសំខាន់ៗជាច្រើនដែលត្រូវសិក្សាស្រាវជ្រាវដើម្បីវាយតម្លៃស្ថានភាពជាក់ស្តែង និងបញ្ហានៃលទ្ធភាពទទួលបានការអប់រំកម្រិតណាមួយ ឬអនុវិស័យជាក់លាក់មួយនៃប្រព័ន្ធអប់រំ។ ការឆ្លើយសំណួរទាំងនេះនៅក្នុង ESD នឹងអនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រដែលពាក់ព័ន្ធ និងកំណត់ទិសដៅ និងគោលដៅនានាក្នុង ESP។ សំណួរទាំងនេះមានដូចខាងក្រោម៖ តើនរណាខ្លះត្រូវការការអប់រំនៅក្នុងរាជធានី-ខេត្ត និងសាលារៀននីមួយៗ? តើការអប់រំនោះមានទំហំប៉ុនណា? ហើយការអប់រំនោះសម្រាប់គោលបំណងអ្វី? តើមានកុមារដែលត្រូវការសេវាអប់រំប៉ុន្មាននាក់? តើមានកុមារទទួលបានសេវាអប់រំ (ចាប់ផ្តើមឆ្នាំទី១នៃការសិក្សា)ប៉ុន្មាននាក់? តើមានកុមារ យុវវ័យ និងមនុស្សដែលអាចធ្វើការបានប៉ុន្មាន? យុវវ័យដែលជាអាទិភាព (អតិថិជន) សម្រាប់សាលាដែលមានកម្រិតខុសគ្នា និងការអប់រំក្រៅសាលាមានចំនួនប៉ុន្មាន? តើកម្រិតអប្បបរមានៃការអប់រំដែលសង្គមត្រូវការសម្រាប់ជាសមាជិកម្នាក់ៗគឺជាអ្វី? តើអ្នកណាដែលពិតជាចង់ទទួលការអប់រំ? ហើយការអប់រំបែបណា? ក្នុងករណីធនធានដែលមានមិនអាចឆ្លើយតបទៅនឹងការទាមទារទាំងអស់នៃតម្រូវការ តើមានចំនួនប៉ុន្មានដែលគួរមានសិទ្ធិទទួលបានការអប់រំកម្រិតខុសគ្នា?

(៤) **ប្រសិទ្ធភាពផ្ទៃក្រៅ៖** ការវាយតម្លៃទៅលើប្រសិទ្ធភាពផ្ទៃក្រៅនៃការអប់រំមាននៅក្នុងការវាយតម្លៃទៅលើភាពពាក់ព័ន្ធនៃលទ្ធផលសិក្សាដែលទាក់ទងទៅនឹងតម្រូវការទីផ្សារ សេដ្ឋកិច្ច និងសង្គមទាំងមូល។ ឧទាហរណ៍មួយចំនួននៃសំណួរសំខាន់ៗដែលត្រូវលើកឡើងរួមមាន៖ តើសិស្សដែលបានបញ្ចប់ការសិក្សាពីសាលារៀនទៅរកការងារធ្វើបានដល់កម្រិតណាទាំងវិស័យរដ្ឋ និងវិស័យឯកជន? តើជំនាញ និងសមត្ថភាពដែលទទួលបានត្រូវនឹងអ្វីដែលនិយោជកត្រូវការក្នុងវិស័យផ្សេងៗនៃសេដ្ឋកិច្ចដែរឬទេ? តើចំណេះដឹង និងជំនាញដែលទទួលបាននៅសាលាមានប្រយោជន៍អ្វីខ្លះ សម្រាប់ការកែលម្អឥរិយាបថ និងទម្លាប់របស់សិស្សដោយស្របទៅនឹងការការពារសុខភាពអាហារូបត្ថម្ភ និងបំណិនជីវិតផ្សេងទៀត?

ការឆ្លើយសំណួរទាំងនេះគឺចាំបាច់សម្រាប់ការកំណត់និយមន័យ ឬការកំណត់ឡើងវិញនូវគោលនយោបាយអភិវឌ្ឍធនធានមនុស្ស។ ប៉ុន្តែការផ្សារភ្ជាប់គ្នារវាងការអភិវឌ្ឍសង្គម និងការអប់រំគឺ

ស្មុគស្មាញណាស់។ ទោះជាយ៉ាងដូច្នេះក្ដី ហេតុវិនិច្ឆ័យវិស័យអប់រំគួរតែមានគោលបំណងផ្ដល់ជូនអ្នកបង្កើតគោលនយោបាយ និងអ្នកគ្រប់គ្រងប្រព័ន្ធនូវព័ត៌មានដែលពាក់ព័ន្ធ ស្ដីពីភាពគ្រប់គ្រាន់រវាង "ផលិតផល" នៃប្រព័ន្ធអប់រំ និងគោលដៅសេដ្ឋកិច្ច និងមជ្ឈដ្ឋានរបស់ប្រទេស និងរាជធានី-ខេត្ត។ នេះបញ្ជាក់ពីការសំយោគលទ្ធផលពីការសិក្សាដែលបានអនុវត្តរួចហើយ និងបើចាំបាច់ត្រូវធ្វើការស្ទង់មតិនៅក្នុងតំបន់នេះ។

(៥)**ប្រសិទ្ធភាពផ្ទៃក្នុង៖** ប្រការសំខាន់ អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងប្រព័ន្ធត្រូវដឹងពីចំនួនសិស្សចុះឈ្មោះចូលរៀនដែលពិតជាបានបញ្ចប់វគ្គអប់រំមួយ ឬទទួលបានសញ្ញាបត្រក្នុងរយៈពេលកំណត់ផ្លូវការ។ ស្ថានភាពដ៏ល្អបំផុត គឺករណីដែលសិស្សទាំងអស់ចាប់ផ្ដើមចូលរៀនក្នុងថ្នាក់ជាក់លាក់ បានបញ្ចប់ថ្នាក់នោះក្នុងចំនួនឆ្នាំសិក្សារំពឹងទុក ពោលគឺមិនមានសិស្សរៀនត្រួតថ្នាក់ឬបោះបង់ការសិក្សា។ ESD នឹងផ្ដល់នូវចម្លើយតាមលំដាប់លំដោយទៅកាន់សំណួរចំនួនពីរគឺ៖ តើសិស្សដែលចូលក្នុងប្រព័ន្ធអប់រំពិតជាបានប្រឡងជាប់ និងបញ្ចប់ការសិក្សារបស់ខ្លួនដល់កម្រិតណា? ហើយតើពួកគេរីកចម្រើនយ៉ាងដូចម្ដេចតាមរយៈវគ្គអប់រំមួយឬក្នុងកម្រិតមួយនៃប្រព័ន្ធអប់រំ? តើត្រូវមានធនធានចាំបាច់អ្វីខ្លះដើម្បីអាចឱ្យសិស្សម្នាក់បញ្ចប់ការសិក្សាបាន?

គោលគំនិតនៃ"ភាពគ្មានប្រសិទ្ធភាពផ្ទៃក្នុង" គឺពិតជាមានលក្ខណៈរឹតត្បិតខ្លាំងណាស់ ដូច្នេះការធ្វើដដែលៗ និងការបោះបង់ការសិក្សាគឺមិនមែនគ្រាន់តែជារោគសញ្ញា និងមូលហេតុនៃ "ភាពគ្មានប្រសិទ្ធភាពផ្ទៃក្នុង" និង "ការខ្ជះខ្ជាយ" ដែលមានលក្ខណៈជាប្រព័ន្ធអប់រំនោះទេ។ កត្តាផ្សេងទៀតដែលត្រូវយកមកពិចារណានៅក្នុង ESD គឺ៖ធនធានមិនគ្រប់គ្រាន់ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ការអប់រំ ការចែកចាយធនធានមនុស្ស និងធនធានសម្ភារមិនស្មើគ្នា អវត្តមានរបស់គ្រូ និងកង្វះអាហារូបត្ថម្ភជាដើម។ ចំណុចមួយទៀតដែលគួរតែប្រុងប្រយ័ត្នគឺការកំណត់សេចក្ដីសន្និដ្ឋាន(ការបកស្រាយ)ពីសូចនាករប្រសិទ្ធភាពផ្ទៃក្នុងដូចជាអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ជាដើម ព្រោះការបោះបង់ការសិក្សា ក៏អាចបណ្ដាលមកពីកត្តាដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងការផ្គត់ផ្គង់សេវាអប់រំផងដែរ។ ឧទាហរណ៍ដូចជាការឆាប់រៀបការសម្រាប់ក្មេងស្រី ឬភាពចាំបាច់ដើម្បីជួយធ្វើការងារគ្រួសារ (នៅពេលជាក់លាក់ក្នុងមួយ

ឆ្នាំសម្រាប់កសិកម្ម) ក៏បង្កើតឱ្យមានការបោះបង់ការសិក្សាផងដែរ ប៉ុន្តែមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រព័ន្ធអប់រំទេ។ ខាងក្រោមផ្នែកប្រសិទ្ធភាពផ្ទៃក្នុង ESD នឹងធ្វើឱ្យបាននូវៈ វិភាគពីវិសាលភាពដែលសិស្សចូលក្នុងវដ្ត ឬប្រភេទនៃការអប់រំមានការរីកចម្រើនជាប្រចាំតាមរយៈប្រព័ន្ធអប់រំ និងផលប៉ះពាល់នៃតម្លៃ ដំណើការរបស់ពួកគេ។ ការវិភាគពីភាពប្រែប្រួលនៃលំហូររបស់សិស្សៈ ការឆ្លងថ្នាក់របស់ពួកគេពីកម្រិតមួយឬអនុវិស័យមួយ ទៅកម្រិតមួយ ឬអនុវិស័យមួយទៀត គឺជាការវាស់ស្ទង់នូវអត្រាបោះបង់ការសិក្សា និងអត្រារៀនត្រួតថ្នាក់។ ការវិភាគពេលវេលា និងធនធានដែលត្រូវការដើម្បីដកសិស្សដែលបានបញ្ចប់ការសិក្សាចេញពីប្រព័ន្ធអប់រំនៅកម្រិតខុសគ្នា។

សូចនាករដែលត្រូវបានប្រើជាទូទៅបំផុត ដើម្បីវាស់ស្ទង់ប្រសិទ្ធភាពផ្ទៃក្នុងមានដូចខាងក្រោមៈ អត្រាត្រួតថ្នាក់ អត្រាឡើងថ្នាក់ និងអត្រាបោះបង់ការសិក្សា ភាគរយនៃការត្រួតថ្នាក់ អាយុកាលសិក្សា អត្រាឡើងថ្នាក់ពីមួយថ្នាក់ទៅមួយថ្នាក់ អត្រាឆ្លងភូមិសិក្សាពីមួយកម្រិត ឬមួយវដ្ត ទៅកម្រិតបន្ទាប់។ អត្រាគង់វង់តាមថ្នាក់ ចំនួនបង្កើនប្រសិទ្ធភាព ឆ្នាំចូលរៀន ធៀបនឹងសិស្សបញ្ចប់ការសិក្សា អត្រារួមនៃការចូលរៀនថ្មី នៅក្នុងថ្នាក់ចុងក្រោយនៃការអប់រំបឋមសិក្សា ផលធៀបនៃសិស្សបោះបង់។ ការវិភាគជាក់ស្តែងលើប្រសិទ្ធភាពផ្ទៃក្នុងនៅក្នុងរាជធានី-ខេត្ត សូចនាករសំខាន់ៗដែលត្រូវបានប្រើដើម្បីវិភាគប្រសិទ្ធភាពផ្ទៃក្នុងគឺអត្រាត្រួតថ្នាក់ អត្រាបោះបង់ការសិក្សា និងអត្រាឡើងថ្នាក់។ ប្រើសំណួរណែនាំខាងក្រោមដើម្បីធ្វើការវិភាគទៅលើប្រសិទ្ធភាពផ្ទៃក្នុងនៅរាជធានី-ខេត្តៈ តើមានសិស្សត្រួតថ្នាក់ប៉ុន្មាននាក់? តើមានសិស្សបោះបង់ការសិក្សាប៉ុន្មាននាក់? តើមានសិស្សឡើងថ្នាក់បន្ទាប់ប៉ុន្មាននាក់?តើមានធនធានប៉ុន្មានដែលត្រូវបានចំណាយដើម្បីនាំចំនួនសិស្សចូលរៀនដល់កម្រិតនៃការអប់រំពិតប្រាកដ?

(៦) **ការចំណាយ និងហិរញ្ញប្បទានៈ** ការវិភាគការចំណាយ និងហិរញ្ញប្បទានក្នុង ESD មិនត្រូវបានកំណត់ត្រឹមតែរបាយការណ៍គណនីនោះទេ។ វាក៏តម្រូវឱ្យពិនិត្យលើនីតិវិធីដែលបានប្រើសម្រាប់ការរៀបចំថវិកា ការប្តេជ្ញាចិត្តក្នុងការចំណាយ ការធ្វើរបាយការណ៍ និងការត្រួតពិនិត្យផងដែរ។ លើសពីនេះទៀត វារួមបញ្ចូលទាំងការពិនិត្យឡើងវិញនៃប្រភពរបស់ហិរញ្ញប្បទានអប់រំ និងការវាយតម្លៃពីលទ្ធភាពនៃការបង្កើនធនធានដែលមាន សម្រាប់ការអប់រំ។ សំណួរជាមូលដ្ឋានស្តីពីការចំណាយ និង

ហិរញ្ញប្បទានរួមមាន៖ តើមានការចំណាយប៉ុន្មានសម្រាប់ការអប់រំក្នុងមួយឆ្នាំ? តើការចំណាយលើការអប់រំបានវិវត្តយ៉ាងដូចម្តេចក្នុងរយៈពេល១០ ឆ្នាំចុងក្រោយនេះ? តើប្រភពថវិកាសំខាន់ៗមានអ្វីខ្លះ? តើប្រព័ន្ធហិរញ្ញប្បទានការអប់រំមានលក្ខណៈកាន់តែមិនអាចទទួលយកបាន ឬកាត់បន្ថយវិសមភាពសង្គមដែរឬទេ? តើការគ្រប់គ្រងធនធានបច្ចុប្បន្នមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិដល់កម្រិតណា? តើធ្វើដូចម្តេចដើម្បីកាត់បន្ថយចំណាយលើការអប់រំ? តើធ្វើដូចម្តេចដើម្បីកៀរគរធនធានបន្ថែមសម្រាប់ការអប់រំ?

ការវិភាគការចំណាយនៃការអប់រំហាក់ដូចជាគួរឱ្យធុញទ្រាន់ ជាពិសេសដល់អ្នកអប់រំទាំងអស់ គឺតែងតែដឹងអំពីការប្រើប្រាស់ធនធាននាពេលបច្ចុប្បន្ន និងមានសមត្ថភាពដែលអាចវិនិច្ឆ័យថាតើការបែងចែកមូលនិធិក្នុងចំណោមកម្រិត និងប្រភេទនៃការអប់រំ គឺត្រឹមត្រូវ សមធម៌ និងសមហេតុផល។ ទន្ទឹមនឹងនេះដែរ វាមានតម្រូវការមុនសម្រាប់ការសិក្សាពីលទ្ធភាពនៃការកែទម្រង់ដែលបានស្នើឡើង។ នៅចុងបញ្ចប់ការសិក្សាអំពីការចំណាយលើការអប់រំជាក់ស្តែង និងការបែងចែកធនធាន គឺជាវិធីមួយដើម្បីផ្ទៀងផ្ទាត់ថាតើគោលនយោបាយមួយត្រូវបានអនុវត្តនៅក្នុងការអនុវត្តជាក់ស្តែង ឬយ៉ាងណា។

(៧)**សមធម៌៖** ភាពខុសគ្នានៃការអប់រំតែងតែកើតមានរវាងក្មេងស្រី និងក្មេងប្រុស រវាងកុមាររស់នៅក្នុងតំបន់ភូមិសាស្ត្រផ្សេងគ្នា និងមកពីក្រុមសេដ្ឋកិច្ចសង្គម ឬវប្បធម៌ផ្សេងៗគ្នាជាដើម។ វិសមភាពរវាងកុមារគឺមិនត្រូវបានកំណត់ចំពោះការទទួលបានសេវាអប់រំនោះទេ ប៉ុន្តែអាចត្រូវបានរកឃើញទាក់ទងទៅនឹងប្រសិទ្ធភាពផ្ទៃក្នុង។ ឧទាហរណ៍ ការត្រួតថ្នាក់ និងការបញ្ចប់ការសិក្សាឆាប់ មានជាញឹកញាប់ក្នុងចំណោមក្មេងស្រី និងសិស្សនៅតាមតំបន់ជនបទ និងទាក់ទងទៅនឹងគុណភាពនៃការផ្តល់ជូនសេវាអប់រំ។ ខាងក្រោមនេះគឺជាសំណួរសំខាន់ៗដែលត្រូវដោះស្រាយ៖ តើមានវិសមភាពអ្វីដែលទាក់ទងនឹងការទទួលបានសេវាអបរំ និងការសម្រេចចិត្តក្នុងការផ្តល់សេវាអប់រំរបស់ក្រុមផ្សេងៗគ្នានៅគ្រប់កម្រិត និងគ្រប់អនុ វិស័យនៃការអប់រំ? តើភាពខុសគ្នាទាំងនេះ អាចត្រូវបានពន្យល់ដោយគុណភាពនៃការផ្គត់ផ្គង់សេវាអប់រំមិនស្មើគ្នា (ទាក់ទងនឹងគ្រូកិច្ចសន្យា គ្រូបណ្តាញជំនួយគរុកោសល្យ សៀវភៅសិក្សាគោល អគារសាលារៀនជាដើម)ឬទេ? តើបញ្ហាដែលបានអង្កេតឃើញនៃការផ្តល់សេវាអប់រំ ដំណើរការវឌ្ឍនភាព និងលទ្ធផលសម្រេចបានរបស់ក្រុមមួយចំនួនដោយសារកត្តាវប្បធម៌ ឬសេដ្ឋកិច្ចសង្គមដែរ

ឬទេ? តើបញ្ហាទាំងនេះអាចត្រូវបានដោះស្រាយយ៉ាងដូចម្ដេច? តើបញ្ហាទាំងនេះមានឥទ្ធិពលអ្វីខ្លះពីយុទ្ធសាស្ត្រកន្លងមក សម្រាប់ជួយធ្វើការសម្រួលដល់ក្រុមដែលមិនទទួលបានជោគជ័យក្នុងសង្គម? តើមានភាពខុសគ្នាអ្វីខ្លះរវាងកុមារា និងកុមារី រវាងតំបន់ទីក្រុង និងជនបទ ក្នុងចំណោមតំបន់ផ្សេងៗ និងក្រុម ឬប្រភេទប្រជាជនផ្សេងៗ (ដូចជា គិតតាមប្រាក់ចំណូល សហគមន៍បម្លាស់ទី និងសហគមន៍ម្ចាស់ស្រុក)? ពាក់ព័ន្ធនឹង៖ លទ្ធភាពទទួលបានសេវាអប់រំ ការវិវឌ្ឍក្នុងប្រព័ន្ធអប់រំ និងលទ្ធផលអប់រំ គុណភាពនៃការអប់រំដែលទទួលបាន និងការគាំទ្រផ្នែកសេដ្ឋកិច្ចដែលទទួលបានសម្រាប់ការសិក្សា។ តើក្រុម ឬប្រភេទប្រជាជនណាដែលមានសមាសភាគតិចបំផុត ក្នុងចំណោមសិស្សដែលបានបញ្ចប់ការសិក្សាមូលដ្ឋាន និងក្នុងចំណោមសិស្សដែលបានចុះឈ្មោះចូលរៀនក្នុងការអប់រំកម្រិតក្រោយមធ្យមសិក្សា? តើក្រុមណាដែលទទួលរងផលប៉ះពាល់ខ្លាំងបំផុតពីអនក្ខរភាព? (ដូចជា កុមារី កុមារដែលរស់នៅក្នុងគ្រួសារក្រីក្រក្នុងតំបន់ទីក្រុង ក្រុមជនជាតិវប្បធម៌ភាគតិច)។ តើអ្វីខ្លះជាដើមហេតុបង្កជាអសមធម៌ដែលបានលើកឡើង? តើអសមធម៌ទាំងនោះផ្សារភ្ជាប់នឹងភាពខុសគ្នាលើ "តម្រូវការអប់រំក្នុងសង្គម" (ពាក់ព័ន្ធនឹងប្រាក់ចំណូល និងភាពក្រីក្រក្នុងចំណោមក្រុមគ្រួសារ) ឬផ្សារភ្ជាប់នឹង "ឧបសគ្គហេដ្ឋារចនាសម្ព័ន្ធ" ដែលពាក់ព័ន្ធនឹងការផ្ដល់សេវាអប់រំក្នុងកម្រិតណា? (ដូចជា ការខ្វះខាតសាលាមធ្យមសិក្សា ក្នុងតំបន់ជនបទ ឬការខូចខាតហេដ្ឋារចនាសម្ព័ន្ធដែលបង្កឡើងដោយគ្រោះមហន្តរាយ) តើគោលនយោបាយ និងវិធានការណាខ្លះដែលអាចជួយកាត់បន្ថយអសមធម៌ទាំងនេះ?

(៨) **ការគ្រប់គ្រងអប់រំ៖** នៅក្នុង ESD មានវិធីជាច្រើនដែលអាចអនុវត្តបានដើម្បីវាយតម្លៃភាពខ្លាំង និងភាពខ្សោយនៃការគ្រប់គ្រងការអប់រំ។ វិធីសាស្ត្រមួយគឺធ្វើសវនកម្ម ឬការវិភាគតាមអង្គភាព ដោយធ្វើការស៊ើបអង្កេតលើមុខងារធំៗចំនួន៤ ឬកម្រិតនៃការគ្រប់គ្រងដូចខាងក្រោម៖ (១)មុខងារជាយុទ្ធសាស្ត្រ៖ តើនរណាជាអ្នកទទួលបន្ទុកលើការធ្វើគោលនយោបាយ? តើអ្នកណាជាអ្នករៀបចំផែនការអភិវឌ្ឍ និងថវិកា? តើអ្នកពាក់ព័ន្ធណាខ្លះចូលរួមក្នុងដំណើរការនេះ? តើផែនការ និងថវិកាមានភាពស៊ីគ្នាហើយឬនៅ? ហើយតើពួកគេបានចូលរួមក្នុងការសម្រេចបាននូវគោលនយោបាយអប់រំចម្បងៗដែរឬទេ? (២)តួនាទី៖ តើច្បាប់ និងបទបញ្ញត្តិអ្វីខ្លះដែលកើតមាន? តើប្រព័ន្ធអប់រំដំណើរការបានពេញ

លេញចំពោះច្បាប់ និងបទបញ្ញត្តិដែរឬទេ? បើមិនដូច្នោះទេតើវាបង្វែរទៅទីណា? (៣)មុខងារព័ត៌មានៈ តើនរណាជាអ្នកទទួលខុសត្រូវក្នុងការប្រមូលទិន្នន័យ? តើទិន្នន័យត្រូវបានដំណើរការ និងរក្សាទុកយ៉ាងដូចម្តេច? តើទិន្នន័យចែកចាយយ៉ាងដូចម្តេចទៅអ្នកដែលត្រូវការទិន្នន័យសម្រាប់ធ្វើការសម្រេចចិត្ត? (៤)តួនាទីនៃអ្នកប្រតិបត្តិៈ តើនរណាជាអ្នកពិនិត្យតាមដាន និងគាំទ្រការអនុវត្តគោលនយោបាយអប់រំនៅថ្នាក់មូលដ្ឋាន? តើពួកគេមានសមត្ថភាពចាំបាច់ទេ? តើពួកគេមានសិទ្ធិអំណាចចាំបាច់ទេ? ការគ្រប់គ្រងធនធានមនុស្សជាពិសេសគ្រូគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទាំងការវិនិយោគ និងលទ្ធផលនៃការអប់រំ ដូច្នេះហើយបានទាក់ទាញការយកចិត្តទុកដាក់ជាពិសេសនៅក្នុង ESD ថ្មីៗនេះ។

**ជំហានទី២៖ អាទិភាពគោលនយោបាយយុទ្ធសាស្រ្តគន្លឹះ និងចំណុចដៅផែនការ**

ការឯកភាព គឺជាការចាំបាច់លើ (១) ការតម្រង់ទិស និងគោលដៅគោលនយោបាយរយៈពេលយូរ និងទូលំទូលាយ (២) អាទិភាពមានដែនកំណត់ និង(៣) យុទ្ធសាស្រ្តសំខាន់ៗ សម្រាប់សម្រេចបានគោលដៅ។ ការធ្វើហេតុវិនិច្ឆ័យ បានរកឃើញនូវបញ្ហាប្រឈមធំៗជាច្រើន។ អាទិភាពគោលនយោបាយ គួរតែភ្ជាប់ទៅនឹងបញ្ហាប្រឈមទាំងនោះ។ ការកំណត់ការងារអាទិភាព គឺជាលទ្ធផលនៃការសន្ទនារវាងទស្សនៈនយោបាយ និងទស្សនៈបច្ចេកទេស។ ការពិភាក្សាគោលនយោបាយសាធារណៈអាចជួយបំភ្លឺបញ្ហាធ្ងន់ធ្ងរមួយចំនួនដើម្បីកំណត់យុទ្ធសាស្រ្ត និងចំណុចដៅជាក់លាក់ គួរអនុវត្តដូចខាងក្រោម៖

បង្កើតការធ្វើចំណោលអប់រំ និងគំរូព្យាករណ៍ហិរញ្ញវត្ថុ។ ការធ្វើបែបនេះ និងចង្អុលបង្ហាញពីលទ្ធភាព និងការចំណាយថវិកា ដើម្បីឈានទៅដល់ចំណុចដៅ និងអនុញ្ញាតឱ្យអ្នកធ្វើការសម្រេចចិត្ត អាចរុករកនូវសេណារីយ៉ូហិរញ្ញវត្ថុច្រើនជម្រើស។ ប៉ារ៉ាម៉ែត្រមូលដ្ឋានជាច្រើននៅក្នុងគំរូនេះ រួមមានចំណោលប្រជាជន សូចនាករអតិវឌ្ឍសេដ្ឋកិច្ច សូចនាករហិរញ្ញវត្ថុ (ឧទាហរណ៍ ភាគហ៊ុនអប់រំ ក្នុងថវិកាជាតិតម្លៃឯកតា) និងប៉ារ៉ាម៉ែត្រអប់រំ (ដូចជា ទំហំថ្នាក់រៀន ផលធៀបគ្រូសិស្ស ផលធៀបសិស្ស និងសៀវភៅសិក្សាប្រាក់បៀវត្ស និងរង្វាន់លើកទឹកចិត្តនៅជនបទ)។

វិភាគអ្នកពាក់ព័ន្ធ៖ ការស្គាល់អ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងវិស័យអប់រំ ព្រមទាំងចំណុចខ្លាំង និងបទពិសោធន៍របស់ពួកគេគឺជាចំណុចសំខាន់ណាស់ក្នុងការរៀបចំផែនការ។ ការវិភាគអាចបំភ្លឺនូវកម្មវិធី

ដែលត្រូវសម្របសម្រួលទៅនឹងការរំពឹងទុករបស់អ្នកពាក់ព័ន្ធទាំងអស់។

ជម្រើសអាទិភាពគោលនយោបាយនឹងជះឥទ្ធិពលដល់អាទិភាពនៃការអភិវឌ្ឍសង្គម និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលលើកិច្ចការអន្តរជាតិ។ ប្រទេសភាគច្រើនរួមទាំងប្រទេសកម្ពុជា បានប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍសហសវត្សរ៍លើវិស័យអប់រំ ព្រមទាំងគោលដៅ និងចំណុចដៅការអប់រំសម្រាប់ទាំងអស់គ្នាទាំង៦ចំណុច។ អាទិភាពគោលនយោបាយត្រូវមានចំណុចដៅជាក់លាក់ និងប្រែក្លាយអាទិភាពទាំងអស់នោះឱ្យទៅជាយុទ្ធសាស្ត្រគន្លឹះ។ នៅជំហាននេះអាទិភាពគោលនយោបាយទាំងនេះត្រូវមានលក្ខណៈទូទៅ។

**ជំហានទី៣៖ ការសរសេរកម្មវិធី**

អាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រត្រូវប្រែក្លាយឱ្យទៅជាកម្មវិធីអាទិភាព។ កម្មវិធីអាទិភាពនីមួយៗគួរមានចំណុចដៅ និងលទ្ធផលជាក់លាក់ហើយប្រសិនបើអាចធ្វើទៅបានត្រូវតែធ្វើឱ្យទៅជាសកម្មភាពគន្លឹះជាមួយនឹងចំណុចដៅសកម្មភាព។ មានវិធីជាច្រើនក្នុងការបង្កើតយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រមានសមាសភាពដូចខាងក្រោម៖ គោលដៅ វត្ថុបំណងទូទៅ (ឧទាហរណ៍ ការបង្កើនការចូលរៀននៅមត្តេយ្យសិក្សា) ចំណុចដៅ ឬគោលបំណងជាក់លាក់ (ឧទាហរណ៍ លើកកម្ពស់ការចូលរៀននៅមត្តេយ្យសិក្សា ពី ២៥% ទៅ ៤០%) កម្មវិធី (ឧទាហរណ៍ បង្កើតគោលនយោបាយអប់រំនៅមត្តេយ្យសិក្សា ការបណ្តុះបណ្តាលគ្រូបង្រៀន) សកម្មភាព (ឧទាហរណ៍ សិក្ខាសាលាសំខាន់មួយដើម្បីបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន)។ បន្ទាប់ពីចំណុចដៅទាំងអស់ត្រូវបានបង្កើតរួចរាល់ (សម្រាប់អនុវិស័យទាំងអស់) សកម្មភាពគន្លឹះត្រូវបានគូសបញ្ជាក់ ការពិនិត្យលទ្ធភាពអាចណែនាំនូវសំណួរដូចខាងក្រោម៖ តើតម្លៃដែលបានប៉ាន់ប្រមាណស៊ីគ្នាទៅនឹងធនធានហិរញ្ញវត្ថុដែលបានរំពឹងទុកដែរឬទេ? តើវត្ថុបំណង និងសកម្មភាពជាអាទិភាពស៊ីគ្នាដែរឬទេ? ការពិនិត្យលទ្ធភាពអាចឈានទៅដល់ការវាយតម្លៃអាទិភាព និងជម្រើសយុទ្ធសាស្ត្រនានា។ អ្នកពាក់ព័ន្ធគួរតែចូលរួមនៅក្នុងជំហាននេះតាមរយៈការចូលរួមផ្នែកបច្ចេកទេស ក្នុងក្រុមការងារ ឬវេទិកាសម្ព័ន្ធសមរម្យដទៃទៀត។ នៅចុងបញ្ចប់នៃជំហាននេះដំណើរការពិគ្រោះយោបល់ទូលំទូលាយគួរត្រូវបានធ្វើឡើងដើម្បីទាញយកនូវមតិ និងអនុសាសន៍ចុងក្រោយពីអ្នកពាក់ព័ន្ធ។

### ជំហានទី៤៖ ការរៀបចំការអនុវត្ត និងសមត្ថភាព

ជំហានបន្ទាប់ក្នុងការរៀបចំផែនការយុទ្ធសាស្រ្តអប់រំរួមមានការកំណត់រៀបចំការអនុវត្ត និងការធានាឱ្យប្រាកដថាសមត្ថភាពចាំបាច់គឺមាន។ ផែនការសកម្មភាពលម្អិតជាងនេះនឹងកើតមានឡើង នៅពេលផែនការយុទ្ធសាស្រ្តវិស័យអប់រំត្រូវបានកំណត់តម្លៃ។ ការរៀបចំដំណើរការអនុវត្ត៖ សំណួរជាគន្លឹះនៅទីនេះគឺអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការអនុវត្តផែនការ និងអ្នកណាទទួលខុសត្រូវចំពោះកម្មវិធីជាក់លាក់។ ការទទួលខុសត្រូវទាមទារឱ្យមានការកំណត់ច្បាស់លាស់។ វាប្រហាក់ប្រហែលគ្នាទៅនឹងការទទួលខុសត្រូវរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ អង្គការលេខជួយបង្ហាញពីរចនាសម្ព័ន្ធទូទៅ និងខ្សែបន្ទាត់អំណាច។ អង្គការលេខគួរតែស៊ីគ្នាជាមួយអង្គការលេខរបស់មន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត។ ការបង្កើតអង្គការលេខថ្មី៖ គឺចាំបាច់ក្នុងករណីដំណើរការរៀបចំផែនការគណៈកម្មការទទួលខុសត្រូវរួមនឹងទទួលបន្ទុកក្នុងការទទួលខុសត្រូវអនុវត្ត និងឃ្លាំមើលការអនុវត្តនៅកម្រិតគោលនយោបាយ ផ្ទុយមកវិញក្រុមតាមដានយុទ្ធសាស្រ្តនឹងសម្របសម្រួលដល់ការងារប្រតិបត្តិប្រចាំថ្ងៃ។ សមត្ថភាពប្រតិបត្តិ៖ សមត្ថភាពរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តក្នុងការអនុវត្តផែនការគឺពឹងផ្អែកទៅលើកត្តាមួយចំនួន ព្រោះអ្វីៗទាំងអស់មិនមែនសុទ្ធតែស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តនោះទេ។ កត្តាខ្លះគឺជាលទ្ធផលនៃគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។ ការវិភាគសមត្ថភាពសម្រាប់ការអនុវត្តផែនការទាមទារឱ្យពិនិត្យមើលនូវចំណុចដូចខាងក្រោម៖ ការគ្រប់គ្រងស្ថាប័នរដ្ឋ៖ ត្រូវវិភាគគុណភាពគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ប្រសិទ្ធភាពនៃការកៀរគររកប្រាក់ចំណូល គុណភាពរដ្ឋបាលសាធារណៈ ការគ្រប់គ្រងមន្ត្រីរាជការ តម្លាភាព និងការទទួលខុសត្រូវក្នុងវិស័យសាធារណៈ។ ប្រសិទ្ធភាពរដ្ឋបាលអប់រំ៖ ត្រូវវិភាគទៅលើការកំណត់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ ការតភ្ជាប់គ្នារវាងតួនាទី និងរចនាសម្ព័ន្ធ ការប្រាស្រ័យទាក់ទង និងការសម្របសម្រួល និងការតាមដាន និងវាយតម្លៃ។ សមត្ថភាពមន្ត្រីអប់រំ៖ ត្រូវវិភាគទៅលើកម្រិតវប្បធម៌ បំណិន ការបណ្តុះបណ្តាល និងប័ណ្ណសរសើរ។

## ជំហានទី៥៖ ការកំណត់តម្លៃ និងការផ្តល់ហិរញ្ញវត្ថុដល់ផែនការសកម្មភាព

ការកំណត់តម្លៃនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវបានគេពិនិត្យមើលជាទៀងទាត់ ក្នុងអំឡុងពេលនៃការរៀបចំផែនការដោយប្រើប្រាស់ចំណោល និងគំរូព្យាករណ៍ហិរញ្ញវត្ថុ។ ការប៉ាន់ស្មានតម្លៃអាចនាំទៅដល់ការគិតឡើងវិញ និងការផ្លាស់ប្តូរចំណុចដៅ និងកម្មវិធីនៃផែនការ។ ការកំណត់តម្លៃនៃផែនការអប់រំពឹងផ្អែកលើកត្តាដូចតទៅ៖ វត្ថុបំណងនៃគោលនយោបាយដោយប្រែក្លាយឱ្យទៅជាចំណុចដៅ។ វត្ថុបំណងទាំងអស់នេះពាក់ព័ន្ធទៅដល់អត្រាចូលរៀន និងផលធៀបប្រសិទ្ធភាពខាងក្រៅ (ឧទាហរណ៍ បង្កើនការចូលរៀនរបស់កុមារតូចត្រឹម២០% ឬបង្កើនអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សា ទៅមធ្យមសិក្សាឱ្យដល់៩០%)។ ចំណុចដៅទាំងនេះនឹងរាប់បញ្ចូលទៅក្នុងសូចនាករគុណភាព (ឧទាហរណ៍ បង្កើនគ្រូមធ្យមសិក្សាដែលទទួលបានការបណ្តុះបណ្តាលឱ្យដល់៩០%)។ ការសន្មត់ការប្រើប្រាស់ធនធាន៖ ឧទាហរណ៍ ផលធៀបសៀវភៅក្នុងសិស្សម្នាក់ ផលធៀបសិស្សក្នុងមួយថ្នាក់ ចំនួនសិស្សរៀនពីរវេន។ ការសន្មត់មុខតម្លៃ៖ ឧទាហរណ៍ ប្រាក់ខែគ្រូបង្រៀន ការចំណាយថវិកាក្នុងថ្នាក់រៀនមួយ។ ការសន្មត់គួរត្រូវបានធ្វើជាពិសេសដើម្បីឱ្យការប៉ាន់ប្រមាណពីតម្លៃងាយគណនា ដោយប្រើប្រាស់ចំណុចដៅ និងការសន្មត់ទាំងនេះ។ ការប៉ាន់ស្មានតម្លៃសរុបអាចត្រូវបានបំបែកជាជំពូកតូចៗ។ វាមានសារប្រយោជន៍ប្រសិនបើរចនាសម្ព័ន្ធចំណាយនៃផែនការអាចត្រូវបានគេកំណត់ស្របជាមួយរចនាសម្ព័ន្ធថវិកាជាតិពីព្រោះវាអាចភ្ជាប់ទៅនឹងក្របខ័ណ្ឌប្រាក់ចំណាយរយៈពេលមធ្យម។ ការផ្តល់ហិរញ្ញវត្ថុនៃផែនការ៖ ធនធានដែលមានគួរតែត្រូវបានគេពិចារណានៅពេលអភិវឌ្ឍផែនការ។ ប្រសិនបើគម្លាតនៃការផ្តល់មូលនិធិនៅតែមានរវាងតម្លៃផែនការ និងថវិការំពឹងទុកចំពោះធនធានក្នុងស្រុក និងក្រៅស្រុកយុទ្ធសាស្ត្រទាំងនោះគួរត្រូវពិនិត្យមើលឡើងវិញ។ វិភាគទានរបស់សមាជិកគ្រួសារមិនគួរពឹងផ្អែកទាំងស្រុងដើម្បីធ្វើជាប្រភពថវិកាសម្រាប់វិស័យអប់រំទេ។ គម្លាតនៃការផ្តល់មូលនិធិត្រូវបានគណនាតាមរយៈការរកឱ្យឃើញនូវភាពខុសប្លែកគ្នារវាងតម្លៃនៃផែនការ និងប្រភពធនធានសំខាន់ក្នុងស្រុកសម្រាប់វិស័យអប់រំ។ ការពិនិត្យមើលការផ្តល់មូលនិធិឡើងវិញដោយដៃគូអភិវឌ្ឍគួរត្រូវធ្វើឡើងទោះបីជាមានប្រភពមកពីការគាំទ្រថវិកាទូទៅ ឬតាមវិស័យក៏ដោយសម្រាប់សកម្មភាពដែលបានជ្រើសរើសហើយ។ គម្លាតដែលនៅសេសសល់ប្រសិនបើមានតំណាងឱ្យការ

គាំទ្របន្ថែមដែលត្រូវតែស្វែងរក។ ប្រសិនបើគម្លាតនៃការផ្តល់មូលនិធិធំពេកយុទ្ធសាស្ត្រទាំងអស់ត្រូវតែពិនិត្យមើលឡើងវិញ ដើម្បីឈានទៅរកកម្រិតសមស្របមួយ។ ប្រហែលជាមានឱកាសក្នុងការស្វែងរកយុទ្ធសាស្ត្រអនុវត្តថវិកាឱ្យកាន់តែមានប្រសិទ្ធភាព។ ឧទាហរណ៍ ម្ចាស់ជំនួយប្រហែលជាមានតម្លៃឯកតាខ្ពស់ (unit costs) ហើយអាចជួយកាត់បន្ថយតម្លៃទាំងនេះតាមរយៈការសន្ទនា និងការចែករំលែកព័ត៌មានស្តីពីការអនុវត្តដ៏ប្រសើរបំផុត។ ក្នុងករណីទាំងអស់នេះ តម្លៃឯកតាអាចត្រូវបានកាត់បន្ថយតាមរយៈការរៀបចំកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព និងកាន់តែមានភាពជោគជ័យ។ ប្រសិនបើដំណោះស្រាយទាំងនេះមិនបានធ្វើឱ្យគម្លាតធនធានកាន់តែតូច ទៅដល់កម្រិតសមរម្យមួយទេនោះជម្រើសគោលនយោបាយ និងចំណុចដៅចាំបាច់ត្រូវពិនិត្យមើលឡើងវិញ។ សេណារីយ៉ូចុងក្រោយ និងផែនការផ្តល់ហិរញ្ញវត្ថុដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអប់រំនឹងឆ្លុះបញ្ចាំងពីការសន្និដ្ឋានទៅលើការពិចារណា ស្តីអំពីសកម្មភាពដែលបានធ្វើផែនការរួច និងធនធានដែលមានស្រាប់។

## ជំហានទី៦៖ ការអភិវឌ្ឍ និងការផ្តល់ហិរញ្ញវត្ថុដល់ផែនការសកម្មភាព

ផែនការប្រតិបត្តិប្រចាំឆ្នាំត្រូវបានរៀបចំឡើងដោយផ្អែកលើមូលដ្ឋានកម្មវិធីជាក់លាក់។ វាជាទូទៅអនុវត្តតាមរចនាសម្ព័ន្ធ និងគំរូក្របខ័ណ្ឌសមហេតុផលដែលជាម៉ែត្រទ្រីសរបស់កម្មវិធី ប៉ុន្តែវាមានភាពលម្អិតជាង។ វាជាផ្នែកមួយដែលផ្តល់ការតភ្ជាប់រវាងយុទ្ធសាស្ត្រកម្មវិធី និងធនធានហើយវាក៏ផ្តល់ព័ត៌មានស្តីពីតួនាទី ការទទួលខុសត្រូវពេលវេលា និងតម្លៃឯកតា (Unit Costs) ផងដែរ។ ផែនការប្រតិបត្តិខ្លាំងមួយអាចបង្កើនលទ្ធភាពការអនុវត្តកាន់តែទទួលបានជោគជ័យ។ ក្នុងករណីភាគច្រើនផែនការប្រតិបត្តិត្រូវបានរៀបចំស្របតាមវត្ថុបំណងនៅក្នុងក្របខ័ណ្ឌលទ្ធផល។ វាជាទូទៅរួមមានព័ត៌មានដូចខាងក្រោមសម្រាប់សកម្មភាពនីមួយៗ៖ (១) អំណះអំណាងជាក់លាក់នៃសកម្មភាព៖ ការធ្វើបែបនេះនឹងដើរតួនាទីជាឯកសារយោងក្នុងការអភិវឌ្ឍផែនការការងារ (២) វត្ថុបំណងរបស់កម្មវិធីដែលសកម្មភាពកំពុងគាំទ្រ៖ ព័ត៌មាននេះបង្ហាញអ្នកអាននូវទំនាក់ទំនងរវាងសកម្មភាពទៅនឹងក្របខ័ណ្ឌលទ្ធផល។ វាធានាឱ្យប្រាកដថាសកម្មភាពទាំងនេះគាំទ្រអាទិភាពដែលបានឯកភាពគ្នា។ (៣) រយៈពេល៖ ចំណុចនេះបង្ហាញពីភាពស៊ីគ្នារវាងតម្លៃប្រចាំឆ្នាំនៃការអនុវត្តសកម្មភាព និងមូលនិធិដែលមាន។ (៤) គុណភាពនៃលទ្ធផល

(ឧទាហរណ៍ ចំនួនគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាល ចំនួនថ្នាក់រៀនដែលបានសាងសង់)៖ ព័ត៌មាននេះគឺសំខាន់ណាស់សម្រាប់របាយការណ៍អនុវត្តប្រចាំឆ្នាំ។ វាអះអាងពីចំណុចដៅសម្រាប់សកម្មភាពមួយក្នុងឆ្នាំនីមួយៗ។ (៥) តម្លៃឯកតា (Unit cost)៖ ព័ត៌មាននេះជាចំណុចយោងមួយសម្រាប់របាយការណ៍អនុវត្តប្រចាំឆ្នាំ។ អ្នកធ្វើផែនការអប់រំ អ្នកធ្វើការសម្រេចចិត្ត និងដៃគូទាំងអស់នឹងចង់ដឹងថាតើយុទ្ធសាស្ត្រនៃការអនុវត្តមានប្រសិទ្ធភាពដែរឬទេ។ (៦) តម្លៃរួមនៃសកម្មភាព៖ នេះគឺជាបរិមាណដែលត្រូវគុណជាមួយនឹងតម្លៃឯកតា។ តម្លៃនៃសកម្មភាពផែនការប្រតិបត្តិទាំងអស់ទាមទារឱ្យនៅក្នុងកញ្ចប់ធនធានរួមដែលគេស្គាល់ថានៅក្នុងផែនការវិស័យអប់រំ។ (៧) ប្រភពនៃការផ្តល់ថវិកា៖ វាជារឿងសំខាន់ណាស់ក្នុងការប្រើប្រាស់ប្រភពថវិកាទាំងអស់ដែលមានដោយផ្អែកលើចំណាយពេលបច្ចុប្បន្ន។ ដោយពឹងផ្អែកលើប្រភពនៃការគាំទ្រពីដៃគូអភិវឌ្ឍ ប្រភពថវិកាខ្លះអាចត្រូវបានគេគ្រប់គ្រងពីខាងក្រៅដំណើរការថវិកាជាតិទៀងទាត់ ឬតាមរយៈរដ្ឋាភិបាលក្នុងស្រុក អង្គការក្រៅរដ្ឋាភិបាល ឬអ្នកដទៃផ្សេងទៀត។ ប្រសិនបើសកម្មភាពទាំងអស់ផ្តល់ថវិកាដល់អ្នកទាំងឡាយណាដែលជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ពួកគេគួរតែមានវត្តមាននៅក្នុងផែនការប្រតិបត្តិ។ ព័ត៌មានផ្តល់ហិរញ្ញវត្ថុដែលពាក់ព័ន្ធជាមួយផែនការប្រតិបត្តិចាំបាច់ត្រូវតែស៊ីគ្នាជាមួយនឹងផែនការហិរញ្ញវត្ថុ (មើលជំហានទី៥)។ (៨) អ្នកទទួលខុសត្រូវក្នុងការអនុវត្ត៖ ព័ត៌មាននេះបង្ហាញពីការទទួលខុសត្រូវសម្រាប់សកម្មភាពនីមួយៗ។ អ្នកដែលមានឈ្មោះទទួលខុសត្រូវចំពោះការអនុវត្តសកម្មភាពគួរតែផ្តួចផ្តើមសំណើផ្តល់ថវិកាក្នុងពេលវេលាមួយសម្រាប់ការអនុវត្ត។ ផែនការប្រតិបត្តិរាប់បញ្ចូលទាំងសូចនាករទិន្នន័យពីកម្មវិធីមួយ ឬក្របខ័ណ្ឌលទ្ធផលដែលសកម្មភាពមួយកំពុងរួមវិភាគទានក្នុងនោះ។ ប្រសិនបើមានសកម្មភាពច្រើន ដែលមិនឆ្លើយតបទៅនឹងសូចនាករកម្រិតទិន្នន័យ និងក្នុងក្របខ័ណ្ឌលទ្ធផលនោះទេវានៅតែមានប្រយោជន៍ក្នុងការផ្តល់ឱ្យ នូវព័ត៌មានបែបសូចនាករដែលនឹងបង្ហាញថាតើសកម្មភាពមួយនេះត្រូវបានអនុវត្តហើយឬនៅ។ ដំណើរការនៃការអភិវឌ្ឍផែនការប្រតិបត្តិទាមទារការសន្ទនាដូចខាងក្រោមនេះ៖ រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ៖ ការទទួលបានព័ត៌មានច្រើនលើទម្រង់នៃការផ្តល់ហិរញ្ញវត្ថុខាងក្រៅគឺជារឿងចាំបាច់។ នៅអតីតកាលការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយភាគច្រើនគឺតែទៅលើគម្រោងហើយតម្លៃភាគច្រើនគឺជាថវិកាខាងក្រៅ។ អ្នកផ្តល់ជំនួយភាគច្រើន

នាពេលបច្ចុប្បន្ននេះផ្តល់ជំនួយក្នុងបរិបទផែនការវិស័យអប់រំ និងអ្នកផ្តល់ជំនួយជាច្រើនទៀតនឹងចូលរួម។ ការចូលរួមជាក្រុម និងផ្តល់មូលនិធិតាមរយៈការគាំទ្រទូទៅ ឬតាមវិស័យ។ រាល់ចំនួនថវិកាខាងក្នុង (on-budget) និងថវិកាខាងក្រៅ (off-budget) គួរតែត្រូវបានគេស្គាល់។ ក្នុងចំណោមការិយាល័យក្នុងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តៈ ត្រូវតែមានភាពសហការជិតស្និតក្នុងចំណោមអង្គភាព(directorates) និងការិយាល័យផែនការ។ រវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុៈ វាជារឿងសំខាន់ជាពិសេសដើម្បីបង្កើតទំនាក់ទំនងជិតស្និទ្ធរវាងការរៀបចំផែនការប្រចាំឆ្នាំ និងការរៀបចំថវិកាប្រចាំឆ្នាំដើម្បីធានាភាពស្របគ្នារវាងក្រសួងទាំងពីរតាមរយៈការសម្របសម្រួលការអនុវត្តផែនការ។ រវាងរាជរដ្ឋាភិបាល និងតួអង្គក្នុងតំបន់ៈ កម្ពុជាកំពុងស្ថិតក្នុងការផ្តល់ស្វ័យភាព និងអំណាចដល់គណៈកម្មការគ្រប់គ្រងសាលារៀន។ ការធ្វើបែបនេះអាចកែលម្អការទទួលខុសត្រូវ ប៉ុន្តែអាចមានគោលនយោបាយមិនបង់ថ្លៃសាលា។ ដំណើរការនៃការអភិវឌ្ឍផែនការប្រតិបត្តិជួយសម្របសម្រួលសកម្មភាពអាទិភាព និងពាក់ព័ន្ធដល់ trade-offs។ ប្រសិនបើគម្លាតនៃការផ្តល់ហិរញ្ញវត្ថុ ត្រូវបានគេរកឃើញនៅពេលដំណើរការអភិវឌ្ឍផែនការប្រតិបត្តិការពិនិត្យឡើងវិញការពន្យាពេល ឬការលុបចោលសកម្មភាពអាទិភាពថ្នាក់ក្រោមនឹងត្រូវអនុវត្ត។

## ជំហានទី៧ៈ យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃគឺមានសារៈសំខាន់ក្នុងការធានាថា ផែនការនោះកំពុងដើរលើផ្លូវត្រូវដើម្បីសម្រេចបាននូវចំណុចដៅ។ ប្រព័ន្ធតាមដាន និងវាយតម្លៃដែលមានប្រសិទ្ធភាពគួរតែសួរថាតើសកម្មភាពដែលចង់បានកំពុងត្រូវបានគេអនុវត្តដូចដែលបានរៀបចំ និងថាតើចំណុចដៅនៃផែនការនេះកំពុងសម្រេចបានផលដែរឬទេ។ កត្តាខាងក្រោមនេះបង្ហាញពីការរៀបចំការតាមដាន និងវាយតម្លៃ និងសូចនាករគន្លឹះក្នុងការរៀបចំផែនការ។ ជំហានដំបូងគឺការធានាការរៀបចំ និងនីតិវិធីនៃការតាមដាន។ អង្គភាព និងនាយកដ្ឋានទទួលបន្ទុកការតាមដានទូទៅគឺចាំបាច់ដើម្បីធានាភាពស៊ីគ្នា និងភាពគ្រប់ដណ្តប់។ ផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មាន គឺជាក្បាលម៉ាស៊ីននៃដំណើរការតាមដានពីព្រោះវាប្រមូលផ្តុំ និងវិភាគទិន្នន័យដែលបានមកពីគ្រប់កម្រិតនៃប្រព័ន្ធអប់រំ។ សកម្មភាពតាមដានសំខាន់បំផុតមានដូចខាងក្រោមៈ ការតាម

ដានជាទម្លាប់នៅក្នុងនាយកដ្ឋានប្រតិបត្តិ៖ ការអនុវត្តផែនការនឹងត្រូវបានគេតាមដានតាមរយៈការប្រជុំជាមួយនាយកដ្ឋាននានាដោយផ្អែកចំណុចដៅ និងសូចនាករដែលមាននៅក្នុងផែនការការងារដែលបានមកពីផែនការសកម្មភាពហើយបានព្រមព្រៀងគ្នា។ ស្រដៀងគ្នាផងដែរនីតិវិធីតាមដានត្រូវតែមាននៅកម្រិតគ្រប់គ្រងបែបវិមជ្ឈការ។ ការពិនិត្យមើលប្រចាំត្រីមាស (Periodic Reviews) ធ្វើឡើងដោយក្រុម ឬអង្គភាពពិនិត្យតាមដាន៖ របាយការណ៍ការងារស្តង់ដាខ្លីមួយត្រូវបានសសេរឡើងដោយនាយកដ្ឋានតែមួយនៅក្នុងរយៈពេលទៀងទាត់ដោយប្រើប្រាស់គោលការណ៍ណែនាំ និងឧបករណ៍នានាដែលបានផ្តល់ឱ្យពួកគេតាមរយៈគណៈកម្មការពិនិត្យតាមដាន។ របាយការណ៍ទាំងនោះត្រូវបានដាក់ជូនគណៈកម្មការដើម្បីពិនិត្យឡើងវិញនូវការវិវឌ្ឍ ពិនិត្យមើលពីបញ្ហាលំបាក និងណែនាំសកម្មភាពកែតម្រូវ។ កម្រិតគ្រប់គ្រងតាមឋានានុក្រមតាមបែប វិមជ្ឈការអាចសុំរបាយការណ៍ទៀងទាត់បាន។ ការពិនិត្យមើលប្រចាំឆ្នាំជាមួយភាគីពាក់ព័ន្ធ៖ ក្រុម ឬអង្គភាពពិនិត្យតាមដានគួររៀបចំរបាយការណ៍ការងារប្រចាំឆ្នាំ។ ការធ្វើបែបនេះនឹងជួយបង្កើតឯកសារសម្រាប់សន្និបាតអប់រំប្រចាំឆ្នាំ ដែលនឹងវាយតម្លៃសមិទ្ធផល និងកំហុសនានា និងឈានទៅរកកិច្ចព្រមព្រៀងគ្នាទៅលើការកែលម្អ។ សន្និបាតនីមួយៗគួររកជាតុចូលសម្រាប់ផែនការប្រតិបត្តិប្រចាំឆ្នាំនៅឆ្នាំបន្តបន្ទាប់ទៀត (រួមទាំងថវិកាផង)។ សូចនាករដូចគ្នាគួរត្រូវបានគេវាស់ពីសន្និបាតមួយទៅសន្និបាតមួយទៀត។ ការវាយតម្លៃ៖ ការវាយតម្លៃជាទូទៅត្រូវបានធ្វើឡើងនៅពាក់កណ្តាលគម្រោង និងនៅចុងគម្រោង។ ជារឿយៗការវាយតម្លៃនេះធ្វើឡើងដោយបុគ្គលឯករាជ្យម្នាក់ដើម្បីជានាសត្យានុម័ត។ ការវាយតម្លៃធ្វើតេស្តលើអំណះអំណាង ឬគំនិតដែលមាននៅក្នុងផែនការវិស័យអប់រំ និងផ្តល់ការណែនាំសម្រាប់ការអភិវឌ្ឍផែនការនាពេលអនាគត។ វាអាចឈានទៅរកការគិតពីអាទិភាព និងចំណុចដៅឡើងវិញ។ គោលបំណងនៃការពិនិត្យឡើងវិញចុងក្រោយគឺមិនត្រឹមតែវាយតម្លៃលទ្ធផលភាពពាក់ព័ន្ធ និងប្រសិទ្ធភាពថវិកា និងនិរន្តរភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិភាគហេតុផលរបស់លទ្ធផលដើម្បីទាញយកបទពិសោធន៍សម្រាប់ការពិនិត្យឡើងវិញ និងសម្រាប់រៀបចំផែនការរយៈពេលមធ្យមនៅពេលបន្ទាប់ទៀត។ សូចនាករការងារសំខាន់ៗ៖ ឧបករណ៍សំខាន់ក្នុងការតាមដាន និងវាយតម្លៃគឺជាសូចនាករដែលតភ្ជាប់ទៅនឹងចំណុចដៅ និងឆ្លុះបញ្ចាំងពីការសម្រេចបានចំណុចដៅ។ សូច

នាករមួយចំនួននឹងត្រូវបានគេរកឃើញនៅក្នុងតារាងម៉ាទ្រីសកម្មវិធីផ្សេងៗ និងដើរតួនាទីជាមូលដ្ឋានគ្រឹះសម្រាប់ដំណើរការតាមដានកម្មវិធី។ ទោះបីជាយ៉ាងណាក៏ដោយសម្រាប់គោលបំណងនៃការពិនិត្យតាមដាន ការងារអនុវត្តផែនការ សូចនាករសំខាន់ទាំងនោះគួរត្រូវបានបង្ហាញក្នុងក្របខ័ណ្ឌលទ្ធផល។ ការជ្រើសរើសសូចនាករទាំងនោះនឹងពិចារណាពីតម្រូវការជាក់លាក់ដូចខាងក្រោមៈ សូចនាករគន្លឹះគួរផ្តោតលើលទ្ធផលនៃប្រព័ន្ធអប់រំ។ វាគួរផ្តោតលើលទ្ធផលនៃគោលដៅរួម វត្ថុបំណងរួម និងចំណុចដៅរួមដោយមិនអើពើអំពីសូចនាករទិន្នន័យ (ដូចជាសាលារៀន) ឬសូចនាករជាតុចូល (ដូចជា ភាគរយថវិកាជាតិលើវិស័យអប់រំ)។ សូចនាករគួរកំណត់ចំនួនមិនឱ្យលើសពី២០។ ការផ្តោតលើសកម្មភាពអាទិភាពគឺមានសារៈសំខាន់។ សូចនាករគួរតែផ្តល់ព័ត៌មានស្តីពីគម្លាតនៅក្នុងការងារប្រព័ន្ធអប់រំ។ សូចនាករត្រូវរាប់បញ្ចូលបញ្ហាយេនឌ័រ និងព័ត៌មានអំពីក្រុមមនុស្សដែលងាយទទួលរងគ្រោះ។ តារាង និងនិយមន័យនៃសូចនាករគួរតែមានស្ថិរភាពនៅពេលធ្វើផែនការ (ទោះបីជាមានការកែតម្រូវខ្លះៗ) ដើម្បីវាស់ការវិវឌ្ឍ។ សូចនាករគួរតែងាយយល់ទាំងអ្នកសម្រេចចិត្ត និងអ្នកមិនមែនបច្ចេកទេស។ សូចនាករទាំងអស់គួរត្រូវបានព្រមព្រៀង និងទទួលយកដោយភាគីពាក់ព័ន្ធនឹងដៃគូអភិវឌ្ឍដើម្បីជានាការសម្របសម្រួល និងការសហការប្រកបដោយភាពរលូន។ នៅពេលដែលរាជធានី-ខេត្តជាច្រើនទទួលបានជោគជ័យក្នុងការប្រមូលព័ត៌មានចាំបាច់ ដើម្បីគណនាសូចនាករគន្លឹះ ការប្រើប្រាស់សូចនាករក្នុងការរកឱ្យឃើញផ្នែកដែលរីកចម្រើន និងយល់ដឹង និងអាចបង្ហាញពីបុព្វហេតុនៃកង្វះការវិវឌ្ឍន៍គឺជារឿងសំខាន់បំផុត។ បន្ថែមលើសូចនាករការធ្វើបែបនេះទាមទារការពឹងពាក់លើព័ត៌មានដែលមានគុណភាពដូចជា ព័ត៌មានដែលប្រមូលបានពីអធិការសាលារៀន ឬតាមរយៈការស្រាវជ្រាវ។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនឹងមានប្រសិទ្ធភាពប្រសិនបើវាមានឥទ្ធិពលលើគោលនយោបាយ និងការធ្វើផែនការយុទ្ធសាស្ត្រ។ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៥)

## ២.៦. គោលការណ៍រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១

- វត្ថុបំណង

- ផ្តល់ជាក្របខ័ណ្ឌ និងឧបករណ៍សម្រាប់ប្រែក្លាយគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីសំខាន់ៗឱ្យទៅជាសកម្មភាពប្រតិបត្តិច្បាស់លាស់ ដែលមានលក្ខណៈទូលំទូលាយ
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលមានលក្ខណៈជាក់ស្តែង និងគ្របដណ្តប់គ្រប់សកម្មភាពទាំងអស់ (រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ) ដោយផ្អែកតាមទិសដៅអាទិភាពប្រចាំឆ្នាំ
- ផ្តល់ក្របខ័ណ្ឌសម្រាប់ការពិនិត្យឡើងវិញប្រចាំឆ្នាំរួមគ្នាលើវិស័យអប់រំរវាងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ តាមរយៈសន្និបាតអប់រំ

ផែនការប្រតិបត្តិប្រចាំឆ្នាំបានរៀបចំឡើងដោយផ្អែកលើគោលការណ៍ ៣ ដូចខាងក្រោមគឺ៖

❖ គោលការណ៍ទី១ : ដំណើរការរៀបចំផែនការដោយមានចូលរួម

- ត្រូវរំលេចរាល់ សកម្មភាពអភិវឌ្ឍទាំងអស់
- ត្រូវប្រមូលផ្តុំគំនិត យោបល់ សកម្មភាពពីគ្រប់ផ្នែក និងអ្នកពាក់ព័ន្ធ
- ដៃគូអភិវឌ្ឍ ត្រូវបន្សុី និងធ្វើសមាហរណកម្មសកម្មភាពអនុវត្តរបស់ខ្លួនទៅនឹងសកម្មភាពនីមួយៗរបស់នាយកដ្ឋានជំនាញ ឬអង្គភាពដែលខ្លួនគាំទ្រ
- ដៃគូអភិឌ្ឍ ត្រូវប្រើប្រាស់យន្តការ និងនីតិវិធីដែលមានស្រាប់របស់រាជរដ្ឋាភិបាល

❖ គោលការណ៍ទី២៖ ការរៀបចំអាទិភាពស្របតាមលទ្ធផលនៃសន្និបាតអប់រំ

- ត្រូវរំលេចឱ្យឃើញពីសកម្មភាព និងអាទិភាពនានាក្នុងវិស័យអប់រំ
- ត្រូវកែលម្អអាទិភាព កម្មវិធី និងសកម្មភាពឱ្យបានច្បាស់លាស់ស្របទៅនឹងអាទិភាពរបស់ក្រសួង
- ដៃគូអភិវឌ្ឍ ត្រូវពិនិត្យមើលសកម្មភាពដែលនាយកដ្ឋានជំនាញ ឬអង្គភាពបានរៀបចំ ថាតើសកម្មភាពណាអាចនឹងគាំទ្របាន

❖ គោលការណ៍ទី៣ ៖ ការរៀបចំផែនការថវិកាផ្អែកលើលទ្ធផល

- ត្រូវរំលេចឱ្យឃើញពីទំនាក់ទំនងរវាងគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងលទ្ធផលរបស់វិស័យអប់រំ យុវជន និងកីឡា

- នាយកដ្ឋានជំនាញ ឬអង្គភាពត្រូវផ្តោតការយកចិត្តទុកដាក់លើលទ្ធផល របស់អនុកម្មវិធីរៀងៗខ្លួន
- នាយកដ្ឋានជំនាញ និងដៃគូអភិវឌ្ឍ នឹងធ្វើការពិភាក្សា និងកំណត់នូវសកម្មភាពច្បាស់លាស់ និងការងារចាំបាច់ ដើម្បីនាំមកនូវលទ្ធផលដែលបានគ្រោងទុក

### ២.៦.១. ពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

*តារាងទី2៖ ពេលវេលានៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ*

| | |
|---|---|
| សប្តាហ៍ទី២ ខែវិច្ឆិកា | សេចក្តីណែនាំស្តីពីការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ ដល់នាយកដ្ឋានជំនាញ អង្គភាព និងដៃគូអភិវឌ្ឍ |
| សប្តាហ៍ទី៤ ខែវិច្ឆិកា | នាយកដ្ឋាន ឬអង្គភាពបញ្ជូនផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ មកនាយកដ្ឋានផែនការជាពីរភាសា (ភាសាខ្មែរ និងភាសាអង់គ្លេស) (Hard and soft copy) |
| សប្តាហ៍ទី២ ខែធ្នូ | សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ និងផ្តល់យោបល់បន្ថែមផ្សេងៗពីអ្នកពាក់ព័ន្ធ |
| សប្តាហ៍ទី៤ ខែធ្នូ | សេចក្តីព្រាងចុងក្រោយ និងបញ្ចប់ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៧ |

### ២.៦.២. តារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១

*តារាងទី3៖ តារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១*

| សកម្មភាពគ្រោងទុក | លទ្ធផលគ្រោងទុក | ក្របខ័ណ្ឌពេលវេលា | | | | អង្គភាពទទួលបន្ទុក | ចំណាយឯកតា | ថវិកាគ្រោងទុក | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | តម្រូវការថវិកាសរុប | ធនធានដែលមាន | | | កង្វះខាតធនធាន |
| | | Q1 | Q2 | Q3 | Q4 | | | | រដ្ឋាភិបាល | ឈ្មោះដៃគូ | សរុប | |
| | | | | | | | | 1 | 2 | 3(1+2+3+...+n) | 4 = 2 + 3 | 5= 1 - 4 |
| កម្មវិធី ៖ | | | | | | | | | | | | |
| អនុកម្មវិធី ៖ | | | | | | | | | | | | |
| ចំណុចដៅ ESP៖ | | | | | | | | | | | | |
| ចំណុចដៅប្រចាំឆ្នាំ៖ | | | | | | | | | | | | |
| សកម្មភាពគោលទី១ ៖ | | | | | | | | | | | | |
| សកម្មភាពរងទី១ ៖ | | | | | | | | | | | | |
| សកម្មភាពរងទី២ ៖ | | | | | | | | | | | | |

- **ការបំពេញតារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១**

– កម្មវិធី : ជាឈ្មោះកម្មវិធីដែលអគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាននីមួយៗទទួលខុសត្រូវ។ ឈ្មោះកម្មវិធីទាំងនេះ ជាឈ្មោះកម្មវិធីរបស់ថវិកាកម្មវិធី ឬនៅក្នុងផែនការយុទ្ធសាស្រ្តថវិកា ២០១៧-២០១៩។ ក្រៅពីនេះ ត្រូវស្ថិតនៅក្រោមកម្មវិធីទី៦ (កម្មវិធីផ្សេងៗ)។

ឧទាហរណ៍ កម្មវិធីទី១ : ការអភិវឌ្ឍអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ។

– អនុកម្មវិធី៖ ជាឈ្មោះអនុកម្មវិធីដែលនាយកដ្ឋាន/អង្គភាពនីមួយៗទទួលខុសត្រូវ។

ឧទាហរណ៍ អនុកម្មវិធី ១.១ ការពង្រីកការអប់រំកុមារតូច។

– សូចនាករ និងចំណុចដៅ ESP: ជាសូចនាករ និងចំណុចដៅ ដែលបានលើកឡើងនៅក្នុង ESP 2019-2023

ឧទាហរណ៍ ចំណុចដៅក្នុងអនុកម្មវិធីទី១.១ ភាគរយកុមារអាយុ ៥ឆ្នាំ បានចូលរៀនកើនឡើងពី ៥៦.៥%នៅឆ្នាំសិក្សា២០១៨-២០១៩ ទៅ ៨០% នៅឆ្នាំសិក្សា២០២០-២០២១។

– ចំណុចដៅប្រចាំឆ្នាំ៖ អនុកម្មវិធីនីមួយៗ ត្រូវបានកំណត់ចំណុចដៅប្រចាំឆ្នាំ(ស្របតាមគោលការណ៍ SMART) ដើម្បីវាស់វែងលទ្ធផលរបស់សកម្មភាពគោលនីមួយៗ។ ចំណុចដៅប្រចាំឆ្នាំ ត្រូវឆ្លើយតបទៅនឹងចំណុចដៅនៅក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០២១-២០២៣។

ឧទាហរណ៍ ចំណុចដៅប្រចាំឆ្នាំក្នុងអនុកម្មវិធីទី៥.១ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២១ របស់ក្រសួង អយក ត្រូវបានរៀបចំឡើង។

– សកម្មភាពគោល៖

- ជាបណ្តុំនៃសកម្មភាពរងជាច្រើន និងរួមចំណែកសម្រេចចំណុចដៅប្រចាំឆ្នាំ
- សកម្មភាពគោល អាចជាសកម្មភាពគោលនៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងថវិកាកម្មវិធី(សម្រាប់នាយកដ្ឋានអនុវត្តថវិកាកម្មវិធី)
- សកម្មភាពគោល អាចជាទិសដៅអាទិភាពរបស់សន្និបាតអប់រំឆ្នាំ២០២០(សម្រាប់នាយកដ្ឋាន ឬ អង្គភាពមិនអនុវត្តថវិកាកម្មវិធី)
- សកម្មភាពគោល ត្រូវបង្ហាញពីលទ្ធផលគ្រោងទុក។

– សកម្មភាពរង៖ ជាសកម្មភាពដែលស្ថិតនៅក្នុងកម្រិតមួយ អាចឆ្លុះបញ្ចាំងពីតម្រូវការធនធាន ពេលវេលា និងអ្នកទទួលខុសត្រូវ។ សកម្មភាពនៅកម្រិតនេះ ចូលរួមសម្រេចសកម្មភាពគោល។ សកម្មភាពទាំងនេះ អាចជួយដល់នាយកដ្ឋានជំនាញធ្វើការរៀបចំផែនការថវិកា និងសកម្មភាពឱ្យមានលក្ខណៈជាក់ស្តែង។ សកម្មភាពរងមិនដូចសកម្មភាពលម្អិតទេ។

– លទ្ធផលគ្រោងទុក៖ ជាលទ្ធផលកើតចេញពីសកម្មភាពគោលនីមួយៗ ក្នុងកំឡុងពេលតិចជាង ១ឆ្នាំ (លទ្ធផលក្នុងឆ្នាំ)។ ចំពោះសកម្មភាពរងនីមួយៗ មិនចាំបាច់បង្ហាញពីលទ្ធផលគ្រោងទុកទេ។

– ក្របខ័ណ្ឌពេលវេលា៖ គឺពេលវេលាគ្រោងសម្រាប់អនុវត្តសកម្មភាពរងនីមួយៗតាមត្រីមាស

– អង្គភាពទទួលបន្ទុក

- អនុកម្មវិធី៖ ត្រូវដាក់ឈ្មោះនាយកដ្ឋាន
- សកម្មភាពគោល៖ ត្រូវដាក់ឈ្មោះនាយកដ្ឋាន ឬ អង្គភាពអនុវត្តផ្ទាល់
- សកម្មភាពរង៖ ត្រូវដាក់ឈ្មោះការិយាល័យ ឬផ្នែក ឬអង្គការដៃគូអភិវឌ្ឍ

– ចំណាយមូលធន៖ គូសសញ្ញា (√) ប៉ុន្តែបើជាចំណាយចរន្តមិនបាច់គូសសញ្ញាទេ។

– ថវិកាគ្រោងទុក៖

- តម្រូវការថវិកាសរុបឆ្នាំ២០១៧
- ធនធានដែលមាន(រដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា)
- កង្វះធនធាន

– តម្រូវការថវិកាសរុបឆ្នាំ២០២១៖ គ្រប់សកម្មភាពទាំងអស់ត្រូវបង្ហាញពីតម្រូវការថវិកាដើម្បីអនុវត្ត

- ថវិកាសកម្មភាពគោល = ថវិកា( សកម្មភាពរង១ + សកម្មភាពរង២+...)
- ថវិកាអនុកម្មវិធី = ថវិកា( សកម្មភាពគោល១ + សកម្មភាពគោល២+...)
- ថវិកាកម្មវិធី = ថវិកា(អនុកម្មវិធី១ + អនុកម្មវិធី២+...)

– ធនធានដែលមាន៖ ធនធានដែលផ្តល់ដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។ នាយកដ្ឋានជំនាញ ឬអង្គភាព ត្រូវបង្ហាញពីលទ្ធភាពធនធានថវិកាកម្មវិធី ដោយយោងទៅតាម BSP2021-2023 និង PB2021។

- ថវិកាដែលផ្តល់ដោយរាជរដ្ឋាភិបាល
- សកម្មភាពដែលរំពឹងថា ទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍ សូមដាក់បញ្ចូលតួលេខថវិកា ទៅតាមឈ្មោះដៃគូអភិវឌ្ឍ
- បើសិនជាសកម្មភាពលើកឡើងថ្មីហើយមិនទាន់មានប្រភពនឹងត្រូវទុកនៅទំនេរ ដើម្បីស្វែងរកការគាំទ្រពីដៃគូពាក់ព័ន្ធជាបន្តទៀត។

– ថវិកាគ្រោងទុក៖

- 1 = តម្រូវការថវិកាសរុបឆ្នាំ២០២១
- 4 = ធនធានដែលមាន( 2=ថវិការាជរដ្ឋាភិបាល+ 3=ថវិកាដៃគូអភិវឌ្ឍ)
- 5 = កង្វះធនធាន = 1 – 4

ឧទាហរណ៍ ការបំពេញតារាងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១

– កម្មវិធីទី៥ គ្រប់គ្រងដោយអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

– អនុកម្មវិធី ៥.១ "ការអភិវឌ្ឍគោលនយោបាយ និងពង្រឹងប្រព័ន្ធផែនការអប់រំ"

– នៅក្នុងឆ្នាំ ២០២០ នាយកដ្ឋានផែនការនឹងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ២០២១

– នៅក្នុងការងារនេះ សកម្មភាពមួយចំនួននឹងត្រូវគ្រោងអនុវត្ត

- រៀបចំសេចក្តីណែនាំ
- សិក្ខាសាលាណែនាំ
- រៀបចំសេចក្តីព្រាងទី១
- សិក្ខាសាលាផ្សព្វផ្សាយ (នាយកដ្ឋានផែនការ, ឆ្នាំ២០២០)

## ២.៧. អត្ថប្រយោជន៍នៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ

ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡារៀបចំឡើងបានល្អប្រសើរ និងច្បាស់លាស់ទាំងរចនាសម្ព័ន្ធ និងខ្លឹមសារឯកសារ។ ផែនការនេះប្រមូលផ្តុំបាននូវគ្រប់សកម្មភាពរបស់ក្រសួង និងបានបែងចែកតាមសកម្មភាពគោលនីមួយៗ ដែលមានការគាំទ្រថវិកាដោយរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍនានារួមមាន អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងគាំទ្រដល់វិស័យអប់រំ។ ក្រសួងបានអនុវត្តតាមគោលការណ៍បើកទូលាយដើម្បីទទួលបានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងមានការពិគ្រោះយោបល់ជាបន្តបន្ទាប់តាំងពីចាប់ផ្តើមរហូតដល់ពេលបញ្ចប់បានឯកសារជាស្ថាពរ។ ផែនការប្រតិបត្តិប្រចាំឆ្នាំនឹងត្រូវបានធ្វើការពិនិត្យឡើងវិញនៅពាក់កណ្តាលឆ្នាំដើម្បីមើលពីវឌ្ឍនភាព និងមានវិធានការដោះស្រាយឱ្យបានទាន់ពេលវេលានូវចំណុចដែលត្រូវកែលម្អ និងជាមេរៀនបទពិសោធន៍សម្រាប់ការរៀបចំនៅឆ្នាំបន្តបន្ទាប់ទៀត។ ផែនការប្រតិបត្តិប្រចាំឆ្នាំជាឧបករណ៍គ្រប់គ្រងដ៏មានសារៈសំខាន់មួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ម្យ៉ាងទៀតផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ដែលជាផ្នែកសំខាន់មួយ នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ របស់ក្រសួងអប់រំ យុវជន និងកីឡាក៏រួមចំណែកជួយដល់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានឱ្យមាន៖ ទស្សនៈ និងចំណេះដឹងទូលំទូលាយ ក្នុងការអនុវត្តការងារគ្រប់គ្រងសាលារៀន ដោយផ្តោតលើផលសម្រេច និងផ្តោតជាចម្បងលើគុណភាពលទ្ធផលសិក្សារបស់សិស្ស។ មានលទ្ធភាពបកស្រាយបញ្ញត្តិ និងគោលការណ៍របស់ឯកសារគោលនយោបាយសេចក្តីណែនាំ និងលិខិតបទដ្ឋាននានាដែលបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និង

កីឡា និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាឱ្យទៅជាសកម្មភាពអនុវត្តជាក់ស្តែងនៅតាមសាលារៀននីមួយៗដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនឱ្យឆ្លើយតបទៅនឹងផែនការប្រតិបត្តិ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំយុវជន និងកីឡា។ ក្នុងផែនប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក៏មានសកម្មភាពស្វ័យវង្វាយតម្លៃសាលារៀនគឺដើម្បីឱ្យបានដឹងពីចំណុចជោគជ័យ និងចំណុចត្រូវកែលម្អដោយបានកំណត់មុខសញ្ញាទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាក់ស្តែង ក្នុងដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀន សាលារៀន និងក្នុងសហគមន៍។ ធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនដោយផ្តោតលើចំណុចត្រូវកែលម្អដែលបានមកពីលទ្ធផលស្វ័យវង្វាយតម្លៃសាលារៀន លទ្ធផលនៃការងារអធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅ ដោយកំណត់មុខសញ្ញាទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពជាក់ស្តែង នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនដើម្បីឱ្យក្លាយទៅជាសកម្មភាពនៃដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀន ក្នុងសាលារៀន និងក្នុងសហគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៤)។

## ២.៨. ពន្យល់ពាក្យគន្លឹះ

### ២.៨.១. តើអ្វីគឺជាផែនការ?

រឿងរ៉ាវដែលល្អៗជាច្រើននៅក្នុងឆាកជីវិត ក៏ដូចជារឿងរ៉ាវដែលគួរឱ្យចាប់អារម្មណ៍បំផុតនៅក្នុងលោកគឺកើតឡើងដោយមិនមានការរៀបចំផែនការទុកនោះឡើយ។ រឿងហេតុទាំងនោះគឺជាលទ្ធផលនៃដំណើរការទាំងឡាយដែលត្រូវចំណាយពេលវេលាយូរហើយអាចកើតឡើងដោយចៃដន្យ ឬជាព្រឹត្តិការណ៍មិនទៀងទាត់ដែលបានបង្កើតជាលទ្ធផលដែលចង់បាន។ ប៉ុន្តែនៅក្នុងទ្រឹស្តីទំនើបនៃការគ្រប់គ្រងអង្គការស្ថាប័នលទ្ធផលដែលចង់បានទាំងអស់នេះ គឺជាលទ្ធផលនៃការរៀបចំផែនការទុកជាមុន (UNESCO 2001:1)។ ការធ្វើផែនការគឺជាប់ពាក់ព័ន្ធនឹងការកំណត់គោលបំណង និងវត្ថុសិក្សារបស់អង្គភាព ឬស្ថាប័នដើម្បីសម្រេចបានប្រសិទ្ធភាពជាអតិបរមា។ វាក៏ពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយ និងការស្រាវជ្រាវស្វែងរកជាបន្តបន្ទាប់នូវវិធីថ្មីៗព្រមទាំងមធ្យោបាយដែលល្អប្រសើរដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារ។

**ផែនការ** គឺជាមូលដ្ឋានគ្រឹះដំបូងបំផុតនៃមុខងារគ្រប់គ្រងទាំងអស់។ អ្នកគ្រប់គ្រងរៀបចំបុគ្គលិកគ្រប់គ្រង និងសម្របសម្រួលដើម្បីជានាឱ្យសម្រេចបាននូវសមិទ្ធផលនៃវត្ថុបំណងដោយយោងទៅតាមផែនការ។ ប្រសិនបើផែនការដើរខុសមុខងារផ្សេងៗទៀតភាគច្រើនក៏អនុវត្តខុសដែរ។ ទោះជាយ៉ាងណាការធ្វើផែនការមិនចាំបាច់ធានាថាត្រូវតែបាននូវភាពជោគជ័យនោះទេ។ គោលបំណងរួមគឺត្រូវឆ្ពោះសំដៅទៅរកភាពជាមូលដ្ឋានដើម្បីកំណត់គោលដៅសមស្រប ព្រមទាំងរៀបចំសម្រាប់ការផ្លាស់ប្តូរនៃការសម្របខ្លួន និងភាពច្នៃប្រឌិតថ្មី Forojalla (1993:40) អ្នកគ្រប់គ្រងទាំងអស់គឺត្រូវប្រែក្លាយផែនការទៅជាសកម្មភាពសំខាន់ៗ ដើម្បីកំណត់គោលដៅរបស់អង្គភាពហើយក៏ឆ្លងកាត់ការសម្រេចចិត្តផងដែរ ដែលត្រូវដាក់បញ្ចូលកម្មវិធីសកម្មភាពជាប្រព័ន្ធសម្រាប់ការអនុវត្តផែនការ។

**ផែនការ** គឺជាមធ្យោបាយជាប្រព័ន្ធមួយដើម្បីដោះស្រាយបញ្ហានាពេលអនាគត។ មធ្យោបាយជាប្រព័ន្ធមានន័យថាធ្វើជាជំហានៗដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពីធនធាន និងពេលវេលាដែលមាន។ ដោះស្រាយបញ្ហាគឺធ្វើឱ្យមានការប្រែប្រួល និងមានលក្ខណៈកាន់តែល្អប្រសើរឡើងៗ ឬអាចនិយាយម្យ៉ាងទៀតថាដើម្បីលុបបំបាត់ ឬកាត់បន្ថយគម្លាតរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលយើងចង់បាន។ បញ្ហាគឺជាឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់ការរីកចម្រើន (ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០០៦)។

**ផែនការ** គឺជាឯកសារមូលដ្ឋានរបស់អង្គភាព ឬការងារដែលបានកើតចេញពីការចងក្រងជាប្រព័ន្ធស្តីពីព័ត៌មានពាក់ព័ន្ធទៅនឹងលទ្ធផលនៃការសម្រេចចិត្តរបស់មន្ត្រីគ្រប់គ្រងអង្គភាពលើការកំណត់ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីការងារដែលត្រូវអនុវត្តតាមដំណាក់កាល និងឆ្នាំនីមួយៗដើម្បីសម្រេចនូវគោលដៅការងារ និងកម្មវិធីរបស់អង្គភាព (អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, ឆ្នាំ២០១០)។ **ផែនការ** គឺជាការបង្ហាញព័ត៌មាន ដែលមានលក្ខណៈវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការគ្រប់គ្រងដំណើរការកម្មវិធីការងារ លទ្ធផលរំពឹងទុកទីកន្លែង ពេលវេលា អ្នកទទួលខុសត្រូវ និងថវិកាគាំទ្រផងដែរ។

**ផែនការ** គឺជាមូលដ្ឋាននៃដំណើរការគ្រប់គ្រងដែលអ្នកគ្រប់គ្រងគ្រប់រូប បានកំណត់គោលដៅការងារជ្រើសរើសសកម្មភាពដើម្បីឈានទៅសម្រេចគោលដៅនោះ។ **ផែនការ** គឺជាត្រីវិស័យដែលគេប្រើសម្រាប់ចង្អុលទិសដៅ និងដែនកំណត់ការងារដែលវិស័យ និងផ្នែកនីមួយៗត្រូវធ្វើ។ ផ្អែកលើមូលដ្ឋាន

ទិន្នន័យដែលបានកំណត់ក្នុងផែនការ អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់អាចទទួលបានឱកាសបង្កើតការច្នៃប្រឌិត សម្រាប់ដំណើរការឈានទៅសម្រេចគោលដៅនៃការងារតាមភារកិច្ចរបស់ខ្លួន (អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ, ឆ្នាំ២០១០)។

**ផែនការ** គឺជាការកំណត់វត្ថុបំណងនៃអ្វីដែលបានធ្វើរួចហើយ និងមានលក្ខណៈគ្រប់គ្រង ជាងការរចនាពីរបៀបដែលវត្ថុបំណងអាចត្រូវបានធ្វើឱ្យសម្រេច។ វាគឺជាសេចក្តីថ្លែងអំពីដែនកំណត់នៃព្រឹត្តិការណ៍នាពេលអនាគត។ យោងទៅតាមលោក Gatewood et al (1995:244) ផែនការគឺជាសំណុំនៃសកម្មភាពដែលមានគោលបំណងដើម្បីសម្រេចគោលដៅ។ ថាតើសម្រាប់នាយកដ្ឋាន អង្គភាពទាំងមូល ឬជាលក្ខណៈបុគ្គល។ លោកបានពន្យល់បន្ថែមទៀតថានៅកម្រិតជាមូលដ្ឋានផែនការគឺជាផែនទីបង្ហាញផ្លូវដែលឆ្លើយតបទៅនឹងសំណួរដែលជាគ្រឹះសំខាន់ៗ។

**ផែនការ** គឺជាជំហានដំបូងនៃធាតុផ្សំនៃការគ្រប់គ្រងអង្គភាព ដែលអ្នកគ្រប់គ្រងកំណត់គោលដៅរបស់ខ្លួន និងរៀបចំយុទ្ធសាស្ត្រទូទៅដើម្បីសម្រេចគោលដៅទាំងនោះ។ លោកFrojalla (1993:40) បានលើកឡើងថា តាមរយៈការធ្វើផែនការនៃការសម្រេចចិត្តត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសកម្មភាពជាប្រព័ន្ធសម្រាប់ការអនុវត្តការងារ។ លើសពីនេះទៅទៀតលោក Benveniste (1970:17) ចែងថាវាមិនមែនចោទជាបញ្ហាអ្វីនោះទេក្នុងការរៀបចំផែនការពីអតីតកាលទៅអនាគត។ ប៉ុន្តែវាគឺជាការផ្លាស់ប្តូរអនាគត តាមរយៈសកម្មភាពអតីតកាល ហើយរាល់ផែនការសកម្មភាពទាំងអស់ក៏មានភាពប្រសើរជាងអ្វីដែលពួកគេធ្លាប់បានធ្វើពីមុនមកផងដែរ។

អ្នកជំនាញជាច្រើនបានកំណត់ផែនការតាមវិធីផ្សេងៗគ្នា។ យោងទៅតាមលោក Chandan (1987:58) កំណត់ការធ្វើ**ផែនការ**ជា "ដំណើរការបន្តនៃការធ្វើបច្ចុប្បន្នភាពនៃសេចក្តីសម្រេចចិត្តរបស់សហគ្រិនភាពជាលក្ខណៈប្រព័ន្ធ និងជាចំណេះដឹងដែលល្អបំផុតអំពីអនាគត ការខិតខំប្រឹងប្រែងទាមទារឱ្យអនុវត្តនូវការសម្រេចចិត្ត និងថ្លឹងថ្លែងនូវលទ្ធផលនៃការសម្រេចចិត្តទាំងនោះជំទាស់នឹងការរំពឹងទុកតាមរយៈមតិយោបល់ត្រឡប់ដែលបានរៀបចំជាលក្ខណៈប្រព័ន្ធ"។ លើសពីនេះទៅទៀតបើតាមលោក Gatewood et al(1995:6)កំណត់ផែនការថាជា "ដំណើរការនៃការកំណត់នូវអ្វីដែលអង្គភាពនឹងសម្រេច

បាន ជាពិសេសថាតើត្រូវធ្វើដូចម្ដេច ដើម្បីសម្រេចបាននូវគោលដៅទាំងអស់នោះដែលបានគ្រោងទុក។ Wateson and his colleagues in Benveniste (1970:18) បានកំណត់ផែនការនៅក្នុងលក្ខខណ្ឌនៃមុខងារជំនាញបានរចនាឡើងដើម្បីជម្រើសមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត ឆ្ពោះទៅរកលទ្ធផលដែលផ្ដល់ឱ្យនៅទីបញ្ចប់។ ម្យ៉ាងវិញទៀតលោក Cunninghum (1982:5) បានកំណត់ថា" ការជ្រើសរើសរវាងទំនាក់ទំនងចំណេះដឹង រូបភាពពិត ការសន្មត់ចាត់ទុកជាការមើលឃើញគោលបំណងសម្រាប់អនាគត ការបង្កើតលទ្ធផលដែលចង់បានគឺត្រូវបានធ្វើឱ្យជោគជ័យតាមរយៈការធ្វើផែនការ"។ និយមន័យខាងលើទាំងនេះ រួមទាំងនិយមន័យផ្សេងៗទៀតនៃការធ្វើផែនការ គឺបញ្ជាក់ថាវាជាមុខងារមូលដ្ឋាននៃការគ្រប់គ្រងបន្តគោលដៅសកម្មភាព និងតម្រង់ទិសដៅសកម្មភាពការងារ។

**២.៨.២. តើអ្វីគឺជាផែនការអប់រំ?**

គ្រប់ប្រទេសគឺធ្លាប់បានរៀបចំផែនការអភិវឌ្ឍរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ។ ទន្ទឹមនឹងនេះវិស័យផ្សេងៗគ្នានៃប្រទេសនេះក៏មានរៀបចំផែនការយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍ។ ដូច្នេះការអប់រំជាវិស័យមួយដែលបានរៀបចំផែនការផងដែរ ក្នុងការបំពេញនូវគោលបំណងរបស់ខ្លួនដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍរយៈពេលខ្លី និងរយៈពេលវែងរបស់ប្រទេស។ លោកJoilu, (2009/10:20) ក៏បង្ហាញពីការធ្វើផែនការអប់រំផងដែរថាជាដំណើរការដែលវិភាគអំពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធអប់រំបង្កើតឡើងក្នុងគោលបំណងដើម្បីកំណត់ និងបង្កើតវិធីសាស្ត្រដែលចង់បាននៅពេលអនាគត។ ជាការពិតផែនការអប់រំគឺមានគោលបំណងជាចម្បងក្នុងការសម្របសម្រួល និងកំណត់ទិសដៅរបស់មនុស្សទាំងអស់ តាមផ្នែកផ្សេងៗគ្នានៃប្រព័ន្ធអប់រំឆ្ពោះទៅរកការសម្រេចបាននូវគោលដៅរយៈពេលវែងរបស់ប្រទេស តំបន់ ឬរដ្ឋ។ លោកJoilu,(2009:10) បញ្ជាក់ម្ដងទៀតថា ផែនការអប់រំនៅក្នុងការផ្សព្វផ្សាយដែលទូលំទូលាយបំផុត វាជាការអនុវត្តនៃការវិភាគប្រកបដោយហេតុផល និងមានលក្ខណៈជាប្រព័ន្ធទៅនឹងដំណើរការនៃការអប់រំ ការអភិវឌ្ឍដោយមានគោលបំណងធ្វើឱ្យការអប់រំកាន់តែមានប្រសិទ្ធភាព និងមានការឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និងសង្គម។

លោកForojalla (1993:39) ដកស្រង់សម្ដីលោក Williams បានបញ្ជាក់ថា" មានផែនការក្នុង

ការអប់រំដូចមានអ្វីគ្រប់យ៉ាងវាពិតជាមានសារៈសំខាន់ណាស់ក្នុងការសម្រេចចិត្តជាមុន នូវអ្វីដែលអ្នកចង់ធ្វើ និងវិធីដែលអ្នកនឹងត្រូវធ្វើ។ លើសពីនេះទៀតលោក Hattand and Ishumi (1984:21) បានលើកឡើងថាផែនការអប់រំមិនមែនជាវិន័យទេ ប៉ុន្តែជាបច្ចេកទេសមួយដែលព្យាយាមប្រើការយល់ដឹងពេញលេញទៅនឹងវិញ្ញាសាមួយចំនួន ការរួមបញ្ចូលគ្នាជាមួយនឹងការយល់ដឹងច្បាស់អំពីតថភាពជាក់ស្តែង។ លើសពីនេះទៀតអង្គការ UNESCO(1970:75) កំណត់ថាវាជាការអនុវត្តចំពោះការអប់រំខ្លួន វិធីសាស្ត្រទាក់ទងនឹងវិទ្យាសាស្ត្រក្នុងការពិនិត្យមើលមួយជំនួសដោយការជ្រើសរើសដោយវាងវៃ ក្នុងចំណោមពួកគេ ជាជាងដឹកនាំជាប្រព័ន្ធដើម្បីអនុវត្តជម្រើសដែលបានបង្កើតឡើង។ សាលារៀនក៏ដូចជាស្ថាប័នដទៃទៀតដែរតម្រូវឱ្យមានផែនការដើម្បីឱ្យដឹងពីប្រសិទ្ធភាពនៅក្នុងអង្គភាព។ ការអប់រំនៅក្នុងវិស័យនេះបានផ្តល់នូវនិយមន័យមួយចំនួនសម្រាប់ការធ្វើផែនការនៅក្នុងសាលារៀន។ លោកUbben and Hughens(1997) កំណត់ការធ្វើផែនការនៅក្នុងសាលារៀន គឺជាដំណើរការមួយដែលពាក់ព័ន្ធនឹងការបកប្រែគោលបំណង គំនិត ជំនឿក្នុងដំណើរការប្រតិបត្តិការ និងអាចវាស់វែងពីលទ្ធផលបាន។

### ២.៨.៣. ផែនការប្រតិបត្តិប្រចាំឆ្នាំ

**ផែនការប្រតិបត្តិប្រចាំឆ្នាំ** គឺជាផែនការរយៈពេលមួយឆ្នាំដែលរៀបចំដោយមានការប្រមូលផ្តុំ និងចងក្រងនូវកម្មវិធី អនុកម្មវិធី ចំណុចដៅប្រចាំឆ្នាំ សកម្មភាពគោល និងរង រួមបញ្ចូលនូវសកម្មភាពដៃគូអភិវឌ្ឍ និងអង្គការក្រៅរដ្ឋាភិបាល លទ្ធផលគ្រោងទុក និងមានក្របខ័ណ្ឌពេលវេលាច្បាស់លាស់ដែលសាលារៀនត្រូវអនុវត្តមួយឆ្នាំពេញ។ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)

ផែនការប្រតិបត្តិប្រចាំឆ្នាំ (AOP) គឺផ្អែកលើថវិកាកម្មវិធីប្រចាំឆ្នាំដែលត្រូវបានអនុម័តដោយសភា។ វាត្រូវបានរៀបចំឡើងដោយក្រសួងពាក់ព័ន្ធទាំងអស់រួមទាំងក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ AOP ត្រូវបានរៀបចំជាកម្មវិធី អនុកម្មវិធី និងសកម្មភាពដែលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា។ លំដាប់នៃ AOP ចំនួនប្រាំត្រូវបានប្រើដើម្បីអនុវត្ត ESP រយៈពេលប្រាំឆ្នាំ។ លើសពីនេះទៀត AOP គឺជាឧបករណ៍រៀបចំ និងតាមដានផែនការដែលត្រូវបានប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានជំនាញ ដើម្បីជំរុញការទទួលខុសត្រូវ តម្លាភាព និងបំណែងចែកធនធានឱ្យមានប្រសិទ្ធភាព។

ផែនការប្រតិបត្តិប្រចាំឆ្នាំមានគោលបំណងផ្តល់ព័ត៌មានជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាដៃគូអភិវឌ្ឍក្នុងវិស័យអប់រំ យល់ដឹងអំពីការងារសកម្មភាពសំខាន់ៗ ដែលនាយកដ្ឋានជំនាញ អង្គភាពជំនាញនានាចំណុះទីស្តីការក្រសួងត្រូវអនុវត្តប្រចាំឆ្នាំ និងងាយស្រួលពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលដែលនាយកដ្ឋាន អង្គភាពជំនាញសម្រេចបានធៀបទៅនឹងផែនការដែលបានលើកឡើង។ ផែនការនេះរួមចំណែកជំរុញឱ្យមានការទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធសំដៅពង្រឹងប្រសិទ្ធភាព អនុវត្តផែនការសកម្មភាពប្រកបដោយសុខដុមនីយកម្ម ការតម្រឹម និងការគ្រប់គ្រងផ្អែកលើលទ្ធផល។ មិនតែប៉ុណ្ណោះផែនការប្រតិបត្តិប្រចាំឆ្នាំជាយន្តការមួយសម្រាប់កៀគរធនធានពីគ្រប់ប្រភពទាំងអស់ និងបង្ហាញឱ្យឃើញពីការប្រើប្រាស់ធនធានអភិវឌ្ឍវិស័យអប់រំប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។ ផែនការប្រតិបត្តិប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងតាមឋានានុក្រមតាំងពីថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា រហូតដល់សាលារៀន។ ផែនការនេះរួមមាន៖ ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រសួងអប់រំ យុជន និងកីឡា (M-AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត (P-AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ(D-AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (S-AOP) (ក្រសួងអប់រំ យុវជន និងកីឡា, ឆ្នាំ២០១៤)។

## ២.៩. ដំណើរការនៃការរៀបចំផែនការអប់រំ

ការរៀបចំផែនការគឺជាដំណើរការឥតឈប់ឈរ មិនត្រឹមតែជាកន្លែងមួយដែលត្រូវទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិធីដើម្បីទៅដល់ទីនោះទៀតផង និងត្រូវទៅផ្លូវណាមួយដែលល្អបំផុត។ វាមានជំហានផ្សេងៗគ្នាដែលអ្នករៀបចំផែនការគួរតែអនុវត្តតាម ការរៀបចំផែនការបង្កើតជាការចាប់ផ្តើមនូវសកម្មភាពជាក់លាក់ការឆ្លងកាត់ជំហាននីមួយៗ ជួយរៀបចំដើម្បីកំណត់ទុកជាមុននូវអ្វីដែលជាតម្រូវការ និងអ្វីដែលត្រូវធ្វើ ហើយថាតើត្រូវធ្វើរបៀបណាដើម្បីអាចឈានទៅសម្រេចគោលដៅ។ ជំហានមានការកែប្រែខ្លះ និងទាក់ទងទៅនឹងកាលៈទេសៈជាក់លាក់របស់អង្គភាព និងគោលបំណងនៃផែនការ។ ក្រៅពីនេះក៏មានកិច្ចព្រមព្រៀងដ៏ល្អមួយតាមរយៈអ្នករៀបចំផែនការ ចំពោះអ្វីដែលជាជំហាននៃដំណើរការនៃការរៀបចំ

ផែនការគួរតែមាន ជាទូទៅមានបីដំណាក់កាលធំៗនៅក្នុងដំណើរការនៃផែនការអប់រំ នៅក្នុងកម្រិតនៃប្រព័ន្ធអប់រំមួយ។ ទី១៖ការរៀបចំផែនការ ទី២៖ ការអនុវត្តផែនការ និងទី៣៖ ការវង្វាយតម្លៃផែនការ។

## ២.៩.១. ការរៀបចំផែនការ

ការធ្វើផែនការមិនមែនជាទំនួលខុសត្រូវរបស់ថ្នាក់ដឹកនាំ បុគ្គលិកនៃនាយកដ្ឋានផែនការ ឬអង្គភាពណាមួយតែប៉ុណ្ណោះទេ ប៉ុន្តែសំដៅទៅដល់អ្នកដែលពាក់ព័ន្ធគ្រប់រូបដែលមានទំនួលខុសត្រូវចំពោះការធ្វើឱ្យលទ្ធផលមានភាពប្រសើរឡើង មានទាំងកាតព្វកិច្ចចូលរួមចំណែកលើកកម្ពស់ផែនការនាពេលអនាគត (Agarwal 1982:39) ។ ការរៀបចំផែនការគឺជាជំហានសំខាន់បំផុតនៅក្នុងដំណើរការនៃផែនការ។ វិភាគស្ថានភាពបច្ចុប្បន្ន កំណត់វត្ថុបំណង បញ្ជាក់តម្រូវការ ការវិភាគពីឱកាស និងឧបសគ្គដោយទទួលបានការគាំទ្រពីម្ចាស់ភាគហ៊ុនតាមដែលអាចធ្វើទៅបាន ការអនុម័តខ្លឹមសារនៃការស្វែងរកអង្គការ និងអ្នកដែលគាំទ្រផ្សេងៗទៀត គឺជាសកម្មភាពដែលត្រូវការការយកចិត្តទុកដាក់ក្នុងដំណាក់កាលនេះ។ នេះដោយសារតែជំហានបន្ទាប់ដែលជាការអនុវត្ត និងការវាយតម្លៃផែនការគឺត្រូវពឹងផ្អែកលើការសង្កេតស៊ីជម្រៅទៅលើដំណាក់កាលអនុវត្ត។ ការបង្កើតផែនការមិនត្រឹមត្រូវគឺនាំឱ្យមានការលំបាក ភាពស្មុគស្មាញ និងភាពច្របូកច្របល់សម្រាប់ការអនុវត្ត និងកង្វះខាតឧបករណ៍មិនគ្រប់គ្រាន់តាមស្តង់ដានៅពេលក្រោយនៃការវាយតម្លៃ។ ការរៀបចំផែនការគួរតែពិចារណាលើស្ថានភាពដែលអាចកើតមានជាមុនដើម្បីដោះស្រាយបញ្ហាមួយចំនួននៅពេលអនាគត។ បើយោងតាម Degarge(1998:54) ជំហានដែលនឹងជួយកាត់បន្ថយការជ្រៀតជ្រែកនៃបញ្ហារបស់អ្នកទាំងនោះគឺការកំណត់បញ្ហាអប់រំសំខាន់ៗ ការផ្តល់អាទិភាពដល់បញ្ហាកំណត់ គោលបំណងទូទៅ និងជាក់លាក់សម្រាប់សកម្មភាព បង្កើតយុទ្ធសាស្ត្រនៃការអនុវត្ត ធ្វើសេចក្តីព្រាងនៃឯកសារផែនការ និងទទួលបានការយល់ព្រម និងត្រួតពិនិត្យពីម្ចាស់ភាគហ៊ុនជំនួយ។ លើសពីនេះទៅទៀតផែនការដែលល្អ និងអនុវត្តដោយឆន្ទៈវាគួរតែបានរៀបចំដោយក្រុមនៃអ្នករៀបចំផែនការ និងម្ចាស់ភាគហ៊ុន។ តុល្យភាពរវាងគុណភាព និងបរិមាណគួរតែត្រូវបានរក្សាទុកជាឯកសារទាំងមូលនៃការរៀបចំផែនការ។ ផែនការឯកសារគឺជាមធ្យោបាយសម្រាប់ទាក់ទងមន្ត្រីជាន់ខ្ពស់ អង្គការផ្តល់មូលនិធិ និង

សប្បុរសជនផ្សេងៗទៀត។ ដូច្នេះហើយវាត្រូវតែមានភាពឆ្លាតវៃគ្រប់គ្រាន់ដើម្បីងាយនឹងទទួលយកបាន និងដៃគូអភិវឌ្ឍមានអារម្មណ៍ថាដូចជាផែនការរបស់ខ្លួនផ្ទាល់។ ផ្អែកលើសុពលភាព លទ្ធភាព និងកត្តាដទៃទៀតឯកសារផែនការត្រូវបានអនុម័ត ឬមិនយល់ព្រមតាមរយៈការប៉ានស្មានខ្ពស់បំផុត ហើយបន្ទាប់មកត្រូវបានបញ្ជូនត្រឡប់មកវិញសម្រាប់ការអនុវត្ត ឬការពិនិត្យឡើងវិញ។

**ការរៀបចំផែនការ** គឺការប្រមើលមើលប្រកបដោយបញ្ញាញាណលើសភាពការណ៍នាពេលអនាគតដែលអាចកើតមានឡើង ការជ្រើសរើសស្ថានភាពដែលចង់បានដើម្បីសម្រេចនូវវត្ថុបំណង ការប្តេជ្ញាចិត្តក្នុងការជ្រើសរើសសកម្មភាពត្រឹមត្រូវដើម្បីសម្រេចនូវគោលបំណងទាំងអស់នោះ ការចំណាយថវិកាតិចបំផុតតាមដែលអាចធ្វើទៅបាន។ ម្យ៉ាងវិញទៀតការរៀបចំផែនការ គឺជាការគិតអំពីអនាគត និងជាការព្យាយាមគ្រប់គ្រងព្រឹត្តិការណ៍អនាគតតាមរយៈការរៀបចំ និងគ្រប់គ្រងធនធានរហូតដល់ពួកគេសម្រេចបានដោយជោគជ័យនូវវត្ថុបំណងដែលបានដាក់ចុះ។ សព្វថ្ងៃនេះមានទស្សនៈរួមជាច្រើនស្តីពីនិយមន័យនៃការរៀបចំផែនការអប់រំ និងគោលគំនិតនានាព្រមទាំងជំហានបច្ចេកទេសទាំងអស់ដែលមាន។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការផ្លាស់ប្តូរគួរជាទីកត់សម្គាល់ទាំងទ្រឹស្តី និងការអនុវត្តទៅលើវិធីសាស្ត្រនានាក្នុងការធ្វើផែនការអប់រំ។ មានការផ្លាស់ប្តូរជាច្រើនផងដែរទៅលើវិធីសាស្ត្រ ភារកិច្ច និងអ្នកចូលរួមព្រមទាំងដំណើរការក្នុងការធ្វើផែនការអប់រំ។ អ្វីដែលសំខាន់បំផុតគឺការអនុវត្តការរៀបចំផែនការអប់រំកាន់តែមានភាពទន់ភ្លន់ មានការចូលរួម និងកាន់តែទទួលបានលទ្ធផលល្អ។ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)

## ២.៩.២. ការអនុវត្តផែនការ

**ការអនុវត្តផែនការ** គឺជាដំណាក់កាលប្រតិបត្តិនៃកម្មវិធីដែលបានគ្រោងទុក។ "វាកំពុងតែដាក់បង្ហាញនៅលើផ្លូវដែលបានរៀបចំរួចជាស្រេចសម្រាប់ដើរ" (Ornstein and Hunkins, 1998:310)។ លោក Buchret (1998:30) កំណត់ការអនុវត្តថា "ជាដំណើរការសកម្មភាពកំណែទម្រង់ដែលបានរៀបចំផែនការគ្រោងទុកជាមុន"។ ស្រដៀងគ្នានេះដែរលោក Pratt (1994:334) កំណត់ការអនុវត្តថា "ជាការ

សម្រេចនៃការផ្លាស់ប្តូរដែលបានគ្រោងទុក វាគឺជាការបើកឱ្យប្រើប្រាស់ទូលំទូលាយតាមរយៈការបញ្ចូលកម្មវិធីទៅក្នុងប្រព័ន្ធសាលារៀន" (UNECSO, 1977:22)។ ការអនុវត្តកម្មវិធីថ្មីតម្រូវឱ្យមានសកម្មភាពសង្គមដែលបង្កើតបរិយាកាសនៃការទទួលយកសម្រាប់ការផ្លាស់ប្តូរ ដូច្នេះវាគឺជាដំណើរការអន្តរកម្មរវាងអ្នកដែលបានបង្កើតកម្មវិធី និងអ្នកដែលមានការផ្លាស់ប្តូរថ្មី(Ornstein and Hunkins, (1998:292)។

យោងទៅតាម (Joilu,2009/10) កត់សំគាល់ថា**ការអនុវត្តផែនការអប់រំ** គឺត្រូវបានគេជួយគាំទ្រយ៉ាងខ្លាំង ដោយមានការបង្កើតជារចនាសម្ព័ន្ធសមស្របសម្រាប់ការសហការ និងពិគ្រោះយោបល់។ រចនាសម្ព័នបុគ្គលិករួមមាន៖ ក្រុមដឹកនាំតម្រង់ទិស ប្រធានសម្របសម្រួលផែនការសាលារៀនដើម្បីត្រួតពិនិត្យដំណើរការទាំងមូល និងសមាជិកក្រុមការងារដើម្បីដោះស្រាយតម្រូវការពិសេសដែលនឹងត្រូវអនុវត្តដើម្បីបង្កើតនីតិវិធីសម្រាប់ការទំនាក់ទំនងរវាងបណ្តាញការងារក្រុម និងបុគ្គលិកពេញលេញដើម្បីរក្សាការប្តេជ្ញាចិត្តរបស់បុគ្គលិកចំពោះដំណើរការនេះ។ នីតិវិធីសម្រាប់ការពិគ្រោះយោបល់ជាមួយភាគីអ្នកពាក់ព័ន្ធក៏គួរតែត្រូវបានបង្កើតឡើងផងដែរ។

## ២.៩.៣. ការវាយតម្លៃផែនការ

**ការវាយតំលៃផែនការ** គឺជាដំណើរការបន្តដែលតម្រូវអនុវត្ត ពីដំបូងរហូតដល់ចុងបញ្ចប់កម្មវិធី។ ជាទូទៅវាត្រូវបានអនុវត្តសម្រាប់គោលបំណងពីរគឺ៖ ដើម្បីបង្ហាញគោលដៅដែលត្រូវបានកំណត់ និងដើម្បីកំណត់អត្តសញ្ញាណគម្លាតដែលជួយឱ្យមានការវាស់វែងត្រឹមត្រូវ។ ការវាយតម្លៃក៏ត្រូវបានពិចារណាផងដែរថាជាដំណើរការមួយប្រសិនបើការកំណត់ទទួល និងអនុវត្តការពិពណ៌នា និងព័ត៌មានវិនិច្ឆ័យអំពីតម្លៃ ឬគុណសម្បត្តិនៃវត្ថុមួយចំនួន ផែនការគោលដៅប្រតិបត្តិការ និងលទ្ធផលគឺក្នុងគោលបំណងធ្វើការសម្រេចចិត្តដើម្បីរក្សាឱ្យបាននូវគណនេយ្យភាព និងការយល់ដឹង។ ចំពោះលោក Mbamba (1992:72) **ការវាយតម្លៃផែនការ**គឺត្រូវធ្វើនៅដំណាក់កាលដំបូង និងចុងក្រោយនៅក្នុងដំណើរការរៀបចំផែនការ ហើយវាគឺជាផ្នែកសំខាន់នៃផែនការដែលបង្ហាញពីការវាយតម្លៃ ត្រួតពិនិត្យបទបញ្ញត្តិ និងការត្រួតពិនិត្យទៅលើការអនុវត្តផែនការ។ លើសពីនេះទៅទៀតលោកបានបញ្ជាក់ថាការវាយតម្លៃក៏ជាយុទ្ធសាស្ត្រសំខាន់ផងដែរសម្រាប់ការរៀបចំកម្រិតនៃការអនុវត្តផែនការ និងបញ្ហាដែលជួបប្រទះក្នុងអំឡុងពេលអនុវត្ត

សកម្មភាព លើសពីនេះទៅទៀតការសម្របសម្រួលការវាយតម្លៃ ការប្រមូលទិន្នន័យអំពីផលប៉ះពាល់នៃធនធានដែលបានប្រើប្រាស់ក្នុងការធ្វើផែនការ គណនីដែលបានទាញយកប្រភពធនធានផ្សេងគ្នា រួមទាំងគុណភាព និងបរិមាណរបស់ពួកគេ។ លើសពីនេះទៀតការសម្របសម្រួលការវាយតម្លៃគឺជាការវាស់ស្ទង់ប្រសិទ្ធភាពនៃផែនការ ទៅតាមតម្រូវការសង្គម និងសេដ្ឋកិច្ច។ វាមានតម្លៃក្នុងការបង្កើតទិន្នន័យដែលនឹងផ្តល់ជាមតិយោបល់លើផលប៉ះពាល់នៃផែនការអប់រំ Mbamba( 1992:72 )។ ដូចដែលបានបញ្ជាក់ខាងលើ**ការវាយតម្លៃ** គឺជាផ្នែកសំខាន់មួយនៃផែនការ។ ក្នុងអំឡុងពេលការអនុវត្តផែនការស្តង់ដា គួរតែត្រូវបានកំណត់ដើម្បីសម្រួលដល់ការវាយតម្លៃនៅពេលក្រោយ។ គម្លាតពីវត្ថុបំណងត្រូវបានវិភាគ ក្នុងលក្ខណៈបំភ្លឺផ្លូវទៅតាមស្តង់ដាដែលត្រូវមានការរៀបចំជាមុនមុនពេលធ្វើការកែតម្រូវ។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី ៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងវិភាគ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ និងសម្រេចទៅតាមវត្ថុបំណងនៃការស្រាវជ្រាវទៅលើប្រធានបទ "ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន" ការសិក្សានេះនឹងប្រើប្រាស់វិធីចម្រុះ គឺតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ប្រើប្រាស់កម្រងសំណួរបំពេញជាទម្រង់ Google form តែមួយប្រភេទសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ កម្រងសំណួរត្រូវបានបង្កើតឡើងតាមរយៈ ការអានឯកសារនានា ដែលទាក់ទងនឹងការរៀបចំផែនការតាមសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលទាក់ទងនឹងប្រធានបទនេះ។

## ៣.២. ការប្រមូលទិន្នន័យ

ទិន្នន័យដែលទទួលបានសម្រាប់ការស្រាវជ្រាវនេះ គឺបានតាមរយៈការរៀបចំឱ្យអ្នកចូលរួមបំពេញកម្រងសំណួរតាមអនឡាញជាទម្រង់ (Google form)។ ដំណើរការចុះប្រមូលទិន្នន័យអ្នកសិក្សាស្រាវជ្រាវ បានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់ ដើម្បីពិភាក្សាជាមួយនាយកសាលាក្នុងគោលបំណង សុំនាយកជួយសហការ និងកំណត់កាលបរិច្ឆេទដើម្បីទម្លាក់កម្រងសំណួរបំពេញជាលក្ខណៈ (Google form) តាមរយៈ តេឡេក្រាម (Telegram) និង ហ្វេសប៊ុកឆាត (Facebook chat) ដល់គណៈនាយក គណនេយ្យ ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុន។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំយុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយគាត់ក៏បានកំណត់ពេលវេលា និងអនុញ្ញាតឱ្យរៀបចំការប្រមូលទិន្នន័យទៅតាមផែនការដែលឯកភាពគ្នា ដោយការប្រមូលទិន្នន័យធ្វើឡើងចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។ ខ្ញុំបានចុះទៅតាមសាលាគោលដៅទៅតាមកាលបរិច្ឆេទ ដែលបានឯកភាពគ្នាជាមួយនាយកវិទ្យាល័យនីមួយៗ ដោយយកចិត្តទុកដាក់ក្នុងការ

សម្របសម្រួល និងសហការជាមួយក្រុមគោលដៅទាំងអស់ ដើម្បីទទួលបានព័ត៌មានមួយអាចជឿទុកចិត្តបានសម្រាប់យកទៅវិភាគក្នុងការសិក្សាស្រាវជ្រាវ។ សម្រាប់អ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការបំពេញកម្រងសំណួរក្រៅពីគណៈគ្រប់គ្រងសាលារៀន ខ្ញុំក៏បានធ្វើការណែនាំ និងពន្យល់ពីគោលបំណងនៃសំណួរ និងរបៀបនៃការឆ្លើយបំពេញកម្រងសំណួរយ៉ាងច្បាស់លាស់ដោយប្រើរយៈពេលប្រមាណ ១០នាទី បន្ទាប់មកយើងបានទុកពេលវេលាមួយសមស្របសម្រាប់ការបំពេញចម្លើយបន្ថែម ដែលអាចប្រើប្រាស់រយៈពេលប្រមាណពី ៣០នាទីទៅ ៤០នាទី គណៈគ្រប់គ្រងសាលា ថ្នាក់ដឹកនាំក្រុមបច្ចេកទេស ព្រមទាំងលោកគ្រូ អ្នកគ្រូ បានដាក់ស្នើ (Submit) កម្រងសំណួរត្រឡប់មកវិញ។ អំឡុងពេលចុះប្រមូលទិន្នន័យនៅតាមសាលារៀនគោលដៅនីមួយៗ ខ្ញុំក៏បានជម្រាបអ្នកចូលរួម ពីគោលបំណងនៃការចុះសិក្សាស្រាវជ្រាវ ក្រមសីលធម៌នៃការស្រាវជ្រាវ និងសារៈប្រយោជន៍ដែលទទួលបានពីការចូលរួមនេះផងដែរ។

### ៣.៣. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យឱ្យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតកម្រងសំណួរស្រាវជ្រាវតែមួយប្រភេទសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ គឺទម្រង់កម្រងសំណួរបំពេញសម្រាប់នាយក នាយិកា នាយករង នាយិការង គណនេយ្យ ប្រធានក្រុមបច្ចេកទេស និងលោកគ្រូអ្នកគ្រូដើម្បីធ្វើការបំពេញដែលចំណាយពេលប្រមាណពី ៣០នាទី ទៅ ៤០នាទី។ ទម្រង់កម្រងសំណួរអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា៤ផ្នែកគឺៈ (១) ព័ត៌មានផ្ទាល់ខ្លួន មាន២សំណួរទាក់ទងទៅនឹងភេទ និងអាយុរបស់អ្នកចូលរួមបំពេញកម្រងសំណួរ។ (២) មុខងារបច្ចុប្បន្ន និងបទពិសោធន៍ការងារមាន៥សំណួរដែលចង់ដឹងអំពី តួនាទីបច្ចុប្បន្ននៅក្នុងសាលារៀនជានាយក នាយិកា នាយករង នាយិការង គណនេយ្យ ប្រធានក្រុមបច្ចេកទេស ឬគ្រូបង្រៀន ព្រមទាំងឆ្នាំទទួលបានតួនាទីរបស់ខ្លួន។ ម្យ៉ាងទៀតក៏មានសំណួរបញ្ជាក់ថាតើសាលារៀនមានរៀបចំសកម្មភាពអ្វីខ្លះ និងភាគីណាខ្លះដែលចូលរួមរៀបចំផែនការ និងលើកសកម្មភាពទាំងនោះ ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនផងដែរ។ (៣) ការអនុវត្តផែនការ មាន៦សំណួរផ្តោតទៅលើសកម្មភាពក្នុងការអនុវត្តផែនការសាលារៀន ឆ្នាំ២០១៩កន្លងទៅទទួលបានលទ្ធផលយ៉ាងដូចម្តេចខ្លះ? សកម្មភាពណាខ្លះដែលគណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ បានធ្វើ និងមិនបានធ្វើ? ឧទាហរណ៍ កំណត់

ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ កំណត់យុទ្ធសាស្ត្រអប់រំ ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តផែនការ។ល។ (៤) តម្រូវការបណ្តុះបណ្តាល មាន៣សំណួរទាក់ទងនៅនឹង ការបញ្ជាក់អំពីកម្រិតសមត្ថភាពរបស់អ្នកចូលរួមរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន មានការយល់ដឹងកម្រិតណាចំពោះសកម្មភាពផ្សេងៗដូចជា៖ ការកំណត់គោលនយោបាយអប់រំ ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ ការអនុវត្តផែនការ និងការពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង មុននឹងរៀបចំផែនការ។ ជាងនេះទៅទៀត ក៏មានសំណួរទាក់ទងទៅនឹងតម្រូវការបណ្តុះបណ្តាលរបស់អ្នកចូលរួម ទៅលើចំណុចណាខ្លះក្នុងការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ព្រមទាំងសំណូមពរដែលគណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូចង់ឱ្យក្រសួងបើកវគ្គបំប៉ននាពេលអនាគតពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តផែនការអប់រំ។

មុនការចុះប្រមូលទិន្នន័យផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តស្វាយរៀង។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរ ដើម្បីឱ្យដឹងថាអាចយកមកប្រមូលទិន្នន័យជាផ្លូវការបាន ឬមិនបាន។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនេះ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថាការសាកល្បងនេះពិតជាទទួលបានផលល្អមែន ព្រោះយើងរកឃើញចំណុចខ្វះខាតមួយចំនួនក្នុងការរៀបចំទៅជាទម្រង់ ONLINE Google form។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនេះទៅពិភាក្សាជាមួយសាស្ត្រាចារ្យណែនាំ ដើម្បីទទួលបានយោបល់ត្រឡប់ក្នុងការកែលម្អឡើងវិញ។ ក្រោយពីការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យណែនាំរួចមកអ្នកសិក្សាស្រាវជ្រាវ ក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យដោយទម្លាក់លីង(Link) កម្រងសំណួរជាលក្ខណៈ Google form នៅតាមសាលារៀនគោលដៅទាំង ៨ ក្នុងស្រុក/ក្រុងទាំង ៨ ក្នុងខេត្តស្វាយរៀង។

## ៣.៤. ការជ្រើសរើសគំរូសំណាក

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីជ្រើសរើសសំណាក ឱ្យឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដោយកំណត់យកតែសំណាកណាដែលទាក់ទងទៅនឹងសំណួរស្រាវជ្រាវដែលមានប្រយោជន៍ដើម្បីទទួលបានទិន្នផលចាំបាច់ និងជាក់លាក់ជាពិសេសអាចឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវប្រធានបទខាងលើ។ ការជ្រើសរើសសំណាកដោយប្រើប្រាស់វិធីរ៉េនដឹម(Random) ដំបូងខ្ញុំធ្វើការជ្រើសរើសវិទ្យាល័យចំនួន៨ ចេញពីក្រុង/ស្រុកទាំង៨ក្នុងខេត្តស្វាយរៀង ដោយទូទាំងខេត្តស្វាយរៀងមានក្រុង២គឺ៖ ក្រុងស្វាយរៀង និងក្រុងបាវិត និងស្រុកចំនួន៦ គឺ៖ ស្រុករំដួល រមាសហែក ស្វាយជ្រុំ ស្វាយទាប កំពង់រោទិ៍ និងស្រុកចន្ទ្រា និងវិទ្យាល័យចំនួន២០ បន្ទាប់មកធ្វើការជ្រើសរើសសំណាកចេញពីវិទ្យាល័យទាំង៨។ សំណាកទាំងអស់គឺជ្រើសរើសនាយក-នាយិកា នាយករង-នាយិការង គណនេយ្យសាលា ប្រធានក្រុមបច្ចេកទេស និងលោកគ្រូអ្នកគ្រូ។

ផ្អែកតាមតារាងទី៤ ខាងក្រោមបង្ហាញថា ក្រុងស្វាយរៀងជ្រើសយកវិទ្យាល័យមួយ សរុបចំនួនសំណាកចូលរួម១៤នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលា១នាក់ ប្រធានក្រុមបច្ចេកទេស២នាក់ និងគ្រូបង្រៀន ៩នាក់។ ក្រុងបាវិត ជ្រើសយកវិទ្យាល័យ១ ចំនួនសំណាកចូលរួមសរុប ១២នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលាមិនបានចូលរួម ប្រធានក្រុមបច្ចេកទេស១នាក់ និងគ្រូបង្រៀន ៩នាក់។ ស្រុករំដួលជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១៥នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលា១នាក់ ប្រធានក្រុមបច្ចេកទេស២នាក់ និងគ្រូបង្រៀន ១០នាក់។ ស្រុករមាសហែកជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១៣នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលាមិនបានចូលរួម ប្រធានក្រុមបច្ចេកទេស១នាក់ និងគ្រូបង្រៀន ១០នាក់។ ស្រុកស្វាយជ្រុំជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១២នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលា១នាក់ ប្រធានក្រុមបច្ចេកទេស២នាក់ និងគ្រូបង្រៀន ៧នាក់។ ស្រុកស្វាយទាប

ជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១០នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលា១នាក់ ប្រធានក្រុមបច្ចេកទេស១នាក់ និងគ្រូបង្រៀន ៦នាក់។ ស្រុកកំពង់រោទិ៍ជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១១នាក់ ដោយក្នុងនោះមាន នាយក-នាយិកា១នាក់ នាយករង-នាយិការង១នាក់ គណនេយ្យសាលាមិនបានចូលរួម ប្រធានក្រុមបច្ចេកទេស១នាក់ និងគ្រូបង្រៀន ៨នាក់។ និងស្រុកចន្ទ្រាជ្រើសយកវិទ្យាល័យ១ សរុបចំនួនសំណាកចូលរួម១៣នាក់ ដោយក្នុងនោះមាននាយក-នាយិកា១នាក់ នាយករង-នាយិការង ១នាក់ គណនេយ្យសាលាមិនបានចូលរួម ប្រធានក្រុមបច្ចេកទេស ១នាក់ និងគ្រូបង្រៀន ១០នាក់។ ការជ្រើសរើសមុខសញ្ញានៃភាគសំណាកទាំងអស់មកធ្វើការសិក្សាស្រាវជ្រាវនេះ គឺដើម្បីផ្ទៀងផ្ទាត់គ្នាថាតើចម្លើយដែលបានមកពីភាគសំណាកទាំងអស់នោះមានភាពសុក្រឹត ឬមិនសុក្រឹត។ ការជ្រើសរើសចំនួនសំណាកនៅតាមក្រុង/ស្រុកមិនដូចគ្នានោះទេ គឺអាស្រ័យទៅលើចំនួនបុគ្គលិកនៅតាមសាលានីមួយៗ និងចំនួនសំណាកដែលបានចូលរួមឆ្លើយកម្រងសំណួរតាមរយៈ Google form មកវិញ។

***តារាងទី4៖ ចំនួនវិទ្យាល័យ ចំនួនបុគ្គលិកអប់រំ និងចំនួនសំណាកដែលបានជ្រើសរើសតាមស្រុកនីមួយៗ***

| ល.រ | ឈ្មោះក្រុង/ស្រុក | ចំនួនវិ.ល័យ | នាយក/នាយិកា | នាយករង/នាយិការង | គណនេយ្យ | ប្រធានក្រុមបច្ចេកទេស | គ្រូបង្រៀន | សរុបសំណាក |
|---|---|---|---|---|---|---|---|---|
| ១ | ក្រុងស្វាយរៀង | ១ | ១ | ១ | ១ | ២ | ៩ | ១៤ |
| ២ | ក្រុងបាវិត | ១ | ១ | ១ | ០ | ១ | ៩ | ១២ |
| ៣ | ស្រុករំដួល | ១ | ១ | ១ | ១ | ២ | ១០ | ១៥ |
| ៤ | ស្រុករមាសហែក | ១ | ១ | ១ | ០ | ១ | ១០ | ១៣ |
| ៥ | ស្រុកស្វាយជ្រុំ | ១ | ១ | ១ | ១ | ២ | ៧ | ១២ |
| ៦ | ស្រុកស្វាយទាប | ១ | ១ | ១ | ១ | ១ | ៦ | ១០ |
| ៧ | ស្រុកកំពង់រោទិ៍ | ១ | ១ | ១ | ០ | ១ | ៨ | ១១ |
| ៨ | ស្រុកចន្ទ្រា | ១ | ១ | ១ | ០ | ១ | ១០ | ១៣ |
| សរុប | | ៨ | ៨ | ៨ | ៤ | ១១ | ៦៩ | ១០០នាក់ |

ផ្អែកខាងលើខ្ញុំបានបង្ហាញពី ចំនួនសំណាកលម្អិតដែលបានចូលរួមតាមក្រុង/ស្រុក និងវិទ្យាល័យនីមួយៗរបស់អ្នកចូលរួមឆ្លើយកម្រងសំណួរទាំងអស់ដែលរួមមាន៖ នាយក-នាយិកា នាយករង-នាយិការ

រង គណនេយ្យសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ខាងក្រោមនេះខ្ញុំនឹងបង្ហាញចំនួនសំណាកសរុប ដែលបានចូលរួមទៅតាមតួនាទី។ យោងតាមរូបទី៣.១ ខាងក្រោមបញ្ជាក់ថាក្នុងចំណោមអ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់ដែលជ្រើសចេញពីវិទ្យាល័យទាំង៨ ក្នុងក្រុង/ស្រុកទាំង៨ក្នុងខេត្តស្វាយរៀងមានតួនាទីដូចខាងក្រោម៖ តួនាទីជានាយក-នាយិកាសាលារៀនមាន ៨នាក់ នាយករង-នាយិការងមាន ៨នាក់ គណនេយ្យសាលាមាន ៤នាក់ ប្រធានក្រុមបច្ចេកទេស ១១នាក់ លោកគ្រូ-អ្នកគ្រូ ៦៩នាក់ សរុបចំនួនសំណាកទាំងអស់មាន ១០០នាក់។




*ក្រាហ្វទី 1៖ តួនាទីរបស់អ្នកចូលរួមបំពេញកម្រងសំណួរ*

## ៣.៥. ការវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានតាមរយៈការបំពេញកម្រងសំណួរ ខ្ញុំធ្វើការវិភាគតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ការវិភាគតាមបែបបរិមាណវិស័យគឺខ្ញុំវិភាគទៅលើប្រភេទសំណួរទម្រង់បិទប្រើប្រាស់កម្មវិធី Microsoft Excel ដោយខ្ញុំបានបញ្ចូលទិន្នន័យវិភាគតាមតារាង ដែលគិតទៅជាភាគរយតាមចំនួនអ្នកចូលរួមទៅតាមសកម្មភាពនីមួយៗ។ ចំណែកឯការវិភាគតាមបែបគុណវិស័យគឺ

វិភាគទៅលើសំណួរទម្រង់បើក ប្រើប្រាស់កម្មវិធី Microsoft Word ដោយធ្វើការរៀបចំផ្តុំគោលគំនិតទស្សនៈ និងសកម្មភាពនានាភាគច្រើនប្រហាក់ប្រហែលគ្នា បែងចែកទៅតាមថ្នាក់នៃសកម្មភាពនីមួយៗ ព្រមទាំងបានកំណត់ចំណាំងជើងចំពោះសកម្មភាពគោលដែលមានអ្នកចូលរួមឆ្លើយភាគច្រើនប្រហាក់ប្រហែលគ្នា រួចធ្វើការពន្យល់ បកស្រាយទៅតាមចំណុចនីមួយៗ។ ដូច្នេះនៅក្នុងការវិភាគចម្លើយចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគគឺអាស្រ័យទៅលើប្រភេទសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ។ ចំពោះការវិភាគនេះអ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួនដូចជា៖ ស្ថានភាពរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន សកម្មភាពជាក់ស្តែងដែលគ្រោងឡើងនៅក្នុងផែនការ បញ្ហាប្រឈមនានាក្នុងការអនុវត្តផែនការនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និងតម្រូវការបណ្តុះបណ្តាលរបស់អ្នកចូលរួមទាក់ទងទៅនឹងផែនការអប់រំ។ រាល់ចម្លើយនៅក្នុងកម្រងសំណួរនឹងត្រូវពិនិត្យថាតើវាមានលក្ខណៈសមស្របនឹងយកជាការបានដែរឬអត់ ព្រមទាំងធ្វើការសម្អាតចម្លើយទាំងនោះមុនពេលបញ្ចូលទៅក្នុងកុំព្យូទ័រជាមួយកម្មវិធីWord និងExcel។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច និងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវគឺ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយយើងនឹងទាញសេចក្តីសន្និដ្ឋានព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនតែម្តង។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

ជំពូកនេះ យើងនឹងបង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ តាមរយៈការវិភាគទិន្នន័យ ការបកស្រាយទិន្នន័យ និងពន្យល់នូវអ្វីដែលបានរកឃើញជាក់ស្តែង តាមរយៈការសម្ភាស និងការចូលរួមបំពេញកម្រងសំណួររបស់ក្រុមគោលដៅទាំងអស់រួមមាន៖ គណៈគ្រប់គ្រងសាលា គណនេយ្យ ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ-អ្នកគ្រូ។ ជំពូកនេះត្រូវបានបែងចែកជា៥ផ្នែកធំៗគឺ (ទី១) ផ្នែករៀបចំផែនការដែលវិភាគអំពីស្ថានភាព ក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ក្នុងក្របខ័ណ្ឌទូទាំងខេត្ត និងក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌទូទាំងខេត្ត និងក្នុងក្របខ័ណ្ឌសាលានីមួយៗ (ទី២) ផ្នែកអនុវត្តផែនការ វិភាគពីស្ថានភាពក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងក្របខ័ណ្ឌទូទាំងខេត្ត និងការអនុវត្តសកម្មភាពក្នុងការជួសជុល និងសាងសង់ ការកែលម្អបរិស្ថាន ការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ (ទី៣) ផ្នែកបញ្ហាប្រឈមក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌទូទាំងខេត្ត និងក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ (ទី៤) ផ្នែកតម្រូវការបណ្តុះបណ្តាល ក្នុងក្របខ័ណ្ឌទូទាំងខេត្តទាក់ទងទៅនឹងផែនការអប់រំនៅកម្រិតសាលារៀន និង(ទី៥) ការពិភាក្សា ផ្នែកនេះយើងនឹងធ្វើការពិភាក្សាចំពោះលទ្ធផលដែលបានរកឃើញផ្អែកទៅលើទ្រឹស្តី ដែលផ្តោតលើបីចំណុចគឺ៖ (១)លទ្ធផលក្នុងស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (២) ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និង(៣)តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំនៅកម្រិតសាលារៀន។

## ៤.១. ផ្នែករៀបចំផែនការ

### ៤.១.១. ស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្នុងក្របខ័ណ្ឌទូទាំងខេត្ត)

តើហេតុអ្វីបានជាចាំបាច់ត្រូវរៀបចំផែនការ?

**ការរៀបចំផែនការ** គឺជាការប្រមើលមើលប្រកបដោយបញ្ញាញាណលើសភាពការណ៍នាពេលអនាគតដែលអាចកើតមានឡើង ការជ្រើសរើសស្ថានភាពដែលចង់បានដើម្បីសម្រេចនូវវត្ថុបំណង ការប្តេជ្ញាចិត្តក្នុងការជ្រើសរើសសកម្មភាពត្រឹមត្រូវ ដើម្បីសម្រេចនូវគោលបំណងទាំងអស់នោះ ធ្វើយ៉ាងណាឱ្យចំណាយពេលវេលា និងថវិកាតិចបំផុតតាមដែលអាចធ្វើទៅបាន។ ម្យ៉ាងវិញទៀត ការរៀបចំផែនការ គឺជាការគិតអំពីអនាគត និងជាការព្យាយាមគ្រប់គ្រងព្រឹត្តិការណ៍អនាគតតាមរយៈការរៀបចំ និងការគ្រប់គ្រងធនធានរហូតដល់សម្រេចបានដោយជោគជ័យនូវវត្ថុបំណងដែលបានដាក់ចុះ។

ជាការពិតណាស់ ការរៀបចំផែនការត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទើបអាចអនុវត្តទៅបានដោយជោគជ័យប្រកបដោយប្រសិទ្ធភាព ផ្ទុយទៅវិ ញបើផែនការសកម្មភាពទាំងនោះ រៀបចំឡើងដោយបុគ្គលណាតែម្នាក់ ឬមនុស្សមួយក្រុមតូច ដោយពុំមានការសហការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនោះទេ ច្បាស់ណាស់ថាសកម្មភាពទាំងនោះ ពុំអាចអនុវត្តបានជោគជ័យមួយរយភាគរយបានឡើយ។ ដើម្បីឱ្យកាន់តែជាច្បាស់ថា តើផែនការសកម្មភាពទាំងឡាយ បានរៀបចំឡើងក្នុងក្របខ័ណ្ឌ សាលារៀនទូទាំងខេត្តស្វាយរៀង មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងសាលា និងមានការបង្កលក្ខណៈ ឱ្យមានការចូលរួមរៀបចំពីភាគីពាក់ព័ន្ធដទៃទៀតបែបណានោះ ផ្នែកនេះយើងនឹងធ្វើការសិក្សា និងវិភាគទៅលើសមាសភាពចូលរួមរៀបចំផែនការ និងលើកសកម្មភាពនានារបស់សាលារៀន នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ ២០១៩។

យោងទៅតាមរូបភាពទី ៤.១ បានកំណត់ពីសមាសភាពចូលរួមរៀបចំផែនការ និងលើកសកម្មភាពរបស់សាលារៀនជាបួនចំណុចធំៗគឺទី១៖ ខ្ញុំលើកខ្លួនឯង ទី២៖ មានការប្រជុំមន្ត្រីក្នុងការិយាល័យខ្ញុំរួចឯកភាពគ្នាលើកសកម្មភាពទាំងនេះ ទី៣៖ នាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យជាអ្នកលើកសកម្មភាពទាំងនេះ និងទី៤៖ ថ្នាក់លើជាអ្នកលើកសកម្មភាពទាំងនេះឱ្យ ដើម្បីឱ្យអ្នកចូលរួមឆ្លើយទាំងអស់ជ្រើសរើសតាមជាក់ស្តែង និងតាមបទពិសោធន៍រៀងៗខ្លួន។ ក្នុងចំណោមអ្នកចូលរួម ១០០ នាក់ ស្មើនឹង១០០% មាន ២នាក់ ស្មើនឹង២% បានឆ្លើយថា ខ្ញុំលើកខ្លួនឯង នៅចំណុចទី១។ ចំណែកឯចំណុច ទី២ មានការប្រជុំមន្ត្រីក្នុងការិយាល័យខ្ញុំរួចឯកភាពគ្នាលើកផែនការសកម្មភាពទាំងនេះ មាន

អ្នកចូលរួម ២៦នាក់ ស្មើនឹង២៦%។ ដោយឡែកចំណុច ទី៣ដែលមាននាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យជាអ្នកលើកផែនការសកម្មភាពទាំងនេះ មានអ្នកចូលរួមរហូតដល់ទៅ ៦០នាក់ ស្មើនឹង ៦០% និងចំណុចទី៤ ថ្នាក់លើជាអ្នកលើកសកម្មភាពទាំងនេះឱ្យមានអ្នកចូលរួម១២នាក់ ស្មើនឹង ១២%។ បើតាមលទ្ធផលនេះយើងសង្កេតឃើញថា ចំណុចទី៣ដែលមាននាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យជាអ្នកលើកផែនការ និងធ្វើសកម្មភាពរបស់សាលារៀនមានអ្នកចូលរួមច្រើនជាងគេ ស្មើនឹង៦០%។ នេះសរបញ្ជាក់ឱ្យឃើញថា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងការលើកសកម្មភាពនានា នៅតាមវិទ្យាល័យក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀង មិនមានលក្ខណៈជាយុទ្ធសាស្ត្រ និងគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនោះទេ ដោយមានតែសមាសភាពចូលរួមរៀបចំផែនការតែភាគីមួយក្រុមតូចតែប៉ុណ្ណោះ គឺនាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យ ដែលពុំទាន់ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំគ្រប់លំដាប់ថ្នាក់ តាំងពីថ្នាក់ក្រសួងអប់រំ យុវជន និងកីឡារហូតដល់ថ្នាក់សាលារៀន ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍រួមទាំងដៃគូអភិវឌ្ឍន៍នានា ដើម្បីឱ្យមានការចូលរួមគាំទ្រទើបការរៀបចំផែនការទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព។ ចំពោះចំណុចទី២ ដែលមានសមាសភាពលើកសកម្មភាពដោយមានការចូលរួម មានការប្រជុំមន្ត្រីក្នុងការិយាល័យ ឬអង្គភាពរួបឯកភាពគ្នារៀបចំផែនការ និងលើកសកម្មភាពទាំងឡាយឡើង ជាចំណុចល្អមួយស្របជាមួយផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលតម្រូវឱ្យមានការប្រជុំមន្ត្រី ឬបុគ្គលិកនៅក្នុងអង្គភាពទាំងអស់ ដើម្បីសម្រេចលើកផែនការសកម្មភាពរួមគ្នា ទើបធ្វើឱ្យការរៀបចំផែនការស្របតាមបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ប៉ុន្តែមានអ្នកចូលរួមតែ ២៦នាក់ ស្មើនឹង២៦%ប៉ុណ្ណោះ ក្នុងចំណោមអ្នកចូលរួម១០០នាក់ ដែលនៅមានកម្រិតទាបនៅឡើយ ទាមទាឱ្យមានការយល់ដឹង កែលម្អ និងបណ្តុះបណ្តាលបន្ថែម។ ចំណែកឯចំណុចទី៤ ថ្នាក់លើជាអ្នកលើកសកម្មភាពទាំងនេះឱ្យ មានអ្នកចូលរួម ១២នាក់ ស្មើនឹង១២% ទោះបីជាចំនួនអ្នកចូលរួមតិចតួចក្តីក៏គួរតែជៀសវាង ដោយហេតុថារាល់សកម្មភាពទាំងឡាយ ថ្នាក់លើពុំអាចដឹងពីតម្រូវការជាក់ស្តែង

និងតម្រូវការអាទិភាពរបស់អង្គភាពនោះទេ មានតែអ្នកនៅក្នុងអង្គភាព ជាអ្នកចូលរួមលើកសកម្មភាពឡើងទើបចំគោលដៅពិតប្រាកដ។ ដោយឡែកចំណុចទី១ ខ្ញុំជាអ្នកលើកសកម្មភាពខ្លួនឯង មានអ្នកចូលរួម ២នាក់ ស្មើនឹង២% ចំណុចនេះរឹតតែគួរជៀសវាង ព្រោះថាលើកសកម្មភាពតែឯកឯង ពិតជាពុំមានតម្លាភាព គ្មានការចូលរួម គ្មានការអភិវឌ្ឍ ហើយក៏អាចគ្មានអ្នកចូលរួមអនុវត្តផងដែរ។

សរុបមករៀបចំផែនការ និងលើកសកម្មភាពនានាក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ របស់សាលារៀន ក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀងមិនទាន់បានល្អនៅឡើយ ដោយសារការរៀបចំពុំមានលក្ខណៈជាយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពុំឆ្លើយតបទៅនឹងបញ្ហាប្រឈម តម្រូវការជាក់ស្តែងរបស់សាលារៀន និងមិនឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡានោះទេ ព្រោះថាចំនួនអ្នកចូលរួម ៦០% បញ្ជាក់ថាការរៀបចំផែនការគឺធ្វើឡើងតែនាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យ ដោយពុំមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ចំណែកឯការលើកសកម្មភាពដោយមានការចូលរួមប្រជុំមន្ត្រីក្នុងការិយាល័យ រួចឯកភាពគ្នាលើកសកម្មភាពមានអ្នកចូលរួមតែ ២៦%ប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំពុំទាន់មានប្រសិទ្ធភាពនៅឡើយ។




*ក្រាហ្វទី 2៖ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្នុងក្របខ័ណ្ឌទូទាំងខេត្ត)*

## ៤.១.២. ស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)

ចំណុច៤.១.១ ខាងលើយើងបានសិក្សាអំពីស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ដែលយើងបានធ្វើការវិភាគក្នុងក្របខ័ណ្ឌទូទាំងខេត្ត បង្ហាញថាការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំគឺគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយ៦០% បង្ហាញថាការរៀបចំ ធ្វើឡើងតែនាយក-នាយិកា នាយករង-នាយិការង និងគណនេយ្យតែប៉ុណ្ណោះ។ ដើម្បីឱ្យមានភាពជឿជាក់ច្បាស់លាស់ និងកាន់តែលម្អិតទៅលើការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនទៀតនោះ ផ្នែកនេះយើងនឹងធ្វើការសិក្សា និងវិភាគទៅលើស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនដោយមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ថាតើមានសាលារៀនណាខ្លះដែលរៀបចំផែនការដោយមានការចូលរួម និងសាលារៀនណាខ្លះដែលមានការរៀបចំតែលើភាគីមួយក្រុមតូច។

ផ្អែកតាមរូបភាពទី៤.២ ខាងក្រោម បង្ហាញថា **វិទ្យាល័យទី១** មានអ្នកចូលរួម១២នាក់ ស្មើនឹង ១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមនោះទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើង មានអ្នកចូលរួម៩នាក់ ស្មើនឹង ៧៥% ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួមតែ២នាក់ ស្មើនឹង១៧%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យ មានអ្នកចូលរួម១នាក់ ស្មើនឹង៨% ដូចនេះ វិទ្យាល័យនេះរៀបចំផែនការដោយមានការចូលរួម មានរហូតដល់៧៥% ចំណែកឯការរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានត្រឹម១៧%ប៉ុណ្ណោះ។ **វិទ្យាល័យទី២** មានអ្នកចូលរួម១០នាក់ ស្មើនឹង ១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមនោះទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើង មានអ្នកចូលរួម៨នាក់ ស្មើនឹង ៨០%។ ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម ២នាក់ ស្មើនឹង២០%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យពុំមានអ្នកចូលរួមទេ។ ដូចនេះវិទ្យាល័យនេះ រៀបចំផែនការដោយមានការចូលរួមមានរហូតដល់៨០%។ ចំណែកឯរៀបចំតែលើគណៈគ្រប់គ្រង និង

គណនេយ្យមានត្រឹម ២០%ប៉ុណ្ណោះ។ **វិទ្យាល័យទី៣** មានអ្នកចូលរួម១២នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯង មានអ្នកចូលរួម១នាក់ ស្មើនឹង៨% ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើងមានអ្នកចូលរួម ៩នាក់ ស្មើនឹង៧៥% ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម ២នាក់ ស្មើនឹង ១៧% ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យពុំមានអ្នកចូលរួមទេ។ ជារួមវិទ្យាល័យនេះរៀបចំផែនការដោយមានការចូលរួម មានរហូតដល់៧៥% ចំណែកឯរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានត្រឹម ១៧%ប៉ុណ្ណោះ។ **វិទ្យាល័យទី៤** មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯង មានអ្នកចូលរួម១នាក់ ស្មើនឹង៩% ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើង ពុំមានអ្នកចូលរួមនោះទេ ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម ៩នាក់ ស្មើនឹង៨២%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យមានអ្នកចូលរួម១នាក់ ស្មើនឹង៩%។ ដូចនេះវិទ្យាល័យនេះ រៀបចំផែនការដោយមានការចូលរួមពីគ្រប់ ភាគីក្នុងអង្គភាពពុំមានអ្នកចូលរួមទេ។ ចំណែកឯការរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានអ្នកចូលរួមរហូតដល់៨២%។ **វិទ្យាល័យទី៥** មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើងក៏ពុំមានអ្នកចូលផងរួមដែរ ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួមរហូតដល់ ១២នាក់ ស្មើនឹង៨៦%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យមានអ្នកចូលរួម២នាក់ ស្មើនឹង១៤%។ ជារួមវិទ្យាល័យនេះរៀបចំផែនការដោយមានការចូលរួមពីគ្រប់ភាគីក្នុងអង្គភាព ពុំមានអ្នកចូលរួមទេ ចំណែកឯការរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានអ្នកចូលរួមរហូតដល់៨៦%។ **វិទ្យាល័យទី៦** មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមនោះទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំចូលរួម និងឯកភាពគ្នាលើកសកម្មភាពឡើង ក៏ពុំមានអ្នកចូលរួមផងដែរ។ ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម

១១នាក់ ស្មើនឹង៨៥% ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យមានអ្នកចូលរួម២នាក់ ស្មើនឹង១៥% ដូចនេះ វិទ្យាល័យនេះ រៀបចំផែនការដោយគ្មានការចូលរួមពីគ្រប់ភាគីក្នុងអង្គភាពនោះទេ។ ចំណែកឯការរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានអ្នកចូលរួមរហូតដល់៨៥%។ **វិទ្យាល័យទី៧** មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំ និងឯកភាពគ្នាលើកសកម្មភាពឡើង ក៏ពុំមានអ្នកចូលរួមដែរ។ ម៉្យាងទៀតការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម ១០នាក់ ស្មើនឹង៧៧%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យមានអ្នកចូលរួម ៣នាក់ ស្មើនឹង២៣%។ ជារួមវិទ្យាល័យនេះ ការរៀបចំផែនការ ដោយមានការចូលរួមពីគ្រប់ភាគីក្នុងអង្គភាពពុំមានអ្នកចូលរួមទេ ចំណែកឯរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានអ្នកចូលរួមរហូតដល់៧៧%។ **វិទ្យាល័យទី៨** មានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ដោយក្នុងនោះការលើកផែនការដោយខ្លួនឯងពុំមានអ្នកចូលរួមនោះទេ ចំណែកឯការរៀបចំផែនការដោយមានការប្រជុំ និងឯកភាពគ្នាលើកសកម្មភាពឡើង ក៏ពុំមានអ្នកចូលរួមផងដែរ។ ម៉្យាងទៀត ការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យ មានអ្នកចូលរួម ១២នាក់ ស្មើនឹង៨០%។ ដោយឡែកថ្នាក់លើជាអ្នកលើកផែនការឱ្យមានអ្នកចូលរួម៣នាក់ស្មើនឹង២០% ។ ដូចនេះ វិទ្យាល័យនេះ ការរៀបចំផែនការ ដោយមានការចូលរួមពីគ្រប់ភាគីក្នុងអង្គភាពពុំមានអ្នកចូលរួមទេ។ ចំណែកឯរៀបចំតែលើគណៈគ្រប់គ្រង និងគណនេយ្យមានអ្នកចូលរួមរហូតដល់ ៨០%។

សរុបមកស្ថានភាពក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ មានវិទ្យាល័យតែ៣ប៉ុណ្ណោះ ដែលរៀបចំផែនការដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយកម្រិតនៃការចូលរួមមានភាគរយខ្ពស់លើ៨០%បានឆ្លើយដូច្នេះ។ ដោយឡែកវិទ្យាល័យចំនួន៥ទៀត រៀបចំផែនការដោយគ្មានការចូលរួមពីភាគីពាក់ព័ន្ធនោះទេ គឺការរៀបចំផែនការតែលើនាយក នាយករង និងគណនេយ្យប៉ុណ្ណោះ ដោយការផ្តល់ចម្លើយរបស់អ្នកចូលរួមមានកម្រិតភាគរយខ្ពស់ជាង ៧០%។




*ក្រាហ្វទី 3៖ ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*

### ៤.១.៣. សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)

ជាទូទៅសាលារៀនគ្រប់កម្រិតតែងតែរៀបចំផែនការ និងលើកសកម្មភាពផ្សេងៗ ដែលជាតម្រូវការជាក់ស្តែង ដោយការបែងចែកថវិកាដំណើរការសាលារៀនប្រចាំឆ្នាំរបស់ខ្លួន ដែលទទួលបានពីក្រសួងអប់រំ យុវជន និងកីឡា ឬរាជរដ្ឋាភិបាល និងប្រភពថវិកាពីដៃគូអភិវឌ្ឍន៍នានា ដើម្បីកែលម្អអង្គភាពរបស់ខ្លួនឱ្យមានការរីកចម្រើន។ សកម្មភាពអាចមានតិច ឬច្រើនអាស្រ័យទៅតាមទំហំនិងតម្រូវការរបស់សាលារៀន។ ផ្នែកនេះយើងនឹងធ្វើការសិក្សា និងវិភាគទៅលើសកម្មភាពផ្សេងៗដែលសាលារៀនបានរៀបចំ និងការបែងចែកថវិកាទៅតាមសកម្មភាពនីមួយៗមានកម្រិតបែបណា ផ្តោតទៅលើកត្តាគុណភាព (ផ្នែកទន់) ឬផ្តោតទៅលើកត្តាសមធម៌(ផ្នែករឹង) នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ របស់សាលារៀន។ តាម រយៈការបញ្ជាក់របស់អ្នកចូលរួម អ្នកស្រាវជ្រាវសង្កេតឃើញថាមានសកម្មភាពជាច្រើនដែលសាលារៀនបានរៀបចំ។ ក្នុងចំណោមសកម្មភាពទាំងអស់នោះ អ្នកស្រាវជ្រាវបានរៀបចំបញ្ចូលគ្នាទៅជាសកម្មភាពគោលដូចមានបង្ហាញនៅក្នុងរូបភាពខាងក្រោម។

ផ្អែកទៅតាមរូបភាពទី៤.៣ បង្ហាញថា សាលារៀនទាំងអស់បានរៀបចំនូវសកម្មភាពធំៗចំនួន៤ នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំគឺ៖ ការជួសជុល និងសាងសង់ ការកែលម្អបរិស្ថាន ការរៀន និងបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។ ក្នុងសកម្មភាពទាំង៤នោះដែរ តាមរយៈអ្នកចូលរួមបំពេញកម្រងសំណួរ និងការត្រួតពិនិត្យតារាងផែនការប្រតិបត្តិប្រចាំឆ្នាំ របស់វិទ្យាល័យក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀង ឃើញថាការបែងចែកថវិកាទៅតាមសកម្មភាពនីមួយៗមិនបានស្មើគ្នានោះទេ។ ក្នុងចំណោមថវិកាសរុប ១០០% នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងក្របខ័ណ្ឌទូទាំងខេត្ត បានបែងចែកទៅលើសកម្មភាពការជួសជុល និងសាងសង់ចំនួន ២៨% ការកែលម្អបរិស្ថាន២៦% ការរៀន និងបង្រៀន ២៤% និងការអភិវឌ្ឍវិជ្ជាជីវៈចំនួន២២%។យោងតាមការវិភាគខាងលើយើងសង្កេតឃើញថាសាលារៀនភាគច្រើន បានផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើផ្នែករឹង ដែលមានសកម្មភាពការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន ជាងការផ្តោតទៅលើផ្នែកទន់ដែលមានសកម្មភាពការរៀននិងបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។

សរុបមកនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ក្នុងក្របខ័ណ្ឌទូទាំងខេត្តមានរៀបចំសកម្មភាព៤គឺ ការជួសជុល និងសាងសង់ ការកែលម្អបរិស្ថាន ការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។ ក្នុងសកម្មភាពនោះដែរ សាលារៀនបានផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែករឹង (ការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន) ច្រើនជាងផ្នែកទន់(ការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ)។ ដូចនេះបញ្ជាក់ឱ្យឃើញថា សាលារៀនភាគច្រើនបានផ្តោតតែទៅលើផ្នែកហេដ្ឋារចនាសម្ព័ន្ធខ្ពស់ជាងផ្នែកគុណភាពអប់រំ ដែលពុំទាន់ឆ្លើយតបទៅនឹងគោលនយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយទេ។




*ក្រាហ្វទី 4៖ សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)*

### ៤.១.៤. សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌសាលានីមួយៗ)

ការសិក្សា និងការវិភាគត្រូវបានធ្វើរួចមកហើយ ទៅលើការចំណាយថវិកាសរុបក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀង ដែលបានបែងចែកទៅតាមសកម្មភាពគោលនីមួយៗនៅក្នុងចំណុច៤.១.៣ ខាងលើ។ ដូចនេះ ដើម្បីឱ្យកាន់តែលម្អិត និងមានភាពជឿជាក់បានថាតើមានវិទ្យាល័យណាខ្លះ ដែលបានផ្តោតលើសកម្មភាពក្នុងការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន ហើយវិទ្យាល័យណាខ្លះ ដែលបានផ្តោតការយកចិត្តទុកដាក់លើសកម្មភាពការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ ផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើសកម្មភាព នៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំក្នុងក្របខ័ណ្ឌសាលានីមួយៗ។

ផ្អែកតាមរូបភាពទី៤.៤ខាងក្រោម បង្ហាញថា**វិទ្យាល័យទី១** មានអ្នកចូលរួម១២នាក់ ស្មើនឹង ១០០% ដោយក្នុងនោះការទម្លាក់ថវិកាដោយផ្តោតលើសកម្មភាពជួសជុល និងសាងសង់មានអ្នកចូលរួម ២នាក់ ស្មើនឹង១៧% ចំណែកឯការកែលម្អបរិស្ថានមាន១នាក់ ស្មើនឹង៨% ម៉្យាងទៀតការរៀន និងបង្រៀនមាន៥នាក់ ស្មើនឹង៤២%។ ដោយឡែក ការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួម៤នាក់ ស្មើនឹង

៣៣%។ ដូចនេះ វិទ្យាល័យទី១មានការផ្ដោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់គុណភាពអប់រំ (ផ្នែកទន់) តាមរយៈអ្នកចូលរួមផ្ដោតទៅលើសកម្មភាពការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ មានភាគរយខ្ពស់ជាងផ្នែករឹង(ការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន)។ **វិទ្យាល័យទី២** មានអ្នកចូលរួម១០នាក់ ស្មើនឹង១០០% ដោយក្នុងនោះការទម្លាក់ថវិកាដោយផ្ដោតលើសកម្មភាពការជួសជុល និងសាងសង់មាន២នាក់ ស្មើនឹង២០%។ ចំណែកឯ ការកែលម្អបរិស្ថានមាន១នាក់ ស្មើនឹង១០%។ ម៉្យាងទៀតការរៀន និងបង្រៀនមាន៤នាក់ ស្មើនឹង៤០%។ ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួម៣នាក់ ស្មើនឹង៣០%។ ដូចនេះវិទ្យាល័យទី២ ក៏មានការផ្ដោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់គុណភាពអប់រំផងដែរ ដោយអ្នកចូលរួមផ្ដោតទៅលើសកម្មភាពផ្នែកទន់(ការបង្រៀននិងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ) មានភាគរយខ្ពស់ជាងផ្នែករឹង(ការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន)។ **វិទ្យាល័យទី៣** មានអ្នកចូលរួម១២នាក់ស្មើនឹង១០០%។ ដោយក្នុងនោះ ការផ្ដោតលើសកម្មភាពជួសជុល និងសាងសង់មានអ្នកចូលរួម១នាក់ ស្មើនឹង៨%។ ចំណែកឯ ការកែលម្អបរិស្ថានមាន ១នាក់ ស្មើនឹង៨%។ ម៉្យាងទៀតការរៀន និងបង្រៀនមាន ៥នាក់ ស្មើនឹង៤២%។ ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈក៏មាន៥នាក់ ស្មើនឹង៤២%ផងដែរ។ ដូចនេះ វិទ្យាល័យទី៣នេះ ក៏មានការផ្ដោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់គុណភាពអប់រំ ដូចទៅនឹងវិទ្យាល័យទី១ និងទី២ផងដែរ។ តាមរយៈអ្នកចូលរួមភាគច្រើនបានផ្ដោតទៅលើផ្នែកទន់(ការបង្រៀននិងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ) មានភាគរយខ្ពស់ជាងផ្នែករឹង(ការជួសជុលនិងសាងសង់ និងការកែលម្អបរិស្ថាន)។ **វិទ្យាល័យទី៤** មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% ដោយក្នុងនោះ ការផ្ដោតលើសកម្មភាពការជួសជុល និងសាងសង់មានអ្នកចូលរួម៤នាក់ ស្មើនឹង៣៧%។ ចំណែកឯ ការកែលម្អបរិស្ថានមាន២នាក់ ស្មើនឹង១៨%។ ម៉្យាងទៀតការរៀន និងបង្រៀនក៏មាន២នាក់ ស្មើនឹង១៨%ផងដែរ។ ដោយឡែក ការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួម៣នាក់ស្មើនឹង២៧%។ ដូចនេះ វិទ្យាល័យទី៤ មានការផ្ដោតការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់ទាំងគុណភាពអប់រំ និងសមធម៌(ផ្នែករឹងនិងផ្នែកទន់) តាមរយៈការផ្ដល់ថវិកាខ្ពស់ទៅលើសកម្មភាពការជួសជុល និងការសាងសង់ និងការអភិវឌ្ឍវិជ្ជាជីវៈមានភាគរយខ្ពស់ជាងការបង្រៀន និងរៀន និងការកែលម្អបរិស្ថាន។ **វិទ្យាល័យ**

**ទី៥** មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% ដោយក្នុងនោះការផ្តោតលើសកម្មភាពការជួសជុល និងសាងសង់មានអ្នកចូលរួម ៥នាក់ ស្មើនឹង៣៦%។ ចំណែកឯ ការកែលម្អបរិស្ថានមាន ៥នាក់ ស្មើនឹង៣៦%។ ម៉្យាងទៀតការរៀន និងបង្រៀនមាន៣នាក់ស្មើនឹង២១%។ ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួមតែ១នាក់ ស្មើនឹង៧%ប៉ុណ្ណោះ។ ដូចនេះ វិទ្យាល័យទី៥ មានការផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែករឹង(ការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន) មានកម្រិតខ្ពស់ជាងផ្នែកទន់(ការបង្រៀននិងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ)។ **វិទ្យាល័យទី៦** មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ដោយក្នុងនោះការផ្តោតលើសកម្មភាពការជួសជុល និងសាងសង់មានអ្នកចូលរួម៤នាក់ ស្មើនឹង៣១%។ ចំណែកឯការកែលម្អបរិស្ថានមាន៥នាក់ ស្មើនឹង៣៩%។ ម៉្យាងទៀតការរៀន និងបង្រៀនមាន២នាក់ ស្មើនឹង១៥% ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈក៏មានអ្នកចូលរួម២នាក់ ស្មើនឹង១៥%ផងដែរ។ ដូចនេះវិទ្យាល័យទី៦ មានការផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែករឹង ជាងផ្នែកទន់ផងដែរ។ **វិទ្យាល័យទី៧** មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ដោយក្នុងនោះការផ្តោតលើសកម្មភាពការជួសជុល និងសាងសង់មានអ្នកចូលរួម៤នាក់ ស្មើនឹង៣១%។ ចំណែកឯការកែលម្អបរិស្ថានមាន៥នាក់ស្មើនឹង៣៩%។ ម៉្យាងទៀតការរៀន និងបង្រៀនមាន២នាក់ ស្មើនឹង១៥% ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈក៏មានអ្នកចូលរួម២នាក់ស្មើនឹង១៥%ផងដែរ។ ដូចនេះវិទ្យាល័យនេះ ក៏មានការផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែករឹង ជាងផ្នែកទន់ផងដែរ។ **វិទ្យាល័យទី៨** មានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ដោយក្នុងនោះការទម្លាក់ថវិកាដោយផ្តោតលើសកម្មភាពការជួសជុល និងសាងសង់មានអ្នកចូលរួម៦នាក់ ស្មើនឹង៤០% ចំណែកឯការកែលម្អបរិស្ថានមាន៦នាក់ស្មើនឹង៤០% ម៉្យាងទៀតការរៀន និងបង្រៀនមាន១នាក់ ស្មើនឹង៧%។ ដោយឡែកការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួម ២នាក់ ស្មើនឹង១៣%។ ដូចនេះវិទ្យាល័យទី៨ ក៏មានការផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែករឹង ជាងផ្នែកទន់ផងដែរ ដោយអ្នកចូលរួមភាគច្រើនបានផ្តោតទៅលើសកម្មភាពក្នុងការជួសជុល និងសាងសង់ និងការកែលម្អបរិស្ថាន មានកម្រិតភាគរយខ្ពស់ជាងការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ។

សរុបមក ការបែងចែកថវិកាទៅតាមសកម្មភាពនីមួយៗ ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ របស់សាលារៀន បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាមានវិទ្យាល័យ៣ ផ្តោតទៅលើផ្នែកទន់ (កត្តាគុណភាព) ដោយមានការបែងចែកថវិកាប្រចាំឆ្នាំមានភាគរយច្រើនទៅលើសកម្មភាពនៃការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ ជាជាងផ្តោតទៅលើផ្នែករឹង(ការជួសជុលនិងសាងសង់ និងការកែលម្អបរិស្ថាន)។ ដោយឡែកវិទ្យាល័យ៥ទៀត ផ្តោតទៅលើផ្នែករឹង ជាងផ្នែកទន់។




*ក្រាហ្វទី 5៖ សកម្មភាពនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌសាលានីមួយៗ)*

## ៤.២. ផ្នែកអនុវត្តផែនការ

### ៤.២.១. ស្ថានភាពអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (ក្របខ័ណ្ឌទូទាំងខេត្ត)

ការសិក្សាបានធ្វើរួចមកហើយពីសកម្មភាពផ្សេងៗ ដែលសាលារៀនបានរៀបចំ និងការបែងចែកថវិកាទៅតាមសកម្មភាពនីមួយៗនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនៅផ្នែកខាងលើ។ ក្នុងផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការសិក្សា និងវិភាគទៅលើការអនុវត្តផែនការ ថាតើក្នុងសកម្មភាពទាំងអស់នោះ បើយើង

ពិនិត្យមើលក្នុងក្របខ័ណ្ឌទូទាំងខេត្ត អនុវត្តសម្រេចបានកម្រិតណា មានអ្នកចូលរួមប៉ុន្មាននាក់ទៅតាមកម្រិតនៃភាគរយក្នុងការសម្រេចសកម្មភាពនីមួយៗ។

ផ្អែកតាមតារាងទី៥ សកម្មភាពទាំងអស់ដែលសាលារៀនបានអនុវត្តត្រូវបានរៀបចំជា ៤ផ្នែក៖ ១. ការជួសជុលនិងសាងសង់៖ ដោយក្នុងចំណោមអ្នកចូលរួម១០០នាក់ មាន៦០នាក់ដែលបញ្ជាក់ថា **សកម្មភាពទី១**នេះសាលារៀនអនុវត្តបានស្មើនឹង៦០%ប៉ុណ្ណោះ។ ក្នុងក្របខ័ណ្ឌទូទាំងខេត្ត សកម្មភាពនេះ អនុវត្តពុំទាន់ទទួលបានលទ្ធផលល្អនៅឡើយទេ ដោយសារការរៀបចំផែនការមិនមានលក្ខណៈយុទ្ធសាស្ត្រ គ្មានការចូលរួម ជាពិសេសផ្នែករដ្ឋបាលដែលទទួលបន្ទុកការងារនេះផ្ទាល់ រួមទាំងគណៈកម្មការគ្រប់គ្រងសាលា និងភាគីពាក់ព័ន្ធដទៃទៀតមិនបានចូលរួមរៀបចំផែនការ។ ដូច្នេះមិនអាចកំណត់បានពីបញ្ហាប្រឈមជាក់ស្តែងដែលត្រូវដោះស្រាយ។ **សកម្មភាពទី២៖** ការកែលម្អបរិស្ថាន៖ មានអ្នកចូលរួម ៥៦ នាក់ បញ្ជាក់ថាសាលារៀនអនុវត្តសម្រេចបានស្មើនឹង៥៦%ប៉ុណ្ណោះ។ សកម្មភាពនេះក៏ដូចការជួសជុលនិងសាងសង់ផងដែរ លទ្ធផលសម្រេចបានមិនទាន់ល្អប្រសើរនៅឡើយទេ ដោយសារការរៀបចំគ្មានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗទៀត។ **សកម្មភាពទី៣៖** ការបង្រៀន និងរៀន៖ មាន៥១នាក់ដែលបញ្ជាក់ថា សាលារៀនអនុវត្តសម្រេចបាន ដែលស្មើនឹង ៥១%ប៉ុណ្ណោះ។ សកម្មភាពនេះក៏ដូចសកម្មភាពខាងលើដែរ គឺលទ្ធផលសម្រេចបាននៅត្រឹមកម្រិតមធ្យម មិនទាន់បានល្អប្រសើរនោះទេ។ ចំណែកឯ**សកម្មភាពទី៤៖** ការអភិវឌ្ឍវិជ្ជាជីវៈមានអ្នកចូលរួម៤០នាក់ដែលបញ្ជាក់ថាសាលារៀនអនុវត្តបានស្មើនឹង៤០%។ ជារួមសកម្មភាពទាំងនេះ សម្រេចលទ្ធផលបាននៅមានកម្រិតទាបស្ថិតនៅក្រោមមធ្យម។ ដូចនេះទាំងលទ្ធផលនៃការបង្រៀន និងរៀន និងការអភិវឌ្ឍវិជ្ជាជីវៈ លទ្ធផលសម្រេចបានក៏មិនទាន់ល្អប្រសើរផងដែរ ដោយសារការរៀបចំគ្មានការចូលរួមពីភាគីពាក់ព័ន្ធនានា ជាពិសេសសកម្មភាពទាំងពីរនេះពាក់ព័ន្ធទៅនឹងគ្រូបង្រៀន និងប្រធានក្រុមបច្ចេកទេសដែលជាអ្នកអនុវត្តផ្ទាល់។ ដូច្នេះពួកគាត់អាចដឹងពីកង្វះខាត តម្រូវការជាក់ស្តែង និងបញ្ហាប្រឈមនានា។ ប៉ុន្តែការរៀបចំផែនការគ្មានការចូលរួមពីពួកគាត់ បណ្តាលឱ្យការអនុវត្តពុំទទួលបានលទ្ធផលល្អប្រសើរ។

សរុបមកការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន បើមើលក្នុងក្របខ័ណ្ឌទូទាំងខេត្ត មិនទាន់បានល្អប្រសើរនៅឡើយទេ ដោយអនុវត្តសម្រេចបានត្រឹមក្រោម៦០%ប៉ុណ្ណោះ ដោយសារទាក់ទងទៅនឹងផ្នែកទី១ ការរៀបចំផែនការគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសគណៈកម្មការគ្រប់គ្រងសាលារៀន រដ្ឋបាលសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដែលជាអ្នកត្រូវអនុវត្តផ្ទាល់ដឹងពីតម្រូវការជាក់ស្តែង និងបញ្ហាប្រឈមនានាក្នុងអំឡុងពេលអនុវត្ត។

*តារាងទី5៖ ស្ថានភាពអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន(ក្របខ័ណ្ឌទូទាំងខេត្ត)*

| សកម្មភាព | លទ្ធផល |
|---|---|
| ១. ជួសជុល និងសាងសង់ | ៦០% |
| ២. កែលម្អបរិស្ថាន | ៥៦% |
| ៣. ការបង្រៀន និងរៀន | ៥១% |
| ៤. អភិវឌ្ឍវិជ្ជាជីវៈ | ៤០% |

**៤.២.២. ការអនុវត្តសកម្មភាពក្នុងការជួសជុល និងសាងសង់(ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)**

ផ្នែក៤.២.១ ខាងលើអ្នកស្រាវជ្រាវបានសិក្សាពីសកម្មភាពផ្សេងៗ ដែលសាលារៀនអនុវត្តសម្រេចបានទៅតាមកម្រិតភាគរយ ក្នុងក្របខ័ណ្ឌទូទាំងខេត្ត។ ដើម្បីឱ្យកាន់តែច្បាស់ ថាតើតាមសកម្មភាព នៅតាមសាលារៀននីមួយៗ មានសាលារៀនណាខ្លះដែលអនុវត្តបាន១០០% សាលារៀនណាខ្លះអនុវត្តបានមធ្យមនិងសាលាណាខ្លះអនុវត្តបានខ្សោយ ផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគលម្អិតទៅលើសកម្មភាពក្នុងការជួសជុល និងសាងសង់តាមវិទ្យាល័យនីមួយៗ។

យោងតាមរូបភាពទី៤.៥ ខាងក្រោមបង្ហាញថា សកម្មភាពក្នុងការជួសជុល និងសាងសង់ ក្នុងវិទ្យាល័យទី១ ក្នុងចំណោមអ្នកចូលរួម១២នាក់ ស្មើនឹង១០០% បញ្ជាក់ថាសាលារៀនអនុវត្តសម្រេចបាន

១០០%។ វិទ្យាល័យទី២ មានអ្នកចូលរួម១០នាក់ ស្មើនឹង១០០% បង្ហាញថាសាលារៀនរបស់ខ្លួនអនុវត្តបាន៩៥%។ វិទ្យាល័យទី៣ មានអ្នកចូលរួម១២នាក់ ស្មើនឹង១០០% បង្ហាញថា អនុវត្តបាន ៩០%។ វិទ្យាល័យទី៤ មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% បង្ហាញថា អនុវត្តបាន ៤៩%។ វិទ្យាល័យទី៥ មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% បង្ហាញថាអនុវត្តបាន ៤៣%។ វិទ្យាល័យទី៦ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% បង្ហាញថាអនុវត្តសម្រេចបាន៤០%។ វិទ្យាល័យទី៧ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% បញ្ជាក់ថា អនុវត្តបាន៣៥% និងវិទ្យាល័យទី៨ ដែលមានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ក៏បានបង្ហាញថាសាលារៀនរបស់ខ្លួនអនុវត្តសម្រេចបានត្រឹម ៣០%ប៉ុណ្ណោះ។

សរុបមកក្នុងសកម្មភាពការជួសជុល និងសាងសង់នេះ បើយើងមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ក៏មានសាលារៀន៣ផងដែរ ដែលអនុវត្តសម្រេចបានលទ្ធផលខ្ពស់លើស៩០%។ ខណៈដែលសាលារៀន៥ទៀត អនុវត្តបានលទ្ធផលក្រោមមធ្យមស្ថិតនៅក្រោម៥០%។




*ក្រាហ្វទី ៦៖ ការអនុវត្តសកម្មភាពក្នុងការជួសជុល និងសាងសង់(ក្របខ័ណ្ឌសាលានីមួយៗ)*

### ៤.២.៣. ការអនុវត្តសកម្មភាពក្នុងការកែលម្អបរិស្ថាន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)

ផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគលម្អិតទៅលើសកម្មភាពក្នុងការកែលម្អបរិស្ថាន នៅតាមវិទ្យាល័យនីមួយៗ។ យោងតាមរូបភាពទី៤.៦ ខាងក្រោមបង្ហាញថា សកម្មភាពក្នុងការកែលម្អបរិស្ថាន ក្នុងវិទ្យាល័យទី១ ក្នុងចំណោមអ្នកចូលរួម១២នាក់ ស្មើនឹង១០០% បញ្ជាក់ថាសាលារៀនអនុវត្តសម្រេចបាន៩៧%។ វិទ្យាល័យទី២ មានអ្នកចូលរួម១០នាក់ ស្មើនឹង១០០% បង្ហាញថាសាលារៀនអនុវត្តបាន៩០%។ វិទ្យាល័យទី៣ មានអ្នកចូលរួម១២នាក់ ស្មើនឹង១០០% អនុវត្តបាន៨២%។ វិទ្យាល័យទី៤ មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% អនុវត្តបាន៥៤%។ វិទ្យាល័យទី៥ មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% បង្ហាញថា ៣៥%។ វិទ្យាល័យទី៦ មានអ្នកចូលរួម១៣នាក់ ស្មើនឹង ១០០% អនុវត្តសម្រេចបាន ៣៣%។ វិទ្យាល័យទី៧ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% អនុវត្តបាន ៣០% និងវិទ្យាល័យទី៨ ដែលមានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ក៏បានបង្ហាញថាសាលារៀនរបស់ខ្លួនអនុវត្តសម្រេចបានត្រឹម ២៩%ប៉ុណ្ណោះ។

សរុមមកក្នុងសកម្មភាពការកែលម្អបរិស្ថាន បើយើងមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ក៏មានសាលារៀន៣ ដែលអនុវត្តសម្រេចបានលទ្ធផលខ្ពស់ផងដែរគឺលើ៨០% និងវិទ្យាល័យទី៤ សម្រេចបាន ៥៤%ត្រឹមកម្រិតមធ្យម។ ខណៈដែលសាលារៀន៥ទៀត អនុវត្តលទ្ធផលសម្រេចបានកម្រិតទាប ស្ថិតនៅក្រោម ៤០%។




*ក្រាហ្វទី 7៖ការអនុវត្តសកម្មភាពក្នុងការកែលម្អបរិស្ថាន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*

#### ៤.២.៤. ការអនុវត្តសកម្មភាពក្នុងការបង្រៀន និងរៀន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)

ផ្នែកនេះយើងនឹងធ្វើការវិភាគលម្អិតទៅលើសកម្មភាពក្នុងការបង្រៀន និងរៀន នៅតាមវិទ្យាល័យនីមួយៗ។ យោងតាមរូបភាពទី៤.៧ ខាងក្រោមបង្ហាញថា សកម្មភាពក្នុងការបង្រៀន និងរៀន ក្នុងវិទ្យា ល័យទី១ ក្នុងចំណោមអ្នកចូលរួម១២នាក់ ស្មើនឹង១០០% បញ្ជាក់ថាសាលារៀនអនុវត្តសម្រេចបាន១០០%។ វិទ្យាល័យទី២ មានអ្នកចូលរួម១០នាក់ ស្មើនឹង១០០% អនុវត្តបាន ៩០%។ វិទ្យាល័យទី៣ មានអ្នកចូលរួម១២នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ៦២%។ វិទ្យាល័យទី៤ មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% ថាអនុវត្តបាន៣៦%។ វិទ្យាល័យទី៥ មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ៣៤%។ វិទ្យាល័យទី៦ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ថាអនុវត្តសម្រេចបាន៣១%។ វិទ្យាល័យទី៧ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ថាអនុវត្តបាន

២៩% និងវិទ្យាល័យទី៨ ដែលមានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ក៏បានបង្ហាញថា សាលារៀនរបស់ខ្លួនអនុវត្តសម្រេចបានត្រឹម២៨% ប៉ុណ្ណោះ។

សរុបមកក្នុងសកម្មភាពការបង្រៀន និងរៀន បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ក៏មានសាលារៀនចំនួន២ ដែលអនុវត្តសម្រេចបានលទ្ធផលខ្ពស់ផងដែរគឺលើ៩០% និងវិទ្យាល័យទី៣ ក៏ សម្រេចបានលទ្ធផលល្អបង្គួរគឺស្មើនឹង ៦២%។ ខណៈដែលសាលារៀន៥ទៀត អនុវត្តលទ្ធផលសម្រេចបានមានកម្រិតទាប ស្ថិតនៅក្រោម ៤០%។




*ក្រាហ្វទី ៩៖ ការអនុវត្តសកម្មភាពក្នុងការបង្រៀន និងរៀន (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*

**៤.២.៥. ការអនុវត្តសកម្មភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈ (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)**

ផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើការវិភាគលម្អិតទៅលើសកម្មភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈ នៅតាមវិទ្យាល័យនីមួយៗ។ យោងតាមរូបភាពទី៤.៨ ខាងក្រោមបង្ហាញថា សកម្មភាពក្នុងការបង្រៀននិងរៀនក្នុងវិទ្យាល័យទី១ ក្នុងចំណោមអ្នកចូលរួម១២នាក់ ស្មើនឹង១០០% បញ្ជាក់ថាសាលារៀនអនុវត្តសម្រេច

បាន៨០%។ វិទ្យាល័យទី២ មានអ្នកចូលរួម១០នាក់ ស្មើនឹង១០០% បង្ហាញថាសាលារៀនរបស់ខ្លួនអនុវត្តបាន៦១%។ វិទ្យាល័យទី៣ មានអ្នកចូលរួម១២នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ៥០%។ វិទ្យាល័យទី៤ មានអ្នកចូលរួម១១នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ៣១%។ វិទ្យាល័យទី៥ មានអ្នកចូលរួម១៤នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ២៨%។ វិទ្យាល័យទី៦ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ថាអនុវត្តសម្រេចបាន ២៦%។ វិទ្យាល័យទី៧ មានអ្នកចូលរួម១៣នាក់ ស្មើនឹង១០០% ថាអនុវត្តបាន ២៥% និងវិទ្យាល័យទី៨ ដែលមានអ្នកចូលរួម១៥នាក់ ស្មើនឹង១០០% ក៏បានបង្ហាញថាសាលារៀនរបស់ខ្លួនអនុវត្តសម្រេចបានត្រឹម២២%ប៉ុណ្ណោះ។

សរុបមកក្នុងសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈ បើពិនិត្យមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាវិទ្យាល័យទី១ អនុវត្តសម្រេចបានលទ្ធផលខ្ពស់ស្មើនឹង៨០% និងវិទ្យាល័យទី២សម្រេចបានលទ្ធផលល្អបង្គួរ គឺស្មើនឹង៦១% ចំណែកឯវិទ្យាល័យទី៣សម្រេចបានលទ្ធផលកម្រិតមធ្យមស្មើនឹង៥០%។ ខណៈដែលវិទ្យាល័យ៥ទៀត លទ្ធផលដែលសម្រេចបានមានកម្រិតទាបស្ថិតនៅក្រោម ៤០%។




*ក្រាហ្វទី ១៖ការអនុវត្តសកម្មភាពក្នុងការអភិវឌ្ឍវិជ្ជាជីវៈ (ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ)*

សរុបមកការអនុវត្តសកម្មភាពគោលទាំងបួន ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន បើពិនិត្យមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាសាលារៀនដែលបានរៀបចំផែនការ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធគឺអនុវត្តបានភាគរយខ្ពស់ជាងសាលារៀន ដែលរៀបចំដោយគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

## ៤.៣. បញ្ហាប្រឈមក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)

ក្រោយពីការវិភាគអ្នកស្រាវជ្រាវសង្កេតឃើញថាភាគច្រើននៃសកម្មភាពទាំងនោះអនុវត្តមិនបាន ១០០%នោះទេ បណ្តាលមកពីបញ្ហាប្រឈមជាច្រើន។ ផ្អែកតាមរូបទី៤.៩ បញ្ជាក់ថា សកម្មភាពអនុវត្តមិនបាន១០០% បណ្តាលមកពីកត្តាធំៗ៤គឺៈ **ទី១ គ្មានតម្លាភាពថវិកា** កត្តានេះមានអ្នកចូលរួម៦៩នាក់ស្មើនឹង៦៩%បញ្ជាក់ថា ជាទូទៅនៅដើមឆ្នាំសិក្សាគណៈគ្រប់គ្រងសាលា និងគណនេយ្យដឹងច្បាស់ពីចំនួនថវិកាដំណើរការសាលា និងធ្លាក់មកប៉ុន្មានដងក្នុងមួយឆ្នាំ ដូចនេះពួកគាត់បានរៀបចំគ្រោងសកម្មភាពទុកជាមុន តម្រូវទៅតាមចំនួនថវិកាដោយមានធ្វើវិក្កយបត្រចំណាយផ្សេងៗ ដោយពុំមានការអនុវត្តសកម្មភាពនោះឡើយ ឬសកម្មភាពខ្លះអនុវត្តបានបន្តិចបន្តួចប៉ុណ្ណោះ ដោយហេតុថាពុំមានថវិកាគ្រប់ គ្រាន់។ នៅពេលកញ្ចប់ថវិកានោះធ្លាក់មក គេអាចយកទៅចំណាយលើអ្វីក៏បាន ដោយពុំមានអ្នកផ្សេងដឹងក្រៅពីគណៈគ្រប់គ្រង និងគណនេយ្យនោះឡើយ។ **ទី២ កត្តាកង្វះសមត្ថភាព** មានអ្នកចូលរួម៦២នាក់ ស្មើនឹង៦២% បានលើកហេតុផលមួយចំនួនដូចជាគ្មានជំនាញរៀបចំផែនការ មិនយល់ពីដំហាន និងការវិភាគស្ថានភាពអប់រំ។ ម៉្យាងទៀតដោយសារជាផែនការថ្មី ពុំធ្លាប់បានទទួលការបណ្តុះបណ្តាលពីមុនមក។ **ទី៣ ខ្វះការគាំទ្រ និងសហការចូលរួម** កត្តានេះមានអ្នកចូលរួមឆ្លើយ ៦០នាក់ ស្មើនឹង៦០% ដោយផ្អែកលើហេតុផលមួយចំនួន មិនមានការប្រជុំលើកផែនការសកម្មភាព និងផ្សព្វផ្សាយពីផែនការដល់គ្រប់ភាគីពាក់ព័ន្ធ ដោយឃើញតែសកម្មភាពគេអនុវត្តស្រាប់ សហគមន៍ហាក់ពុំសូវយកចិត្តទុកដាក់នឹងសកម្មភាពរបស់សាលារៀន និង**ទី៤កត្តាថវិកាធ្លាក់យឺត** មានអ្នកចូលរួម ៦០នាក់ ស្មើនឹង៦០% ផ្អែកលើហេតុផលខ្វះខាតថវិកា ថវិកាដំណើរការសាលារៀនទម្លាក់មកមានការយឺតយ៉ាវ ដែលត្រូវផ្អាកការអនុវត្តសកម្មភាពដោយរង់ចាំថវិកា ចំណូលពីសប្បុរសជនមានចំនួនតិចតួច។

សរុបមកកត្តាដែលធ្វើឱ្យការអនុវត្តសកម្មភាព ក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ក្នុងក្រខ័ណ្ឌទូទាំងខេត្ត មិនបានសម្រេច ១០០% ដោយសារកត្តាគ្មានតម្លាភាពថវិកា កត្តាកង្វះសមត្ថភាពក្នុងការរៀបចំ និងអនុវត្តផែនការខ្វះការសហការចូលរួម និងកត្តាថវិកាធ្លាក់យឺត។




*ក្រាហ្វទី 10៖ បញ្ហាប្រឈមក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ(ក្របខ័ណ្ឌទូទាំងខេត្ត)*

### ៤.៣.១. បញ្ហាប្រឈមកត្តាគ្មានតម្លាភាពថវិកា (ក្របខ័ណ្ឌសាលានីមួយៗ)

ចំណុចខាងលើយើងបានវិភាគទៅលើបញ្ហាប្រឈម ក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ពុំទទួលបានជោគជ័យ១០០% ដែលអ្នកចូលរួមទាំងអស់បានលើកឡើងក្នុងក្របខ័ណ្ឌទូទាំងខេត្ត ដោយផ្តោតទៅលើកត្តា៤គឺ៖ កត្តាគ្មានតម្លាភាពថវិកា កង្វះសមត្ថភាព ខ្វះការចូលរួម និងកត្តាថវិកាធ្លាក់យឺត។ ផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការវិភាគទៅលើកត្តាបញ្ហាប្រឈមនីមួយៗ ក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ថាតើសាលារៀនណាខ្លះដែលមានបញ្ហាប្រឈមខ្លាំងជាងគេ និងសាលាណាខ្លះដែលមានបញ្ហាប្រឈមតិចតួច។

ផ្អែកតាមរូបភាពទី៤.១០ ខាងក្រោមបង្ហាញថា កត្តាគ្មានតម្លាភាពថវិកាបើមើលជារួមក្នុងក្របខ័ណ្ឌទូទាំងខេត្តមាន ៦៩%។ ប៉ុន្តែបើពិនិត្យមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗវិញ ឃើញថា

វិទ្យាល័យទី១ បញ្ហាប្រឈមនេះមានត្រឹម ២៤% វិទ្យាល័យទី២ មាន២៦% វិទ្យាល័យទី៣ មាន២៩% វិទ្យាល័យទី៤ មានបញ្ហាប្រឈមខ្ពស់រហូតដល់៨៩% វិទ្យាល័យទី៥ មាន៩២% វិទ្យាល័យទី៦ មាន ៩៦% វិទ្យាល័យទី៧ និងវិទ្យាល័យទី៨ មានបញ្ហាប្រឈមខ្ពស់រហូតដល់ ៩៨%។ សរុបមកបញ្ហាប្រឈមទាក់ទងទៅលើកត្តាគ្មានតម្លាភាពថវិកា បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាក៏មានសាលារៀនបីផងដែរ ដែលមានបញ្ហាប្រឈមតិចតួចត្រឹមក្រោម ៣០%ប៉ុណ្ណោះ។ ចំណែកឯសាលារៀន៥ ផ្សេងទៀតមានបញ្ហាប្រឈមកម្រិតខ្ពស់រហូតដល់ជាង៨០%។




*ក្រាហ្វទី 11៖ បញ្ហាប្រឈមកត្តាគ្មានតម្លាភាពថវិកា (ក្របខ័ណ្ឌសាលានីមួយៗ)*

### ៤.៣.២. បញ្ហាប្រឈមកត្តាកង្វះសមត្ថភាព (ក្របខ័ណ្ឌសាលានីមួយៗ)

ផ្អែកតាមរូបភាពទី៤.១១ខាងក្រោម បង្ហាញថាកត្តាកង្វះសមត្ថភាព ក្នុងការអនុវត្តផែនការ បើមើលជារួមក្នុងក្របខ័ណ្ឌទូទាំងខេត្តមាន៦២%។ ប៉ុន្តែបើពិនិត្យមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗវិញ ឃើញថា វិទ្យាល័យទី១ បញ្ហាប្រឈមនេះមានត្រឹម១៥% វិទ្យាល័យទី២ មាន១៨% វិទ្យាល័យទី៣ មាន

២៥% វិទ្យាល័យទី៤ មានបញ្ហាប្រឈមខ្ពស់រហូតដល់៧៨% វិទ្យាល័យទី៥ មាន៨៧% វិទ្យាល័យទី៦ មាន៨៨% វិទ្យាល័យទី៧ មាន៩១% និងវិទ្យាល័យទី៨ មានបញ្ហាប្រឈមខ្ពស់ជាងគេរហូតដល់៩៤%។ សរុបមកបញ្ហាប្រឈមទាក់ទងទៅលើកត្តាកង្វះសមត្ថភាព ក្នុងការអនុវត្តផែនការ បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗឃើញថា ក៏មានសាលារៀនចំនួនបីផងដែរ ដែលមានបញ្ហាប្រឈមតិចតួចត្រឹមក្រោម ២៥%ប៉ុណ្ណោះ។ ចំណែកឯសាលារៀន៥ ទៀតមានបញ្ហាប្រឈមកម្រិតខ្ពស់រហូតដល់ជាង៧៨%។




*ក្រាហ្វទី 12៖ បញ្ហាប្រឈមកត្តាកង្វះសមត្ថភាព (ក្របខ័ណ្ឌសាលានីមួយៗ)*

### ៤.៣.៣. បញ្ហាប្រឈមកត្តាខ្វះការចូលរួម (ក្របខ័ណ្ឌសាលានីមួយៗ)

ផ្អែកតាមរូបភាពទី ៤.១២ ខាងក្រោមបង្ហាញថា កត្តាខ្វះការចូលរួម បើមើលជារួមក្នុងក្របខ័ណ្ឌទូទាំងខេត្តមាន៦០%។ ប៉ុន្តែបើពិនិត្យមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗវិញឃើញថា វិទ្យាល័យទី១ និងទី២ មានបញ្ហាប្រឈមនេះត្រឹម ៨% វិទ្យាល័យទី៣ មាន៩% វិទ្យាល័យទី៤ មានបញ្ហាប្រឈមខ្ពស់រហូតដល់ ៨៨% វិទ្យាល័យទី៥ មាន៩០% វិទ្យាល័យទី៦ មាន៩១% វិទ្យាល័យទី៧ មាន៩២% និងវិទ្យាល័យទី៨ មានបញ្ហាប្រឈមខ្ពស់ជាងគេរហូតដល់៩៤%។ សរុបមកបញ្ហាប្រឈមទាក់ទងទៅលើកត្តាខ្វះការចូលរួម បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាក៏មានសាលារៀនបីផងដែរ ដែល

មានបញ្ហាប្រឈមកម្រិតទាបត្រឹមក្រោម៩%ប៉ុណ្ណោះ។ ចំណែកឯសាលារៀន៥ ទៀតមានបញ្ហាប្រឈមកម្រិតខ្ពស់រហូតដល់ជាង៨៨%។




*ក្រាហ្វទី 13៖ បញ្ហាប្រឈមកត្តាខ្វះការចូលរួម (ក្របខ័ណ្ឌសាលានីមួយៗ)*

### ៤.៣.៤. បញ្ហាប្រឈមកត្តាថវិកាធ្លាក់យឺត (ក្របខ័ណ្ឌសាលានីមួយៗ)

ផ្អែកតាមរូបភាពទី៤.១៣ ខាងក្រោមបង្ហាញថា កត្តាថវិកាធ្លាក់យឺត បើមើលជារួមក្នុងក្របខ័ណ្ឌទូទាំងខេត្តមាន៦០%។ ប៉ុន្តែបើយើងមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗវិញឃើញថា វិទ្យាល័យទី១ មានបញ្ហាប្រឈមនេះ ត្រឹម៣៨% វិទ្យាល័យទី២ មាន៤០% វិទ្យាល័យទី៣ មាន៤២% វិទ្យាល័យទី៤ មានបញ្ហាប្រឈមខ្ពស់រហូតដល់ ៦៥% វិទ្យាល័យទី៥ មាន៦៨% វិទ្យាល័យទី៦ មាន៧៣% វិទ្យាល័យទី៧ មាន៧៥% និងវិទ្យាល័យទី៨ មានបញ្ហាប្រឈមនេះខ្ពស់ជាងគេរហូតដល់៧៩%។ សរុបមកបញ្ហាប្រឈមទាក់ទងទៅលើកត្តាថវិកាធ្លាក់យឺត បើមើលក្នុងក្របខ័ណ្ឌសាលារៀននីមួយៗ ឃើញថាក៏មានសាលារៀនបីផងដែរ ដែលមានបញ្ហាប្រឈមកម្រិតទាបត្រឹមក្រោម៤២%ប៉ុណ្ណោះ។ ចំណែកឯសាលារៀន៥ ទៀតមានបញ្ហាប្រឈមកម្រិតខ្ពស់រហូតដល់លើ៦៥%។




*ក្រាហ្វទី 14៖ បញ្ហាប្រឈមកត្តាថវិកាធ្លាក់យឺត (គ្រប់ខ័ណ្ឌសាលានីមួយៗ)*

## ៤.៤. តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ( គ្រប់ខ័ណ្ឌទូទាំងខេត្ត )

ក្រោយពីបានធ្វើការសិក្សា និងវិភាគពីស្ថានភាពនៃការរៀបចំ និងការអនុវត្តផែនការរួចមក អ្នកស្រាវជ្រាវអាចកំណត់បានថា ការរៀបចំផែនការតែលើបុគ្គលមួយក្រុមតូចតែប៉ុណ្ណោះ ពុំមានលក្ខណៈជាយុទ្ធសាស្ត្រ មិនមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនោះទេគឺមិនសូវអនុវត្តតាមការរំពឹងទុកនោះទេ។ ចំណែកឯការអនុវត្តផែនការតាមសកម្មភាពនីមួយៗ គឺសាលារៀនទាំងអស់សម្រេចបានត្រឹមកម្រិតមធ្យមប៉ុណ្ណោះ ដោយសារមានបញ្ហាប្រឈមជាច្រើនពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តផែនការ ជាពិសេសកត្តាសមត្ថភាព ការយល់ដឹងពីជំហានផ្សេងៗក្នុងការរៀបចំផែនការ និងការវិភាគពីស្ថានភាពវិស័យអប់រំ។ ដោយមើលឃើញពីបញ្ហាប្រឈម និងកម្រិតសមត្ថភាពខ្វះការយល់ដឹងពាក់ព័ន្ធទៅនឹងការរៀបចំ និងការអនុវត្តផែនការនេះហើយទើបផ្នែកនេះអ្នកស្រាវជ្រាវនឹងធ្វើការសិក្សានិងកំណត់ពីតម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំរបស់អ្នកចូលរួមទាំងអស់ ថាតើមាន

ចំនួនប៉ុន្មាននាក់ដែលត្រូវការបណ្តុះ

បណ្តាល និង បណ្តុះបណ្តាលសមត្ថភាពទៅលើចំណុចណាខ្លះ ក្នុងក្របខ័ណ្ឌទូទាំងខេត្ត។

ជាការពិតណាស់ អ្នកចូលរួមមានតម្រូវការបណ្តុះបណ្តាលច្រើនផ្សេងៗគ្នាទៅតាមសកម្មភាពនីមួយៗ។ អ្នកស្រាវជ្រាវបានរៀបចំបណ្តុំសកម្មភាពទាំងអស់នោះទៅជា៥ផ្នែកធំៗគឺៈ (១) របៀបទាក់ទាញសហគមន៍ឱ្យមានការចូលរួម (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង (៥) ការអនុវត្តផែនការ ។ ម៉្យាងទៀត អ្នកស្រាវជ្រាវក៏បានកំណត់សមត្ថភាពដែលត្រូវការបណ្តុះបណ្តាលទាំងនោះ ទៅតាមចំនួនអ្នកចូលរួម ថាតើសកម្មភាពណាមានអ្នកចូលរួមច្រើនជាងគេគឺជាលំដាប់អាទិភាពទី១។ យោងតាមរូបភាពទី៤.១៤ បង្ហាញថារបៀបទាក់ទាញសហគមន៍ឱ្យមានការចូលរួម មានអ្នកចង់ចេះចង់ដឹងច្រើនជាងគេរហូតដល់៩៥នាក់ ស្មើនឹង៩៥% ជាអាទិភាពទីមួយដែលអ្នកចូលរួមត្រូវការបណ្តុះបណ្តាលចាំបាច់។ ការវិភាគវិស័យអប់រំជាសកម្មភាពអាទិភាពទីពីរ ដែលមានអ្នកចូលរួមច្រើនបន្ទាប់គឺ ៩៤នាក់ស្មើនឹង៩៤%។ ជំហានក្នុងការរៀបចំផែនការ ជាសកម្មភាពអាទិភាពទីបីដែលមានអ្នកចូលរួម៩២នាក់ស្មើនឹង៩២%។ ការពិនិត្យតាមដាន និងវាយតម្លៃផែនការ ជាសកម្មភាពអាទិភាពទីបួន ដែលអ្នកចូលរួមត្រូវពង្រឹងសមត្ថភាពបន្ថែមមាន៩០នាក់ ស្មើនឹង៩០%។ ចំណែកឯការអនុវត្តផែនការជាអាទិភាពចុងក្រោយដែលអ្នកចូលរួមត្រូវការបណ្តុះបណ្តាលបន្ថែមមាន៩០នាក់ ស្មើនឹង៩០%។

សរុបមកគ្រប់សកម្មភាពទាំងអស់ក្នុងក្របខ័ណ្ឌទាំង៨ វិទ្យាល័យទូទាំងខេត្តស្វាយរៀងមានអ្នកចូលរួមត្រូវការបណ្តុះបណ្តាលសមត្ថភាពបន្ថែមលើ ៩០% ដោយផ្តោតលើ៥ចំណុចគឺៈ (១) របៀបទាក់ទាញសហគមន៍ឱ្យមានការចូលរួម (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង(៥) ការអនុវត្តផែនការ។




*ក្រាហ្វទី 15៖ តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ(ក្របខ័ណ្ឌទូទាំងខេត្ត)*

## ៤.៥. ការពិភាក្សា

ផ្នែកនេះយើងនឹងធ្វើការពិភាក្សាទៅលើលទ្ធផលសំខាន់ៗដែលបានរកឃើញ តាមរយៈការសិក្សាស្រាវជ្រាវ ដោយធ្វើការវិភាគរវាងលទ្ធផលដែលទទួលបានដោយផ្អែកទៅលើទ្រឹស្តី ថាតើលទ្ធផល និងទ្រឹស្តីមានលក្ខណៈឆ្លើយតបគ្នា ឬមានលក្ខណៈផ្ទុយគ្នា។ លទ្ធផលដែលត្រូវយកមកធ្វើការពិភាក្សាផ្តោតលើបីចំណុចគឺ៖ ស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និងតម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ។

### ៤.៥.១. ស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនេះ បើយោងតាមទ្រឹស្តីដែលបានលើកឡើងក្នុងជំពូកទី២ការរៀបចំផែនការគឺជាដំណើរការឥតឈប់ឈរ មិនត្រឹមតែជាកន្លែងមួយដែលត្រូវទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិធីដើម្បីទៅដល់ទីនោះទៀតផង និងត្រូវទៅផ្លូវណាមួយដែលល្អបំផុត។ វាមានជំហានផ្សេងៗគ្នាដែលអ្នករៀបចំផែនការគួរតែអនុវត្តតាមការរៀបចំផែនការ បង្កើតជាការចាប់ផ្តើមនូវសកម្មភាពជាក់លាក់ការ

ឆ្លងកាត់ជំហាននីមួយៗ ជួយរៀបចំដើម្បីកំណត់ទុកជាមុននូវអ្វីដែលជាតម្រូវការ និងអ្វីដែលត្រូវធ្វើ ហើយថាតើត្រូវធ្វើរបៀបណាដើម្បីអាចឈានទៅសម្រេចគោលដៅ។ ដើម្បីសម្រេចបានតាមគោលដៅ និងវត្ថុបំណងរបស់ផែនការ ការរៀបចំគឺត្រូវមានលក្ខណៈជាយុទ្ធសាស្ត្រ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ (វិទ្យាស្ថានជាតិអប់រំ, ឆ្នាំ២០១៧)។ យោងតាមលទ្ធផលរូបទី៤.១ បានកំណត់ពីសមាសភាពចូលរួមរៀបចំផែនការ និងលើកសកម្មភាពរបស់សាលារៀនជាបួនចំណុចធំៗគឺទី១៖ ខ្ញុំលើកខ្លួនឯង ក្នុងចំណោមអ្នកចូលរួមឆ្លើយ ១០០នាក់ ស្មើនឹង១០០% មាន ២នាក់ ស្មើនឹង២% បានឆ្លើយថា ខ្ញុំលើកខ្លួនឯង នៅចំណុចទី១។ ចំណែកឯចំណុចទី២ មានការប្រជុំមន្ត្រីក្នុងការិយាល័យខ្ញុំរួចឯកភាពគ្នាលើកផែនការសកម្មភាពទាំងនេះ មានអ្នកចូលរួម ២៦នាក់ ស្មើនឹង២៦%។ ដោយឡែកចំណុចទី៣ ដែលមាននាយក នាយករង និងគណនេយ្យជាអ្នកលើកផែនការសកម្មភាពទាំងនេះ មានអ្នកចូលរួមឆ្លើយដល់ទៅ ៦០នាក់ ស្មើនឹង៦០% និងចំណុចទី៤ ថ្នាក់លើជាអ្នកលើកសកម្មភាពទាំងនេះឱ្យ មានអ្នកចូលរួមឆ្លើយតែ១២នាក់ ស្មើនឹង១២%ប៉ុណ្ណោះ។ បើតាមការវិភាគយើងសង្កេតឃើញថា ចំពោះចំណុចទីពីរដែលមានសមាសភាពលើកសកម្មភាពដោយមានការចូលរួម មានការប្រជុំមន្ត្រីក្នុងការិយាល័យ ឬអង្គភាពរួចឯកភាពគ្នារៀបចំផែនការ និងលើកសកម្មភាពទាំងឡាយឡើង ជាចំណុចល្អមួយស្របជាមួយផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងជាពិសេសឆ្លើយតបទៅនឹងទ្រឹស្តីនៃការរៀបចំផែនការ គឺតម្រូវឱ្យមានការចូលរួម និងប្រជុំមន្ត្រី ឬបុគ្គលិកនៅក្នុងអង្គភាពទាំងអស់ ដើម្បីសម្រេចលើកផែនការសកម្មភាព ទើបធ្វើឱ្យការរៀបចំផែន ការស្របតាមបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន។ ប៉ុន្តែមានអ្នកចូលរួមឆ្លើយតែ២៦នាក់ ស្មើនឹង២៦%តែប៉ុណ្ណោះ ក្នុងចំណោមអ្នកចូលរួម១០០នាក់ ដែលនៅមានកម្រិតទាបនៅឡើយ ទាមទារឱ្យមានការយល់ដឹង និងកែលម្អបន្ថែមពាក់ព័ន្ធនឹងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន តាមរយៈគម្រោងបណ្តុះបណ្តាលផ្សេងៗ។ ផ្ទុយទៅវិញចំណុចទីបីដែលមាននាយកនាយករង និងគណនេយ្យជាអ្នកលើកផែនការ និងសកម្មភាពរបស់សាលារៀនមានអ្នកចូលរួមឆ្លើយច្រើនជាងគេ ស្មើនឹង៦០% ដែលបញ្ជាក់ឱ្យឃើញថា ការរៀបចំផែនការ និងលើកផែនការសកម្មភាពនានា នៅតាមវិទ្យាល័យក្នុងខេត្តស្វាយរៀង មិនមានលក្ខណៈជាយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ

ដោយមានតែសមាសភាពចូលរួមតែភាគីមួយក្រុមតូចប៉ុណ្ណោះគឺគណៈគ្រប់គ្រង និងគណនេយ្យ ដែលពុំទាន់ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងទ្រឹស្តីដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍រួមទាំងដៃគូអភិវឌ្ឍន៍នានា ដើម្បីឱ្យមានការចូលរួមគាំទ្រ ទើបការរៀបចំផែនការទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព។

សរុបមកការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ នៅក្នុងក្របខ័ណ្ឌទាំង៨វិទ្យាល័យទូទាំងខេត្តស្វាយរៀងមិនទាន់បានល្អ មិនមានជាលក្ខណៈយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនោះទេ ដោយសារការរៀបចំធ្វើឡើងតែភាគីមួយក្រុមតូចប៉ុណ្ណោះ ដែលមិនបានឆ្លើយតបទៅនឹងទ្រឹស្តី នៃការរៀបចំផែនការ។

## ៤.៥.២. ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

បើយោងតាមទ្រឹស្តី ការអនុវត្តផែនការ គឺជាជំណាក់កាលប្រតិបត្តិនៃកម្មវិធីដែលបានគ្រោងទុក។ វាកំពុងតែដាក់បង្ហាញនៅលើផ្លូវដែលបានរៀបចំរួចជាស្រេចសម្រាប់ដើរ ឬជាដំណើរការសកម្មភាពកំណែទម្រង់ដែលបានរៀបចំផែនការគ្រោងទុកជាមុន។ ការអនុវត្តផែនការបានជោគជ័យឬអត់ គឺអាស្រ័យលើការរៀបចំផែនការបានត្រឹមត្រូវ មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ(Ornstein and Hunkins, 1998) ។

ផ្អែកតាមតារាងទី៥ បង្ហាញថាសកម្មភាពសរុបនៃការជួសជុល និងសាងសង់អនុវត្តសម្រេចបានបាន ៦០% ការកែលម្អបរិស្ថានអនុវត្តបាន ៥៦% ការរៀន និងបង្រៀនសម្រេចបាន ៥១% និងការអភិវឌ្ឍវិជ្ជាជីវៈអនុវត្តបាន៤០%។ ដូចនេះ យើងអាចសន្និដ្ឋានបានថា ក្នុងក្របខ័ណ្ឌទាំង៨វិទ្យាល័យ ក្នុងខេត្តស្វាយរៀង ការអនុវត្តសកម្មភាពទាំងអស់សម្រេចបានត្រឹមកម្រិតមធ្យមប៉ុណ្ណោះ រីឯការអនុវត្តទៀតសោតគឺបានផ្តោតការយកចិត្តទុកដាក់តែទៅលើសកម្មភាពនៃការជួសជុល និងសាងសង់ជាអាទិភាពទី១ ដែលភាគរយក្នុងការអនុវត្តបានខ្ពស់ជាងគេស្មើនឹង៦០%។ ការកែលម្អបរិស្ថានជាអាទិភាពទី២អនុវត្តបានស្មើនឹង៥៦% ចំណែកឯទាក់ទងទៅនឹងការរៀន និងបង្រៀនអនុវត្តបាន៥១% និងការអភិវឌ្ឍវិជ្ជាជីវៈអនុវត្តបាន៤០% ជាអាទិភាពចុងក្រោយ ដែលសកម្មភាពសម្រេចបានមានភាគរយតិចជាងទេ។

សរុបមកការអនុវត្តផែនការក្នុងក្របខ័ណ្ឌ៨វិទ្យាល័យទូទាំងខេត្តស្វាយរៀងមិនទាន់បានលទ្ធផលល្អនោះទេ សម្រេចបានត្រឹមក្រោម៦០%ប៉ុណ្ណោះ ដែលមិនឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងទ្រឹស្តីនៃការអនុវត្តផែនការនោះទេ ដោយសារទាក់ទងទៅនឹងការរៀបចំផែនការគ្មានលក្ខណៈយុទ្ធសាស្ត្រ និងគ្មានការចូលរួម។ កត្តាសមត្ថភាពនៅមានកម្រិតទាប អ្នកចូលរួមអនុវត្តពុំទាន់មានមូលដ្ឋានគ្រឹះច្បាស់លាស់ក្នុងការកសាងផែនការដ៏ល្អមួយ មិនយល់ច្បាស់ពីជំហាននីមួយៗរបស់ផែនការ និងមិនបានធ្វើហេតុវិនិច្ឆ័យពីស្ថានភាពអប់រំឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយមុននឹងរៀបចំផែនការ។

### ៤.៥.៣. តម្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ

ដោយសារស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន មិនបានត្រឹមត្រូវ គ្មានលក្ខណៈជាយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងការអនុវត្តសកម្មភាពនានាមិនសម្រេចបានជោគជ័យ១០០% ទៅតាមចំណុចដៅ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ទើបផ្នែកនេះ អ្នកស្រាវជ្រាវនឹងធ្វើការពិភាក្សាទៅលើលទ្ធផលនៃតម្រូវការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់បុគ្គលិកអប់រំ ជាពិសេសគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនផ្នែកផែនការអប់រំ។

យោងតាមរូបទី៤.១៤ បង្ហាញថាសមត្ថភាពដែលអ្នកចូលរួមត្រូវការពង្រឹងបន្ថែមគឺទី១ របៀបទាក់ទាញសហគមន៍ឱ្យមានការចូលរួម មានអ្នកចូលរួមច្រើនជាងគេរហូតដល់ ៩៥នាក់ ស្មើនឹង៩៥%។ ទី២ ការវិភាគវិស័យអប់រំ មានអ្នកចូលរួម៩៤នាក់ ស្មើនឹង៩៤%។ ទី៣ ជំហានការរៀបចំផែនការ មានអ្នកចូលរួម៩២នាក់ ស្មើនឹង៩២%។ ទី៤ ការពិនិត្យតាមដាន និងវាយតម្លៃផែនការ មានអ្នកចូលរួម៩០នាក់ ស្មើនឹង៩០%។ ចំណែកឯ ទី៥ការអនុវត្តផែនការ ជាចំណុចចុងក្រោយដែលអ្នកចូលរួមត្រូវការបណ្តុះបណ្តាលបន្ថែមមាន ៩០នាក់ ស្មើនឹង៩០%។

សរុបមកគ្រប់សកម្មភាពទាំងអស់ក្នុងក្របខ័ណ្ឌទាំង ៨ វិទ្យាល័យទូទាំងខេត្តស្វាយរៀងមានអ្នកចូលរួមត្រូវការបណ្តុះបណ្តាលសមត្ថភាពបន្ថែមលើ ៩០% ដោយផ្តោតលើ៥ចំណុចគឺ៖ (១) របៀបទាក់ទាញសហគមន៍ឱ្យមានការចូលរួម (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤)

ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង(៥) ការអនុវត្តផែនការ ។ ដូចនេះ បញ្ជាក់ឱ្យឃើញថា អ្នកចូលរួមទាំងអស់មានគោលបំណង និងឆន្ទៈមោះមុត ក្នុងការទទួលបាននូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ ដើម្បីចូលរួមរៀបចំ និងអនុវត្តផែនការរបស់សាលារៀនឱ្យមានការរីកចម្រើនប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ប្រកបដោយគុណភាព និងប្រសិទ្ធភាពដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសាលារៀនឱ្យមានការរីកចម្រើន ពីមួយឆ្នាំទៅមួយឆ្នាំ ទាំងហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន អនាម័យ ការដឹកនាំ និងគ្រប់គ្រង ការរៀន និងបង្រៀន ព្រមទាំងលទ្ធផលសិក្សារបស់សិស្សផងដែរ។ ដើម្បីរៀបចំផែនការមួយឱ្យឆ្លើយតបទៅនឹងតម្រូវការសង្គម គោលនយោបាយរបស់រាជរដ្ឋាភិបាល គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមទាំងបញ្ហាប្រឈម និងតម្រូវការជាក់ស្តែងរបស់សាលារៀន ទាមទារឱ្យមានការរៀបចំទៅតាមជំហានត្រឹមត្រូវ ធ្វើហេតុវិនិច្ឆ័យវិស័យអប់រំឱ្យបានច្បាស់លាស់ ជាពិសេសគឺត្រូវបង្កឱ្យមានការចូលរួមរៀបចំយ៉ាងទូលំទូលាយ ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដោយប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ ផលប៉ះពាល់ កំណត់បញ្ហាប្រឈមជាអាទិភាព និងធ្វើការរួមគ្នាក្នុងការស្វែងរកដំណោះស្រាយសមស្រប។ ការសហការគ្នាក្នុងការរៀបចំ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយពីផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ការអនុវត្តសកម្មភាពនានា និងលទ្ធផលសម្រេចបាន ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងទំនុកចិត្ត សាមគ្គីភាពផ្ទៃក្នុង កិច្ចសហការ និងស្វែងរកការគាំទ្រពីអ្នកពាក់ព័ន្ធនានាយ៉ាងមានប្រសិទ្ធភាព ដើម្បីអភិវឌ្ឍសាលារៀនឱ្យមានការរីកចម្រើនទៅមុខជាលំដាប់។ ហេតុដូច្នេះហើយបានជាអ្នកស្រាវជ្រាវកំណត់យកប្រធានបទមួយស្តីពី "ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន" មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណង (១) កំណត់ពីស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន (២) កំណត់ពីស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន និង (៣) កំណត់ពីតម្រូវការបណ្តុះបណ្តាលលើជំនាញរៀបចំផែនការអប់រំនៅកម្រិតសាលារៀន។

ឆ្លើយតបទៅនឹងសំណួរ និងគោលបំណងនៃការស្រាវជ្រាវដែលទាក់ទងនឹងស្ថានភាពនៃការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន នៅតាមវិទ្យាល័យគោលដៅនានាក្នុងខេត្តស្វាយរៀង ដោយ

ផ្អែកទៅតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនក្នុងក្របខ័ណ្ឌទូទាំងខេត្ត មិនទាន់បានល្អនៅឡើយទេ ដោយការរៀបចំពុំមានលក្ខណៈជាយុទ្ធសាស្ត្រ គ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ពុំឆ្លើយតបទៅនឹងបញ្ហាប្រឈម តម្រូវការជាក់ស្តែងរបស់សាលារៀន និងមិនឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ព្រោះចំនួនអ្នកចូលរួមឆ្លើយ៦០%បញ្ជាក់ថា ការរៀបចំផែនការគឺធ្វើឡើងតែនាយក នាយករង និងគណនេយ្យដោយពុំមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ចំណែកឯការលើកសកម្មភាពដោយមានការចូលរួមប្រជុំមន្ត្រីក្នុងការិយាល័យ រួចឯកភាពគ្នាលើកសកម្មភាព មានអ្នកចូលរួមតែ ២៦%ប៉ុណ្ណោះ ដែលជាហេតុធ្វើឱ្យការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំពុំទាន់មានប្រសិទ្ធភាព។

ចំណែកឯការអនុវត្តផែនការក្នុងក្របខ័ណ្ឌទូទាំងខេត្តស្វាយរៀង ក៏ពុំទាន់ទទួលបានលទ្ធផលល្អប្រសើរផងដែរ ដោយសម្រេចបានក្រោម៦០%ប៉ុណ្ណោះ។ ប៉ុន្តែបើពិនិត្យក្នុងក្របខ័ណ្ឌសាលារៀនវិញ សាលាដែលធ្វើផែនការដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ គឺអនុវត្តបានភាគរយខ្ពស់ជាងសាលាដែលរៀបចំដោយគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ដូចនេះជារួមគឺលទ្ធផលមិនទាន់ឆ្លើយតបទៅនឹងគោលនយោបាយអប់រំនោះទេ ដោយសារទាក់ទងទៅនឹងការរៀបចំផែនការគ្មានលក្ខណៈយុទ្ធសាស្ត្រ គ្មានការចូលរួម កត្តាសមត្ថភាពនៅមានកម្រិតទាប អ្នកចូលរួមអនុវត្តពុំទាន់មានមូលដ្ឋានគ្រឹះច្បាស់លាស់ក្នុងការកសាងផែនការដ៏ល្អមួយ មិនយល់ច្បាស់ពីជំហាននីមួយៗរបស់ផែនការ និងមិនបានធ្វើហេតុវិនិច្ឆ័យពីស្ថានភាពអប់រំឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយមុននឹងរៀបចំផែនការ។

ដោយឡែក ផ្នែកតម្រូវការបណ្តុះបណ្តាលសមត្ថភាពបន្ថែមក្នុងក្របខ័ណ្ឌទូទាំងខេត្ត មានអ្នកចូលរួមលើ៩០% ដែលត្រូវការបណ្តុះបណ្តាលផ្នែកផែនការអប់រំ ទៅលើ៥ចំណុចគឺៈ (១) របៀបទាក់ទាញសហគមន៍ (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង(៥) ការអនុវត្តផែនការ ដែលបញ្ជាក់ឱ្យឃើញថា អ្នកចូលរួមទាំងអស់មានគោលបំណង និងឆន្ទៈមោះមុត ក្នុងការទទួលបាននូវការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ដើម្បីចូលរួម

រៀបចំ និងអនុវត្តផែនការរបស់សាលារៀនឱ្យមានការរីកចម្រើនប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

សរុបមកការរៀបចំផែនការនៅកម្រិតសាលារៀនមិនទាន់បានល្អនៅឡើយទេ ដោយការរៀបចំគ្មានលក្ខណៈជាយុទ្ធសាស្ត្រ និងគ្មានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ចំណែកឯការអនុវត្តផែនការក៏ពុំទាន់បានល្អប្រសើរផងដែរ ដោយសារមិនបានអនុវត្តតាមនីតិវិធីត្រឹមត្រូវ ការរៀបចំផែនការគ្មានការចូលរួម កង្វះសមត្ថភាពក្នុងការអនុវត្ត។ ប៉ុន្តែទោះបីជាយ៉ាងណាក្តីអ្នកចូលរួមភាគច្រើនលើ៩០% បានបង្ហាញពីតម្រូវការនៃការបណ្តុះបណ្តាលទៅលើផ្នែកផែនការអប់រំ ដើម្បីជាគ្រឹះក្នុងការរៀបចំផែនការដ៏ល្អមួយប្រកបដោយប្រសិទ្ធភាព និងស្របទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជានាឱ្យសាលារៀនមានការអភិវឌ្ឍ លទ្ធផលសិក្សារបស់សិស្សមានការកើនឡើង និងការអប់រំប្រកបដោយប្រសិទ្ធភាព និងគុណភាព។

អ្នកស្រាវជ្រាវមានជំនឿជាក់យ៉ាងមុតមាំថាតាមរយៈការសិក្សាស្រាវជ្រាវមួយនេះ អាចជំរុញ និងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ដើម្បីបង្កើតផែនការមួយដែលមានលក្ខណៈសមស្របទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលដៅអប់រំជាតិ តម្រូវការទីផ្សារ ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាប្រឈម តម្រូវការចាំបាច់របស់សាលារៀន និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។ យើងខ្ញុំក៏សង្ឃឹមផងដែរថាសាលារៀននឹងបង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ខ្លួនមួយ ដែលទទួលបានការគាំទ្រពេញទំហឹងពីគ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងចូលរួមអនុវត្តប្រកបដោយតម្លាភាព គណនេយ្យភាព និងសម្រេចបាននូវលទ្ធផលជោគជ័យត្រចះត្រចង់ដែលធ្វើឱ្យសាលារៀនមានការរីកចម្រើនជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។

## ៥.២. សំណូមពរ

តាមរយៈការសិក្សាស្រាវជ្រាវនេះ ខ្ញុំយល់ឃើញថាស្ថានភាពនៃការរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន កំពុងជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដែលត្រូវយកចិត្តទុកដាក់បន្ថែមក្នុងការកែលម្អ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវលើប្រធានបទ "ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន" យើងខ្ញុំសង្កេតឃើញថា ដំណើរការរៀបចំ និងអនុវត្តមិនទាន់បានត្រឹមត្រូវតាមនីតិវិធី និងឆ្លើយតបទៅនឹងគោលនយោបាយដែលក្រសួងបានកំណត់នោះទេ។ អាស្រ័យហេតុនេះ យើងខ្ញុំដែលជាអ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួនដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមមាន៖ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ សាលារៀន និងសហគមន៍ មេត្តាចូលរួមឱ្យបានសកម្មដើម្បីគាំទ្រដល់ការរៀបចំ និងការអនុវត្តផែនការរបស់សាលារៀនឱ្យបានល្អប្រសើរ។

- **ក្រសួងអប់រំ យុវជន និងកីឡា**
  - ផ្តល់វគ្គបណ្តុះបណ្តាលលើផ្នែក (១) របៀបទាក់ទាញសហគមន៍ (២) ការវិភាគវិស័យអប់រំ (៣) ជំហានក្នុងការរៀបចំផែនការ (៤) ការពិនិត្យតាមដាន និងវាយតម្លៃផែនការ និង(៥) ការអនុវត្តផែនការទៅដល់គណៈគ្រប់គ្រងសាលារៀន
  - បង្កើតកញ្ចប់ថវិកាទម្លាក់ដល់វិទ្យាល័យបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងបង្កើតយន្តការត្រួតពិនិត្យ និងតាមដានឱ្យបានហ្មត់ចត់ និងច្បាស់លាស់ទៅលើការប្រើប្រាស់ថវិការបស់សាលារៀន
  - ទម្លាក់ថវិកាឱ្យបានទាន់ពេលវេលា ដើម្បីឱ្យសាលារៀន អនុវត្តសកម្មភាពនានាបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព។
- **មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត**
  - មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តគួរតែចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីដំណើរការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀនឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ

- ផ្តល់វគ្គបណ្តុះបណ្តាលបំប៉នសមត្ថភាពបន្ថែម ទាក់ទងទៅនឹងផ្នែកផែនការអប់រំ ជាពិសេសផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- ជួយសម្របសម្រួលឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំ អនុវត្ត និងពិនិត្យតាមដានផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

- **ការិយាល័យអប់រំ យុវជន និងកីឡាក្រុង-ស្រុក-ខណ្ឌ**
  - ការិយាល័យអប់រំ(បុគ្គលិកការិយាល័យ និងក្រុម DTMT) គួរតែជួយបង្ហាត់បង្រៀន និងបំប៉នទាក់ទងទៅនឹងការរៀបចំ និងការអនុវត្តផែនការ រួមទាំងការលើកសកម្មភាពនានាឱ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំដល់គណៈគ្រប់គ្រងសាលា
  - ចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើដំណើរការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងការប្រើប្រាស់ថវិការបស់សាលារៀន
  - ចូលរួមផ្តល់ព័ត៌មានត្រឡប់ និងអនុសាសន៍កែលម្អទៅលើចំណុចខ្វះខាត និងបញ្ហាប្រឈមនានាដែលសាលាបាន និងកំពុងជួបប្រទះ។

- **សាលារៀន**
  - គណៈគ្រប់គ្រងសាលារៀនគួរតែសិក្សាស្រាវជ្រាវបន្ថែម ទៅលើជំនាញរៀបចំផែនការ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ
  - រៀបចំរចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងសាលា ឱ្យបានច្បាស់លាស់ និងមានដំណើរការពិតប្រាកដ(ចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាព និងការគ្រប់គ្រងថវិកា) ដោយមានសមាសភាពចូលរួមពីបុគ្គលិកក្នុងអង្គភាព តំណាងសិស្ស (យុវជន) អាជ្ញាធរមូលដ្ឋានតំណាងសហគមន៍។ល។
  - ផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមក្នុងការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ឱ្យបានពេញលេញទៅតាមនីតិវិធី និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលក្រសួងបានកំណត់

- ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ពីសកម្មភាពដែលគ្រោងឡើងនៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន ការរៀបចំ ការអនុវត្ត និងលទ្ធផលសម្រេចបានដល់អ្នកពាក់ព័ន្ធទាំងអស់
- ប្រើប្រាស់ថវិកាឱ្យមានតម្លាភាព គណនេយ្យភាព ឱ្យចំគោលដៅសកម្មភាព និងឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាកម្មវិធីឱ្យបានច្បាស់លាស់ត្រឹមត្រូវ និងបង្កលក្ខណៈឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។
- ពង្រឹងសាមគ្គីភាពផ្ទៃក្នុង ពង្រីកទំនាក់ទំនងទៅគ្រប់ភាគីពាក់ព័ន្ធ។

- **សហគមន៍**
  - មាតាបិតា អាណាព្យាបាលសិស្ស រួមទាំងអាជ្ញាធរមូលដ្ឋានគួរតែចូលរួមយ៉ាងសកម្ម និងគាំទ្រគ្រប់សកម្មភាពរបស់សាលារៀន
  - ចូលរួមរៀបចំ និងអនុវត្តផែនការនានារបស់សាលារៀន
  - រក្សាទំនាក់ទំនងល្អជាមួយលោកគ្រូ-អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា ងាយស្រួលក្នុងការផ្តល់ព័ត៌មានត្រឡប់ទៅវិញទៅមក ពីសកម្មភាពផ្សេងៗ និងលទ្ធផលសិក្សារបស់កូន
  - ចូលរួមត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីការរៀបចំ និងការអនុវត្តសកម្មភាពនានា រួមទាំងការប្រើប្រាស់ថវិការបស់សាលារៀន
  - ជួយបំផុសបំផុលពីសកម្មភាពផ្សេងៗរបស់សាលារៀន និងស្វែងរកសប្បុរសជននានា ដើម្បីជួយអភិវឌ្ឍសាលារៀន។

## ឯកសារយោង

Forojalla.S,B. ( 1993 ). *Educational planning and Development.* Newyork: St. Martin‟s Press.

Joilu Oumer. ( 2009/100 ). *strategic and school Developmental Planning.Module.Syllabus.* ( Unpublished Document ).

Adams Dk. ( 2006 ). *Extending the Educational Planning Discourse=Conceptual and Paradigmatic Exploration.* Comp. Educ. Re 30( 4 )415.

Agarwal R.D. ( 1982 ). *Organization and Management.* Diehi: Tata McGraw-Hill publishing Company limited.

Aikasman and Usnterhalter, E. ( 2005 ). *Beyond access: Transferring policy and Practice for Gender Equity in education.* London: oxford.

Benveniste, G. ( 1970 ). *Bureaucracy and National planning.A sociological case Study in Mexico.* New York: praeger publisher.

Buchert, Line. ( 1998:30 ). *Education reform in the so UNESCO publishers; France.*

Caillods, Francoise. ( 2005 ). *The New Educational Environment; planning for participation.* UNESCO.

Carron, Gabriel; Maharishi, Khalid; DE Granule, Anton; Gay, Dorian; Chophouse, Sultana. ( 2010 ). *Strategic planning: Concept and Rationale.* Education sector planning working.

Chandan,J.S. ( 1987 ). *Management theory and practice.* Delhi: Hundustan offset Printers.

Collins,UnaM.Chf. ( 1996 ). *Devolopnig a School Plan=A Step by stap Approach.* Dubiln: Marino Institute of Education.

Cunninghum,W.G. (1982). *Systematic planning for educational change.* USA: Mayfield Publishing Company.

DegaregeMinale. (1998). *"Regional Disparities in primary schooling of Ethiopia; Implications policy making and Educational planning" Thesis, Addis Ababa University.*

Forojalla.S,B. (1993). *Educational planning and Development.* Newyork: Martin"s Press.

Foskett, Nlumby. (2003: viii). *Leading and managing education: International Dimension.* London: SAGE publication.INC Francisco.

Gatewood, R.D. Tayor, R.R. and Ferell, O.C. (1995). *management; comprehension, Analysis and Application.* Chicago: Richared D. Irwin Inc.

Griffin, W. Ricky. (1999). *Managements.* USA: Houghton. Mifflin Company: 6th Edition.

Hatland, A.andIshumi, A.G.M. (1984). *Educational planning in Developing Countries.* Sweden: Graphic Systems AB Gorebord.

Holmes.et.al. (1998). *In educational policy for effective school.* New York Teacher collage press.

HussienKedir. (2002). *Local Capacity in Implementing Decentralization of Education Management in Oromia Regional State",Thesis.* AAU(UNPub).

Mbamba, A.M. (1992). *Book of Reading in Educational Management.* Harare: Mozonjorora paper converter (Pvt) Ltd.

Ornstein Allanc.and Hunkins F.P. (1998:310). *curriculum foundation, principles, and issue (3rd Ed).* USA: Allyn and Bacon.

*papers, Working Paper 1.* (គ្មានថ្ងៃ). Paris: IIEP-UNESCO.

Ubben. G. and Hughes, L. (1997). *The principals: creative school (3rd).* Boston Ellyn and bacon.

UNESCO. ( 1970 ). *Administrative Aspect of Educational Planning. An IIEP Seminar.* Paris.

UNESCO. ( 2005 ). *Literacy For life. EFA Global monitoring Report 2006.* Summary Paris: UNESCO publishing.

UNESCO/IIEP.UNESCO. ( 2001 ). *Planning by Detecting; IIEP New letter.Vol. Xix No, 3.*

Woodhall, Maurcen. ( 1992 ). *Cost Benefit Analysis in Educational planning.* Paris: UNESCO.

ក្រសួងអប់រំ យុវជន និងកីឡា. ( ឆ្នាំ២០១៦ ). *ប្រកាសលេខ ៧៦១ អយក.ប្រក "ស្តីពីការកំណត់គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអបពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំ".*

ក្រសួងអប់រំ យុវជន និងកីឡា. ( ឆ្នាំ២០១៧ ). *"ឯកសារណែនាំស្តីពីការរៀបចំផែនការអភិវឌ្ឍសាលារៀនសម្រាប់សាលាបឋមសិក្សា".*

ក្រសួងអប់រំ យុវជន និងកីឡា. ( ឆ្នាំ២០១៨ ). *ផែនការយុទ្ធសាស្រ្តថវិកា២០១៩-២០២១.*

គោលនយោបាយក្នុងវិស័យអប់រំ. ( ឆ្នាំ ២០១៦ ). *ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ.*

ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៤. ( គ្មានថ្ងៃ ). *របស់ក្រសួងអប់រំ យុវជន និងកីឡា.*

*ផែនការយុទ្ធសាស្រ្តវិស័យអប់រំ.* ( ឆ្នាំ២០១៤-២០១៨ ).

*ផែនការយុទ្ធសាស្រ្តវិស័យអប់រំ.* ( ឆ្នាំ២០១៩-២០២៣ ).

មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង. ( ឆ្នាំ២០២០ ). *ស្ថិតិបុគ្គលិកអប់រំ.*

រាជរដ្ឋាភិបាល អនុក្រឹត្យលេខ ៥៤ អនក្រ.បក. ( ឆ្នាំ២០១៨ ). *"ស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល".*

វិទ្យាស្ថានជាតិអប់រំ. ( ឆ្នាំ២០១៥ ). *វគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា «ការវិភាគវិស័យអប់រំ ».*

វិទ្យាស្ថានជាតិអប់រំ. (ឆ្នាំ២០១៧). *វគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំផែនការវិស័យអប់រំនៅកម្ពុជា« សេចក្តីផ្តើមស្តីពីការរៀបចំ ផែនការអប់រំនៅកម្ពុជា».*

សារាចរណែនាំ លេខ២ សរណន ចុះថ្ងៃទី៩ ខែមេសា. (ឆ្នាំ២០១៨). *ស្តីពី «ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១».*

សួងអប់រំ យុវជន និងកីឡា. (ឆ្នាំ២០០៦). *ការគ្រប់គ្រងរដ្ឋបាល.*

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ. (ឆ្នាំ២០១០). *អភិក្រមជំនួយស្មារតីស្តីពី គោលការណ៍នៃការគ្រប់គ្រង ការបំពេញការងារក្នុងវិស័យអប់រំ.*

# ឧបសម្ព័ន្ធ(ក)

## កម្រងសំណួរនៃការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

### សូមគោរពជូន: គណៈគ្រប់គ្រងសាលា លោកគ្រូ-អ្នកគ្រូ

ខ្ញុំបាទឈ្មោះ ទេព គង្គា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមប្រធានបទ " **ការរៀបចំ និងអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន**"។

អាស្រ័យហេតុនេះសូមលោក លោកស្រី មេត្តាជួយផ្តល់ចម្លើយចំពោះសំណួរខាងក្រោមដោយអនុគ្រោះ។ **គ្រប់ចម្លើយរបស់លោក លោកស្រីនឹងត្រូវបានរក្សាជាសម្ងាត់**។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក លោកស្រី។

**កម្រងសំណួរស្រាវជ្រាវចែកចេញជា៤ផ្នែកដូចខាងក្រោម៖**

- **ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន**
- **ផ្នែកទី២៖ មុខងារបច្ចុប្បន្ន និងបទពិសោធន៍ការងារ**
- **ផ្នែកទី៣៖ ការអនុវត្តផែនការ**
- **ផ្នែកទី៤៖ តម្រូវការបណ្តុះបណ្តាល**

**ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន**

១. ភេទ ស្រី ______ប្រុស ______

២. អាយុ __________ ឆ្នាំ

**ផ្នែកទី២៖ មុខងារបច្ចុប្បន្ន និងបទពិសោធន៍ការងារ**

៣. តើបច្ចុប្បន្នអ្នកមានតួនាទីជាអ្វីនៅក្នុងសាលារបស់អ្នក?

…………………………………………………………………………………………………………

…………………………………………………………………………………………………………....

……………………………………………………………………………………………………

……………………………………………………………………………………………………

៤. តើអ្នកមានតួនាទីនេះ តាំងពីឆ្នាំណា?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៥. តើក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ របស់សាលាអ្នកមានសកម្មភាពអ្វីខ្លះ? ចូររៀបរាប់។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៦. តើអ្នកណាជាអ្នកលើកសកម្មភាពទាំងនោះឱ្យអ្នក?

a. ខ្ញុំលើកខ្លួនឯង ______

b. មានការប្រជុំមន្ត្រីក្នុងការិយាល័យខ្ញុំរួចឯកភាពគ្នាលើកសកម្មភាពទាំងនេះ______

c. នាយកនាយករងនិងគណនេយ្យជាអ្នកលើកសកម្មភាពទាំងនេះ______

d. ថ្នាក់លើជាអ្នកលើកសកម្មភាពទាំងនេះឱ្យ______

e. ផ្សេងៗ (សូមរៀបរាប់)

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

៧. តើអ្នកផ្អែកលើកត្តាអ្វីខ្លះ ក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំ២០១៩នេះ? ចូររៀបរាប់ពីជំហានសំខាន់ៗ ក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំរបស់សាលាអ្នក ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់ដំណាក់កាលចុងក្រោយ។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

## ផ្នែកទី៣៖ ការអនុវត្តផែនការ

៨. តើផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩របស់អ្នកអនុវត្តបានប៉ុន្មានភាគរយសរុបជារួម និងតាមសកម្មភាពនីមួយៗ ? តើកត្តាអ្វីខ្លះដែលធ្វើឱ្យការអនុវត្តសកម្មភាពទាំងនោះបានឬមិនបាន១០០%?

%សរុបជារួម៖………………មូលហេតុ……………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ……………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ……………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ……………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ……………………………………………………………………

……………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ………………………………………………………………………

…………………………………………………………………………………………………………

………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

%សកម្មភាព៖………………មូលហេតុ………………………………………………………………………

…………………………………………………………………………………………………………

…

…………………………………………………………………………………………………………

…………………………………………………………………………………………………………

%សកម្មភាព៖……………………មូលហេតុ…………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

៩.តើអ្នកពេញចិត្តនឹងលទ្ធផលនៃការអនុវត្តផែនការនោះដែរឬទេ? ហេតុអ្វី?

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

១០.តើសកម្មភាពខាងក្រោមនេះ សកម្មភាពណាខ្លះដែលអ្នកបានធ្វើនិងសកម្មភាពណាខ្លះដែលអ្នកមិនបានធ្វើ។

| សកម្មភាព | បានធ្វើ | មិនបានធ្វើ |
|---|---|---|
| ការកំណត់គោលនយោបាយអប់រំ | | |
| ហេតុវិនិច្ឆ័យវិស័យអប់រំ | | |
| កំណត់ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ | | |
| កំណត់យុទ្ធសាស្ត្រអប់រំ | | |
| ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ | | |
| បង្កើតគំរូ (Simulation) | | |
| រៀបចំផែនការក្នុងរយៈពេលមធ្យមទៅវែង (៣ទៅ៥ឆ្នាំ) | | |
| ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | | |
| រៀបចំកម្មវិធី ឬគម្រោងអប់រំ | | |
| ការអនុវត្តផែនការ | | |
| ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ | | |
| ការរៀបចំផែនការថវិកាប្រចាំឆ្នាំ | | |
| គ្រប់គ្រងកម្មវិធី និងគម្រោង | | |
| ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | | |
| បង្កើតក្របខណ្ឌកម្មវិធីដែលមានសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | | |
| ប្រមូលទិន្នន័យ ដំណើរការ និងវិភាគទិន្នន័យ | | |
| តាមដានប្រតិបត្តិការថវិកា | | |
| ផ្សេងៗ៖ (សូមបញ្ជាក់) | | |

១១. ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ តើអ្នកបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងផែនការអប់រំដែរឬទេ?

[ ] បាន [ ] មិនបាន [ ] ខ្ញុំមិនដឹងទេ

ប្រសិនបើបាន ចូរបញ្ជាក់ឈ្មោះវគ្គបណ្តុះបណ្តាល រយៈពេល ស្ថាប័នបណ្តុះបណ្តាល និងប្រធានបទរបស់វគ្គបណ្តុះបណ្តាលនោះ។

| ប្រធានបទ | ស្ថាប័នបណ្តុះបណ្តាល | រយៈពេលបណ្តុះបណ្តាល(ចំនួនថ្ងៃ) | តើការបណ្តុះបណ្តាលនេះទាក់ទងនឹងការកិច្ចរបស់អ្នកដែរឬទេ? |
|---|---|---|---|
| | | | [ ] បាទ<br>[ ] ទេ |
| | | | [ ] បាទ<br>[ ] ទេ |
| | | | [ ] បាទ<br>[ ] ទេ |

១២. ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ តើអ្នកបានទទួលការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងផែនការអប់រំដែរឬទេ?

[ ] បាន [ ] មិនបាន [ ] ខ្ញុំមិនដឹងទេ

ប្រសិនបើ បាន តើអ្នកគិតថាវគ្គបណ្តុះបណ្តាលនោះមាន៖

[ ] សារៈសំខាន់ខ្លាំងសម្រាប់ការអភិវឌ្ឍការងាររបស់ខ្ញុំផ្នែកគ្រប់គ្រងនិងផែនការអប់រំ

[ ] សារៈសំខាន់សម្រាប់ការអភិវឌ្ឍការងាររបស់ខ្ញុំផ្នែកគ្រប់គ្រងនិងផែនការអប់រំ

[ ] សារៈសំខាន់តិចតួចសម្រាប់ការអភិវឌ្ឍការងាររបស់ខ្ញុំផ្នែកគ្រប់គ្រងនិងផែនការអប់រំ

[ ] មិនមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍការងាររបស់ខ្ញុំផ្នែកគ្រប់គ្រងនិងផែនការអប់រំ

១៣. ប្រសិនបើអ្នកបានចូលរួមវគ្គបណ្តុះបណ្តាល តើអ្នកបានប្រើប្រាស់វានៅក្នុងការងាររបស់អ្នកដែរឬទេ? [ ] បាន [ ] ទេ

ប្រសិនបើបាន ចូរផ្តល់ឧទាហរណ៍ពីរបៀបដែលអ្នកបានប្រើប្រាស់។

| |
|---|
| |

**ផ្នែកទី៤៖ តម្រូវការបណ្តុះបណ្តាល**

១៤. ចំពោះសកម្មភាពនីមួយៗខាងក្រោម ចូរបញ្ជាក់អំពីកម្រិតសមត្ថភាព និងតម្រូវការរបស់អ្នកក្នុងការបណ្តុះបណ្តាល

| | កម្រិតសមត្ថភាព | | | | តម្រូវការបណ្តុះបណ្តាល | |
|---|---|---|---|---|---|---|
| | មិនដឹង | ដឹងខ្លះ | អាចប្រើប្រាស់បាន | មានជំនាញ | បាទ | ទេ |
| ការកំណត់គោលនយោបាយអប់រំ | | | | | | |
| ហេតុវិនិច្ឆ័យវិស័យអប់រំ | | | | | | |
| កំណត់ជម្រើសគោលនយោបាយដោយផ្អែកលើហេតុវិនិច្ឆ័យ | | | | | | |
| កំណត់យុទ្ធសាស្ត្រអប់រំ | | | | | | |
| ការរៀបចំផែនការ កម្មវិធី និងគម្រោងអប់រំ | | | | | | |
| បង្កើតគំរូ(Simulation) | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| រៀបចំផែនការក្នុងរយៈពេលមធ្យម ទៅវែង (ឆ្នាំ៥ទៅ៣) | | | | | | |
| ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា | | | | | | |
| រៀបចំកម្មវិធី ឬគម្រោងអប់រំ | | | | | | |
| ការអនុវត្តផែនការ | | | | | | |
| ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ | | | | | | |
| ការរៀបចំផែនការថវិកាប្រចាំឆ្នាំ | | | | | | |
| គ្រប់គ្រងកម្មវិធី និងគម្រោង | | | | | | |
| ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | | | | | | |
| បង្កើតក្របខណ្ឌកម្មវិធីដែលមានសូចនាករសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃផែនការ កម្មវិធី និងគម្រោង | | | | | | |
| ប្រមូលទិន្នន័យ ដំណើរការ និងវិភាគទិន្នន័យ | | | | | | |
| តាមដានប្រតិបត្តិការថវិកា | | | | | | |

១៥. នៅក្នុងចំណោមសមត្ថភាពដែលអ្នកត្រូវការទាំងអស់ តើសមត្ថភាពណាខ្លះដែលអ្នកគិតថា អ្នកត្រូវពង្រឹងបន្ថែម? ចូរជ្រើសរើសសមត្ថភាពសំខាន់ៗបំផុតចំនួន៣ និងដាក់តាមលំដាប់អាទិភាព។

១. ……………………………………………………………………………………………………

២. ……………………………………………………………………………………………………

៣. ……………………………………………………………………………………………………

# ឧបសម្ព័ន្ធ(ខ)

# លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :**១៩១**វជអ.**

**គោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង**

**កម្មវត្ថុ៖** សម្រួលដល់ការស្រាវជ្រាវរបស់និស្សិតឈ្មោះ **ទេព គង្គា** នៅតាមវិទ្យាល័យនានា ក្នុងខេត្តស្វាយរៀង។

**យោង៖** ផែនការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានជ្រាបថា លោក **ទេព គង្គា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំពុងទទួលការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំមានគម្រោងចុះស្រាវជ្រាវលើប្រធានបទស្តីពី **«ការរៀបចំ និងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន»** ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ លោក **ទេព គង្គា** នឹងចែកកម្រងសំណួរបំពេញតាមរយៈ Google Form និងសម្ភាសន៍តាមប្រព័ន្ធ ONLINE ដល់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ដែលកំពុងបំពេញការងារនៅវិទ្យាល័យនានា នៅខេត្តស្វាយរៀង ដែលប្រព្រឹត្តទៅចាប់**ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០។**

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយសម្រួលដោយក្តីអនុគ្រោះ។

សូមលោកប្រធានទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ

ថ្ងៃចន្ទ ៨រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១០៥ វជអ.

## លិខិតបង្គាប់ការ

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរងរបស់និស្សិត ទេព គង្គា ក្នុងការសរសេរនិក្ខេបបទបញ្ចប់វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ នៅវិទ្យាស្ថានជាតិអប់រំ៖

១-គ្រូដឹកនាំបង្គោល

ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

២-គ្រូដឹកនាំរង

លោក បាន គនហេង

ឯកឧត្តម និងលោកដូចមានរាយនាមខាងលើត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិនា ឆ្នាំ២០២០
ជ.នាយកវិទ្យាស្ថានជាតិអប់រំ
នាយករង

បណ្ឌិត.នួន_រីទ្ធី

**កន្លែងទទួល៖**
-ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**
**លេខ......✓........វជអ**

## បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧
## កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្ដីផ្ដើម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ២ | រំលឹកទ្រឹស្ដី | ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៣ | វិធីសាស្ត្រស្រាវជ្រាវ | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការ ពិភាក្សា | ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៥ | សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |

កំណត់សម្គាល់:

- ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាល ថ្នាក់ក្រោយឧត្ដម នៅវិទ្យាស្ថានជាតិអប់រំ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ **បទបង្ហាញសាកល្បង**ការពារការសរសេរនិក្ខេបបទ។
- ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ពិធីការពារការនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្ដមនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់ទងគណៈកម្មការប្រតិបត្តិនៃការបណ្ដុះបណ្ដាលថ្នាក់ក្រោយឧត្ដម សម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោក បណ្ឌិត នូវ វ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ។

ថ្ងៃសុក្រ ០៤ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :......./.......ខជអ.

## បំណែងចែកគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ
## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧
## ដែលប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០
## នៅវិទ្យាស្ថានជាតិអប់រំ

**គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**

| ក្រុមទី១ | | ក្រុទី២ | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | ១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម |
| ២- ឯកឧត្តម | នៀ សុផន | ២-លោកបណ្ឌិត | នូវ វីរ៉ា |
| ៣-លោក | ឌី បុណ្ណា | ៣-លោកស្រី | ប៊ុន សុផានី |
| ៤-លោក | ថៃ ហេង | ៤-លោក | ចាប រតនា |
| ៥-លោក | ម៉ន មុនិន្ទ | ៥-លោកបណ្ឌិត | អាន វ៉ុប្រាវ |
| ៦-លោកបណ្ឌិត | នី រដ្ឋា | ៦-លោកស្រី | នូ ចន្ទី |
| ៧-លោកបណ្ឌិត | ឈាង សង្វាត | ៧-លោក | សៀង វិសនា |

**គណៈកម្មការកណ្តាល និងរៀបចំ**

| ក្រុមទី១ | | ក្រុមទី២ | |
|---|---|---|---|
| ៨-លោក | លឹម វ៉ាន់ | ៨-លោក | ឡេង បុរី |
| ៩-លោក | លន លីណា | ៩-លោកស្រី | ហង់ ស្រីម៉ាច |
| ១០-លោក | ឡុច ចាន់ថន | ១០-លោក | ហ៊ីង សារៈបុត្រ |
| ១១-លោកស្រី | ទ្រី វីណា | ១១-លោក | ម៉ែន សុខសុន្ទី |

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
លេខ :...............ទជអ.

# លិខិតអញ្ជើញ

**សូមគោរពអញ្ជើញ** ៖ **និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

*ព័ត៌មានបន្ថែម ៖*

- ✓ *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវដៃខ្លីឬវែងពណ៌ស និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- ✓ *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*